សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Royal University of Law and Economics


3

## សារណាបញ្ចប់ការសិក្សា

# ផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ លោក **វ៉ាត់ ចាន់ធី**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សាផន**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **វ៉ាត់ ចាន់ធី** ជានិស្សិតឆ្នាំទី៤ ផ្នែក នីតិសាស្ត្រ ថ្នាក់ L4C4 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវកតញ្ញូតាធម៌ និងគោរពថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដ៏មានគុណឥតគណនាសំរាប់រូបកូន ដែលរូបលោកទាំងទ្វេបានផ្តល់នូវកំណើតដល់រូបកូន ហើយបានព្យាយាមអស់ពីកំលាំងកាយចិត្តដើម្បីចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់នូវសេចក្តីស្រលាញ់ដ៏ថ្លៃថ្លាដែលមិនអាចកាត់ថ្លៃបាន ប្រកបទៅដោយ ក្តីមេត្តា ករុណា ក្នុងការអប់រំទូន្មានប្រៀនប្រដៅដល់រូបកូនអោយក្លាយទៅ ជាកូនល្អ សិស្សល្អ និង មិត្តល្អនៅក្នុងសង្គម។

ម្ចាស់ជំនួយទាំងអស់ ជាពិសេស **អង្គការមូលនិធិសិទ្ធិកុមារ** ដែលបានឧបត្ថមដល់រូបខ្ញុំបាទបានបន្តការសិក្សានៅថ្នាក់បរិញ្ញាបត្រនេះ តាមរយៈកម្មវិធីអាហាររូបករណ៍របស់អង្គការ Norway House ក្រោមការឧបត្ថមដោយលោក Finn Bjornstad ។

**ឯកឧត្តម សាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស និងលោក លោកស្រីសាស្ត្រាចារ្យ** ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកំលាំងកាយ ចិត្ត ក្នុងការបង្ហាត់បង្រៀន និងផ្តល់នូវចំណេះដឹងយ៉ាងច្រើនក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។

**លោកសាស្ត្រាចារ្យ គង់ សាផន** ដែលបានចំណាយពេលវេលាដ៏មានតម្លៃបំផុតសម្រាប់ ការបង្ហាត់បង្ហាញ នឹង ដឹកនាំខ្ញុំបាទក្នុងការរៀបចំចងក្រងសារណានេះឡើង ប្រកបដោយជោគជ័យ ដែលនេះជាគុណនូបការៈយ៉ាងថ្លៃថ្លាបំផុត ដែលខ្ញុំមិនអាចបំភ្លេចបាន។

**មិត្តភ័ក្ក បងប្អូន** ដែលតែងតែជួយផ្តល់ជាមតិយោបល់ក៏ដូចជាចំណេះដឹង រួមទាំងការលើកទឹកចិត្តមកដល់ខ្ញុំគ្រប់ពេលវេលា។

ជាទីបញ្ចប់ខ្ញុំសូមលើកហត្ថាប្រណម្យ បួងសួងអស់វត្ថុស័ក្តិសិទ្ធិក្នុងលោក ប្រទានពរ ដល់លោកអ្នកមានគុណទាំងទ្វេ ម្ចាស់ជំនួយ ព្រមទាំង ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោកព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ លោកស្រីសាស្ត្រាចារ្យ មិត្តភ័ក្ក បងប្អូនទាំងអស់ ឲ្យជួបប្រទះនូវពុទ្ធិពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ

# អារម្ភកថា

ខ្ញុំបាទមានសេចក្តីត្រេកអរ និង មោទនភាពយ៉ាងក្រៃលែង ដែលសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់ឱកាសដល់ខ្ញុំបាទ ដើម្បីធ្វើការស្រាវជ្រាវ និងចងក្រងនូវអត្ថបទស្នាដៃនេះឡើង ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និង ក៏ដូចជាទុកជាបេតិកភណ្ឌ សម្រាប់ជាកេរ្តិ៍មរតករបស់ខ្ញុំមួយផងដែរ។ ដោយឆ្លងកាត់តាមរយៈការចង្អុលបង្ហាញពីលោកសាស្ត្រាចារ្យ **គង់ សាផន** ដែលជាសាស្ត្រាចារ្យដឹកនាំ ខ្ញុំបាទបានសម្រេចចិត្តទទួលយកនូវប្រធានបទស្តីពី **"ផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច"** នេះមកធ្វើការស្រាវជ្រាវ។

ចំពោះការស្រាវជ្រាវទៅលើប្រធានបទនេះ ខ្ញុំបាទបានជួបប្រទះនូវការលំបាកខ្លាំង ដោយហេតុថាប្រធានបទនេះគឺជា ប្រធានបទមួយថ្មីដែលពិបាកក្នុងការស្រាវជ្រាវ បូករួមទាំងការខ្វះខាត នូវព័ត៌មាន ឯកសារដែលពាក់ព័ន្ធជាដើម។ មួយវិញទៀត ដោយហេតុតែពេលវេលាក្នុងការសរសេរខ្លី ហើយបូករួមទាំងសមត្ថភាពខ្ញុំបាទផ្ទាល់នៅមានកម្រិត នឹងព្រមទាំងការខ្វះការយកចិត្តទុកដាក់ពីស្ថាប័នដែលពាក់ព័ន្ធផងដែរនោះ ទើបណ្តាលឲ្យការតាក់តែងនូវសារណាបទមួយនេះ មិនមានលក្ខណៈល្អប្រសើរផងដែរ។ តែយ៉ាងណាមិញ ដោយការតាំងចិត្ត ការព្យាយាម ខិតខំប្រឹងប្រែងដោយអស់ពីកម្លាំងកាយ ចិត្ត ប្រកបដោយការលះបង់មួយចំនួនផងដែរនោះ ក៏បានធ្វើឲ្យ សារណានេះ បានលេចឡើង និងសម្រេចបានរួចរាល់ជាស្ថាពរផងដែរ។

ជាការពិតណាស់ថា នូវរាល់ការតាក់នូវស្នាដៃអ្វីមួយ វាគឺជៀសមិនផុតពីការដែលកើតមាននូវកំហុសនោះទេ យ៉ាងណាមិញ ចំពោះស្នាដៃមួយនេះក៏ដូចគ្នាផងដែរ ពោលគឺប្រាកដជាមានចំណុចខ្វះខាត និងកំហុសណាមួយកើតមានឡើងជាក់ជាពុំខាន ហេតុដូចនេះ ប្រសិនបើមានកំហុស ផ្នែកខ្លឹមសារ អក្ខរាវារុទ្ធ ពាក្យពេចន៍ អត្ថន័យ នឹង នូវរាល់កំហុសទាំងឡាយផ្សេងៗទៀតនោះ ទោះបីដោយចេតនាក្តី ដោយអចេតនាក្តី ខ្ញុំបាទសូមធ្វើការសូមអធ្យាស្រ័យ និងអភ័យទោសទុកជាមុន និងសូមឲ្យលោកអ្នកមេត្តាយោគយល់ នឹងសន្តោសប្រណីដោយក្តីអនុគ្រោះ។

ជាទីបញ្ចប់ ខ្ញុំបាទសូមគោរពជូនពរដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សាស្ត្រាចារ្យ ប្រិយមិត្ត មិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវទាំងអស់ ឲ្យជួបតែពុទ្ធិពរទាំង៤ (បួន)ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាឃ្លាតឡើយ៕

## មាតិកា

ទំព័រ

**សេចក្ដីផ្ដើម** ..... ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃផលវិបាកក្នុងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច**

**ផ្នែកទី១.ក្រុមហ៊ុនដែលតម្រូវឲ្យធ្វើការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** ..... ៥

**កថាភាគទី១. ក្រុមហ៊ុនសហកម្មសិទ្ធិ** ..... ៥

**១. ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ** ..... ៥

**២. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត** ..... ៧

**កថាភាគទី២. ក្រុមហ៊ុនមូលធន** ..... ៧

**១. សហគ្រាសឯកត្តបុគ្គលទទួលខុសត្រូវមានកម្រិត** ..... ៧

**២. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត** ..... ៩

**៣. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត** ..... ៩

**កថាភាគទី៣. ក្រុមហ៊ុនពាណិជ្ជកម្មបរទេស** ..... ១០

**១. ការិយាល័យតំណាងក្រុមហ៊ុនបរទេស ឬទីភ្នាក់ងារក្រុមហ៊ុនពាណិជ្ជកម្មបរទេស** ..... ១១

**២. សាខាក្រុមហ៊ុនបរទេស** ..... ១២

**៣. បុគ្គសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស** ..... ១៣

**ផ្នែកទី២. ភារកិច្ចរបស់អ្នកស្នើសុំចុះបញ្ជីក្នុងការចុះបញ្ជីក្រុមហ៊ុនថ្មីមួយ** ..... ១៤

**កថាភាគទី១. ការបំពេញបែបបទសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** ..... ១៤

**១. ប្រមូលឯកសារដែលពាក់ព័ន្ធសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម** ..... ១៤

១.១. សម្រាប់ការចុះបញ្ជីក្រុមហ៊ុនមូលធន ..... ១៤

១.២. ឯកសារសម្រាប់ការចុះបញ្ជីសាខា ឬការិយាល័យតំណាង ..... ១៥

១.៣. ឯកសារសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ ..... ១៦

១.៤. ការចុះបញ្ជីសហគ្រាសឯកបុគ្គល ..... ១៦

**២. ការបង្កើតគណនីនៅធនាគារ** ..... ១៧

**កថាភាគទី២. ការអនុវត្តការចុះបញ្ជីជាក់ស្ដែងនៅលើប្រព័ន្ធស្វ័យប្រវត្តិកម្ម** ..... ១៧

**១. ការបង្កើតគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម** ..... ១៨

**២. ការត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** ..... ១៩

២.១. របៀបបំពេញ និងដាក់ស្នើពាក្យសុំត្រួតពិនិត្យនិងបម្រុងទុកនាមករណ៍ ១៩
២.២.ការទូទាត់កម្រៃសេវាសម្រាប់ការតម្កល់ទុកនាមករណ៍ ១៩
**៣. ការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនថ្មីមួយ** ២០
៣.១.ការបញ្ចូលព័ត៌មានទូទៅ ២១
៣.២. ការបំពេញព័ត៌មានអាសយដ្ឋានរបស់ក្រុមហ៊ុន ២១
៣.៣.ការបញ្ចូលព័ត៌មានអភិបាលក្រុមហ៊ុន ២២
៣.៤.ការបញ្ចូលលព័ត៌មានម្ចាស់ហ៊ុន និងការកាន់កាប់ភាគហ៊ុន ២២
**៤. ការទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម** ២៣
**៥. ការបោះពុម្ពចេញនូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម** ២៤
**កថាភាគទី៣. ការយកឯកសារទៅកាន់ក្រសួងពាណិជ្ជកម្មដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងតម្កល់ទុក** ២៤
**១. ចំពោះក្រុមហ៊ុនមូលធន** ២៤
**២. ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ** ២៥
**៣. ចំពោះក្រុមហ៊ុនពាណិជ្ជកម្មបរទេស** ២៥
**ផ្នែកទី៣. ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម** ២៦
**កថាភាគទី១. រៀបចំប្រព័ន្ធសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម** ២៦
**កថាខណ្ឌទី២. ការជួយបំពេញព័ត៌មាន និងត្រួតពិនិត្យឯកសារ** ២៧
**១.ភារកិច្ចមន្ត្រីទទួលបន្ទុកបញ្ជរ** ២៨
**២. ភារកិច្ចមន្ត្រីចុះលេខកាលប្បវត្តិ និងចម្លងចូលសំណុំពាក្យសុំ** ២៨
**៣. ភារកិច្ចមន្ត្រីប្រថាប់ត្រា និងបែងចែកឯកសារ** ២៩
**៤. ភារកិច្ចមន្ត្រីទទួលបន្ទុករៀបចំឯកសារ** ២៩
**៥. ភារកិច្ចមន្ត្រីបោះពុម្ពគោលការណ៍ និងវិញ្ញាបនបត្រ** ២៩
**៦. ភារកិច្ចមន្ត្រីបញ្ជូនឯកសារ** ២៩
**៧.ភារកិច្ចមន្ត្រីទទួលបន្ទុកតម្កល់ឯកសារ** ៣០
**កថាភាគទី៣. ការផ្ទៀងផ្ទាត់ និង តម្កល់ទុកឯកសារ** ៣០
**១. ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារដើម** ៣០
**២. ការតម្កល់ទុកឯកសារដើម** ៣១

## ជំពូកទី២

## កំណែទម្រង់ពាក់ព័ន្ធនិងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច

**ផ្នែកទី១. កំណែទម្រង់ទូទៅ** ៣២

**កថាភាគទី១: បរិបទការងារ** .................................................. ៣២
**១. ចំពោះអ្នកស្នើ សុំចុះបញ្ជីពាណិជ្ជកម្ម** .................................................. ៣២
១.១. ការផ្លាស់ប្តូរចំពោះការរៀបចំឯកសារ .................................................. ៣២
១.២.ការអនុវត្តជាក់ស្តែងចំពោះការចុះបញ្ជីពាណិជ្ជកម្ម .................................................. ៣៣
១.៣. ការគ្រប់គ្រងព័ត៌មានសហគ្រាស ក្រុមហ៊ុន .................................................. ៣៣
**២. ចំពោះមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម** .................................................. ៣៤
២.១. ការផ្លាស់ប្តូរទម្រង់ការងារ .................................................. ៣៤
២.២. ការផ្តល់សេវាកម្មចុះបញ្ជីពាណិជ្ជកម្ម .................................................. ៣៥
២.៣. ចំពោះការគ្រប់គ្រងបញ្ជីពាណិជ្ជកម្ម .................................................. ៣៧
**កថាភាគទី២. ការប្រែប្រួលចំពោះឯកសារ** .................................................. ៣៧
**១. ចំពោះទម្រង់ប្រតិវេទន៍** .................................................. ៣៧
**២. ចំពោះវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម** .................................................. ៣៨
**ផ្នែកទី២. កំណែទម្រង់ផ្សេងៗដែលទាក់ទងនិងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធ អេឡិកត្រូនិច** .................................................. ៣៩
**កថាភាគទី១. ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៣៩
**១. ភាតព្វកិច្ចក្នុងការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មសារឡើងវិញ** .................................................. ៣៩
**២. ឯកសារតម្រូវសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញ** .................................................. ៤១
**៣. នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៤២
**កថាភាគទី២ .ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៤២
**១. នីតិវិធីក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៤២
**២. ទម្រង់ឯកសារសម្រាប់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៤៣
**៣. ភាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម** .................................................. ៤៣
**កថាភាគ៣. ក្រុមការងាររៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម** .................................................. ៤៤
**១. សមាសភាពក្រុមការងាររៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម** .................................................. ៤៥
**២. ភារកិច្ចក្រុមការងាររៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម** .................................................. ៤៥
**សេចក្តីសន្និដ្ឋាន** .................................................. ៤៦
**អនុសាសន៍** .................................................. ៤៩
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បន្ទាប់ពីបានចូលជាសមាជិកពេញសិទ្ធិ នៃអង្គការពាណិជ្ជកម្មពិភពលោក កាលពីថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០០៤ មក រាជរដ្ឋាភិបាលកម្ពុជា បានខិតខំប្រឹងប្រែងអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មរបស់ខ្លួន ដើម្បីផ្តល់នូវភាពងាយស្រួលក្នុងការបែងចែកកំណើនសេដ្ឋកិច្ចជូនដល់ប្រជាជនជាង១៥ លាននាក់នៅក្នុងប្រទេស។ ស្របពេលបច្ចុប្បន្ននេះ ផ្នែកប្រព័ន្ធព័ត៌មានវិទ្យា និង បច្ចេកវិទ្យាកំពុងតែមានការរីកចម្រើនខ្លាំង ហើយការប្រើប្រាស់នូវប្រព័ន្ធអ៊ិនធឺណែត មានគ្របដណ្តប់ស្ទើរពេញប្រទេសកម្ពុជា ដោយមានការគិតគូរជាលក្ខណៈយុទ្ធសាស្ត្រ ប្រកបដោយចក្ខុវិស័យច្បាស់លាស់រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមបង្កើតឡើងនូវ គម្រោងផែនការមេបច្ចេកវិទ្យាព័ត៌មានវិទ្យា និង ទូរគមនាគមន៍ (ICT master plan) ឡើងដោយក្នុងគោលបំណងសំដៅ កសាងហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាដ៏ទំនើបមួយ ដែលមាននិរន្តរភាព ក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃ និងជាពិសេស គឺដើម្បីបម្រើទៅដល់ការផ្គត់ផ្គង់ នូវការផ្តល់សេវាសាធារណៈរបស់ខ្លួន ជូនដល់ពាណិជ្ជករ និងវិនិយោគិនជាតិ និងអន្តរជាតិ ប្រកបដោយប្រសិទ្ធិភាព គុណភាព តម្លាភាព សមភាពនិងគណនេយ្យភាព។ គម្រោង ICT Master Plant បានទទួលជំនួយហិរញ្ញប្បទានពីម្ចាស់ជំនួយពហុភាគី (MDTF[1]) តាមរយៈកម្មវិធីទ្រទ្រង់វិស័យពាណិជ្ជកម្មនៅកម្ពុជា (TDSP[2]) ដែលក្នុងនោះកម្ពុជាបានទទួលទឹកប្រាក់ពីគម្រោងនេះ សរុប ១៥,៤៥លាន ដុល្លារសហរដ្ឋអាមេរិក[3]។

ទទឹមនឹងនេះ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងពាណិជ្ជ បានផ្តួចផ្តើមបង្កើតនូវប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មឡើង ជាលើកដំបូងរបស់ខ្លួន ដើម្បីដាក់ឲ្យប្រើប្រាស់ក្នុងការផ្តល់នូវសេវាសាធារណៈសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម។ ប្រព័ន្ធនេះត្រូវបានចាប់ផ្តើមអនុវត្តដំបូង នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១៦ ដែលក្នុងនោះមានប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះបញ្ជីពាណិជ្ជកម្មសំខាន់ៗចំនួន៣ (បី) គឺ ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីក្រុមហ៊ុន ប្រព័ន្ធស្វ័យ ប្រវត្តិកម្មចុះបញ្ជីប្រភពដើមនៃទំនិញ និង ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជនាម។ ក្នុងនោះ ប្រព័ន្ធស្វ័យប្រវត្តិកម្ម

[1] MILTI-DONER TRUST FUND

[2] TRADE DEVELOPMENT SUPPORT PROGRAM

[3] ថវិការនេះទទួលបានពីមូលនិធិម្ចាស់ជំនួយ ពហុភាគី (Multi Donor Trust Fund) (វិភាគទានរបស់គណៈកម្មការ អឺរ៉ុប DANIDA និងUNIDO)។ មូលនិធិនេះគ្រប់គ្រង ដោយធនាគារពិភពលោក (WB) ដែលជា "ភាគីទីបីគ្រប់គ្រងមូលនិធិ (Trustee)" ដើម្បីគាំទ្រដល់កម្មវិធីTDSP។ គោលដៅអភិវឌ្ឍន៍ នៃកម្មវិធី TDSP គឺ ដើម្បីគាំទ្រ យុទ្ធសាស្ត្ររបស់ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការផ្សព្វផ្សាយ អភិក្រមគ្របដណ្តប់ លើវិស័យពាណិជ្ជកម្ម (Trade SWAp)។

ចុះបញ្ជីក្រុមហ៊ុនត្រូវបានប្រកាសដាក់ឲ្យដំណើរការ ជាលើកដំបូងកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥[4] ដែលការអនុវត្តនេះ គឺអនុវត្តចំពោះតែការចុះឈ្មោះក្រុមហ៊ុនថ្មីមួយតែប៉ុណ្ណោះ។ ទោះបីជាយ៉ានេះក្តី ដើម្បីឲ្យក្រុមហ៊ុន សហគ្រាសទាំងអស់មកប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តកម្មនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការប្រកាស ទៅក្រុមហ៊ុនទាំងអស់ដែលបានចុះឈ្មោះ រួចរាល់ចំនួន៥២០០ និង កំពុងធ្វើអាជីវកម្មនៅក្នុងប្រទេសកម្ពុជា តម្រូវឲ្យចុះឈ្មោះក្រុមហ៊ុនសារឡើងវិញ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ទៅតាមកាលបរិច្ឆេទដែលបានកំណត់ដោយប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ដោយការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញ គឺ មិនត្រូវបានគិតកម្រៃសេវានោះទេ ក៏ប៉ុន្តែបើទោះបីជាកាលបរិច្ឆេទនៃការចុះបញ្ជីសារឡើងវិញនេះ ត្រូវបានផុតក៏ដោយ ក៏ក្រុមហ៊ុន សហគ្រាស នៅតែអាចបន្តធ្វើការចុះឈ្មោះសារឡើងវិញបានដ៏ដែល ប៉ុន្តែក្រុមហ៊ុនត្រូវតែធ្វើការបង់កម្រៃរដ្ឋបាល ដូចជាការចុះបញ្ជីក្រុមហ៊ុនថ្មីមួយ។

ពាក់ព័ន្ធនឹងការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មនេះ លោក **ស៊ុន ចាន់ថុល** អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានអះអាងថា "ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មនេះ និងទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនដូចជា កាត់បន្ថយពេលវេលា កាត់បន្ថយជំនួបមុខដោយផ្ទាល់រវាងមន្ត្រីក្រសួងអនុញ្ញាតឲ្យអ្នកដាក់ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម អាចធ្វើការចុះឈ្មោះក្រុមហ៊ុនពីទីកន្លែងណាមួយនៅក្នុងប្រទេស និង នៅក្នុងពិភពលោកទាំងមូលបាន ដោយមិនចាំបាច់មកកាន់ក្រសួងពាណិជ្ជកម្ម និង អាចធ្វើការបង់កម្រៃសេវា តាមប្រព័ន្ធស្វ័យប្រវត្តិបាន (online payment) ។ ការធ្វើកំណែទម្រង់នៃការចុះបញ្ជីពាណិជ្ជកម្មនេះ គឺ ក្នុងគោលបំណងដើម្បីសម្រួលដល់វិស័យឯកជនក្នុងការបំពេញកិច្ចពាណិជ្ជកម្មរបស់ពួកគេ ដោយកាត់បន្ថយនូវបែបបទ និង លុបបំបាត់នូវអំពីពុករលួយនៅក្នុងក្រសួងផងដែរ"[5]។

តែផ្ទុយមកវិញ យើងឃើញថាចំពោះការអនុវត្តជាក់ស្តែង ប្រព័ន្ធនេះមានភាពស្មុគស្មាញខ្លាំងក្នុងការចុះបញ្ជី ដោយវាគឺជាដំណើរការមួយដែលប្រើប្រាស់នូវឧបករណ៍អេឡិកត្រូនិចទាំងស្រុងបូករួមទាំង ការប្រើប្រាស់នូវប្រព័ន្ធអ៊ិនធឺណែត ដែលជាប្រព័ន្ធព័ត៌មានវិទ្យាមួយ

---

[4]យោងប្រកាសលេខ ២៩៩ ពណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

[5]សំរង់ចេញពីគេហទំព័រ http://www.freshnewsasia.com/index.php/en/13451-2015-12-04-09-23-26.html។

ដែលមានលក្ខណៈស្មុគស្មាញក្នុងការប្រើប្រាស់ផងដែរ។ បន្ថែមទៀត យើងឃើញថា ដើម្បីអាចដំណើរការប្រព័ន្ធនេះបាន អ្នកប្រើប្រាស់ដែលមាន មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម និង អតិថិជនដែលជាអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មទាំងអស់ ត្រូវតែចេះប្រើប្រាស់ប្រព័ន្ធ អ៊ិនធឺណែត និងកុំព្យូទ័រជាចាំបាច់ ។ ម្យ៉ាងទៀតប្រព័ន្ធនេះអាចដំណើរការទៅបាន លុះត្រាណាតែមានកុំព្យូទ័រដែលមានតភ្ជាប់ទៅកាន់ប្រព័ន្ធអ៊ិនធឺណែតរួចជាស្រេច នេះមានន័យថាគឺវាត្រូវការប្រើប្រាស់អ៊ិនធឺណែតជាចាំបាច់ ។

ប្រព័ន្ធនេះបានផ្តល់ឲ្យនូវសេវាចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មចំនួន៥ (ប្រាំ) គឺការត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍ ការចុះបញ្ជីចំពោះក្រុមហ៊ុនថ្មីមួយ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំសេវាផ្លាស់ប្តូរ និង កែប្រែក្រុមហ៊ុន និង ការលុបឈ្មោះក្រុមហ៊ុនចេញពីបញ្ជីពាណិជ្ជកម្ម។ តែចំពោះការផ្តល់សេវាកម្មទាំងនេះជាក់ស្តែងយើងឃើញថា ពុំទាន់អនុវត្តបានទាំងស្រុងនៅឡើងទេ ដោយចំពោះសេវាកម្មមួយចំនួនដូចជាសេវាកម្មផ្លាស់ប្តូរ និងកែប្រែក្រុមហ៊ុន និង សេវាលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម គឺមិនទាន់ត្រូវបានដាក់ឲ្យអនុវត្តតាមប្រព័ន្ធនេះនៅឡើយ។

លើសពីនេះទៅទៀតមានការកំណែទម្រង់ជាច្រើនទៀតដែលពាក់ព័ន្ធ និងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះ ដោយក្នុងនោះមានដូចជាការធ្វើកំណែទម្រង់ចំពោះ បរិបទការងារ ការផ្លាស់ប្តូរទម្រង់ឯកសារ និងព្រមទាំងការផ្លាស់ប្តូរចំពោះនីតិវិធីនៃការផ្តល់សេវាកម្មចុះបញ្ជីពាណិជ្ជកម្មជាអាទ៍។

**ចំណោទបញ្ហានៃការស្រាវជ្រាវ៖** ដោយហេតុថាការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច គឺជាប្រព័ន្ធថ្មីមួយដែលមិនដែលធ្លាប់មានពីមុនមក ហើយវាជាប្រព័ន្ធមួយដែលមានភាពស្មុគស្មាញខ្លាំង ដូចនេះកិច្ចការស្រាវជ្រាវមួយនេះ នឹងបង្ហាញឲ្យលោកអ្នកបានឃើញថា តើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះ វាមានលក្ខណៈយ៉ាងដូចម្តេច? និងថា តើមានបញ្ហាអ្វីខ្លះដែលបានកើតមាន ដែលពាក់ព័ន្ធ និងការអនុវត្តនូវប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មអេឡិកត្រូនិចនេះ?

**គោលបំណងនៃការស្រាវជ្រាវ៖** ចំពោះការស្រាវជ្រាវនេះ គឺធ្វើឡើងដើម្បីបង្ហាញឲ្យឃើញពីចំណុចខ្វះខាត ដែលកើតមានឡើងពីការអនុវត្តការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិចនេះ និង ជួយដោះស្រាយបញ្ហាដែលកើតមានឡើងទាំងនោះ ដោយធ្វើការបង្ហាញពី ចំនុចខ្វះខាត រួមទាំងបង្ហាញពីវិធីសាស្ត្រកែលម្អ តាមរយៈការផ្តល់ជាអនុសាសន៍មួយចំនួន។

**ដែនកំណត់នៃការស្រាវជ្រាវ៖** ចំពោះប្រធានបទស្រាវជ្រាវនេះ ខ្ញុំបាទនិងលើកយកមកសិក្សាតែទៅលើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មនៃក្រសួងពាណិជ្ជកម្ម ហើយ

ផ្តោតសំខាន់ ទៅលើនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម របស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មចំពោះការចុះបញ្ជីក្រុមហ៊ុនថ្មីមួយតែប៉ុណ្ណោះ។ កិច្ចការស្រាវជ្រាវនេះត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៧ រហូតដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០១៧។

**វិធីសាស្ត្រនៃការស្រាវជ្រាវ ៖** ការស្រាវជ្រាវនេះធ្វើឡើងតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ដោយធ្វើការចុះទៅដល់នាយកដ្ឋាចុះបញ្ជីពាណិជ្ជកម្មផ្ទាល់ និង ធ្វើការប្រមូលនូវឯកសារគតិយុត្តិដែលពាក់ព័ន្ធនានា តាមរយៈការចុះស្រាវជ្រាវតាមស្ថាប័នជាក់ស្តែង និង តាម រយៈប្រព័ន្ធអេឡិកត្រូនិចជាដើម ដោយមានប្រើប្រាស់មធ្យោបាយ ក្នុងការប្រមូលទិន្នន័យ តាម រយៈ ការសម្ភាស៍ផ្ទាល់ជាមួយមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម និង សម្ភាស៍ផ្ទាល់ជាមួយអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មជាក់ស្តែង ។

**រចនាសម្ព័ន្ធស្រាវជ្រាវ៖** ប្រធានបទនេះត្រូវបានបែងចែកចេញជា ២ (ពីរ) ជំពូកធំៗ ដែលនៅក្នុងជំពូកនីមួយៗ មានបែងចែកជាផ្នែក ហើយនៅក្នុងផ្នែកនីមួយៗ បែងចែកទៅជាកថាភាគ ហើយកថាភាគនីមួយៗ បែងចែកទៅជាចំនុចតូចៗផងដែរ។ ក្នុងនោះជំពូកទី១ ស្តីពីសញ្ញាណទូទៅនៃផលវិបាកក្នុងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច និង ជំពូកទី២ ស្តីពី កំណែទម្រង់ដែលពាក់ព័ន្ធ និងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច ។

# ជំពូកទី១

## សញ្ញាណទូទៅនៃផលវិបាកក្នុងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច

ដើម្បីអាចធ្វើកំណត់បានថា ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះ មានផលវិបាកអ្វីខ្លះនោះ? យើងគប្បីសិក្សាឲ្យបានស៊ីជម្រៅ និងច្បាស់លាស់ពីរបៀប និង លក្ខណៈនៃការចុះបញ្ជីតាមប្រព័ន្ធនេះជាមុនសិន ព្រោះវាគឺជាសញ្ញាណផ្ទាល់ដែលនាំឲ្យមានផលវិបាកកើតមានឡើង។ ហេតុដូច្នេះនៅក្នុងជំពូកនេះយើងនិងសិក្សាពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិកត្រូនិចនេះ តែខ្ញុំសូមធ្វើការលើកឡើងតែចំពោះការចុះបញ្ជីចំពោះក្រុមហ៊ុនថ្មីមួយតែប៉ុណ្ណោះដែលនៅក្នុងនោះមាន ផ្នែកទី១ស្តីពីក្រុមហ៊ុនដែលតម្រូវឲ្យចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ផ្នែទី២ភារកិច្ចរបស់អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនថ្មីមួយ និង ផ្នែកទី៣ ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មក្នុងការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនថ្មីមួយ។

### ផ្នែកទី១ . ក្រុមហ៊ុនដែលតម្រូវឲ្យធ្វើការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

ដើម្បីឲ្យទទួលបាននីតិបុគ្គលភាពលក្ខណៈ ក្រុមហ៊ុននីមួយៗ ត្រូវតែធ្វើចុះឈ្មោះ នៅក្នុងបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។ ការចុះបញ្ជីត្រូវធ្វើឡើងនៅក្រសួងពាណិជ្ជកម្ម ហើយត្រូវចុះក្នុងបញ្ជីពាណិជ្ជកម្ម នូវគ្រប់ក្រុមហ៊ុន សហគ្រាសទាំងអស់ដែលមានសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាបែបបទនៃការបង្កើត និងចិរវេលារបស់ក្រុមហ៊ុនទាំងនោះមានលក្ខណៈបែបណាក៏ដោយ។ ជាក់ស្តែងក្រុមហ៊ុនដែលច្បាប់កម្ពុជាទទួលស្គាល់ មានតែ២ (ពីរ) ទម្រង់គឺ ក្រុមហ៊ុនសហកម្មសិទ្ធិ និង ក្រុមហ៊ុនមូលធន តែបើចំពោះការចុះបញ្ជីវិញ យើងឃើញថាមាន ៣ (បី) ប្រភេទក្រុមហ៊ុនគឺ ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនមូលធន និងក្រុមហ៊ុនពាណិជ្ជកម្មបរទេស ។

#### កថាភាគទី១. ក្រុមហ៊ុនសហកម្មសិទ្ធិ

តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្រុមហ៊ុនសហកម្មសិទ្ធិមាន ០២ (ពីរ) ទម្រង់គឺ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និង ក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត។

##### ១. ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅគឺជា កិច្ចសន្យារវាងបុគ្គលពីរនាក់ ឬច្រើននាក់ដែលដាក់រួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹង ឬ សកម្មភាពរបស់បុគ្គលទាំងនោះដើម្បីប្រកបពាណិជ្ជកិច្ចរួមគ្នា ក្នុង

គោលដៅរកប្រាក់ចំណេញ។ កិច្ចសន្យានៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅអាចធ្វើឡើងជាលាយល័ក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់។

ប្រសិនបើកិច្ចសន្យានោះ ធ្វើឡើងជាលាយល័ក្ខណ៍អក្សរ សហកម្មសិទ្ធិករទូទៅទាំងអស់ត្រូវចុះហត្ថលេខាលើកិច្ចសន្យានោះ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមាននីតិបុគ្គលភាពដាច់ដោយឡែកពីសហកម្មសិទ្ធិករទូទៅម្នាក់ៗ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ មាននីតិបុគ្គលិកលក្ខណៈចាប់តាំងពីពេលបានចុះញ្ជីស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ហើយមានសិទ្ធិដូចជាៈ ជាម្ចាស់លើចលនទ្រព្យ និងអចលនទ្រព្យក្នុងនាមក្រុមហ៊ុន ធ្វើពាណិជ្ជកិច្ចក្នុងនាមក្រុមហ៊ុន ចុះកិច្ចសន្យាក្នុងនាមក្រុមហ៊ុន នឹងប្តឹង ឬត្រូវគេប្តឹងក្នុងនាមក្រុមហ៊ុន ។

ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅទទួលបាននូវបុគ្គលិកលក្ខណៈសញ្ជាតិខ្មែរ លុះត្រាតែក្រុមហ៊ុនសហកម្មសិទ្ធិទូទៅនោះ មានទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្ម និង កន្លែងធ្វើអាជីវកម្មស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងអត្ថប្រយោជន៍នៅក្នុងក្រុមហ៊ុនចំនួន ៥១% ត្រូវបានកាន់កាប់ដោយរូប វន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ញាតិខ្មែរ ។ សហកម្មសិទ្ធិករអាចបង់ភាគទុនជាសាច់ប្រាក់ជាវត្ថុ ជាសេវាពីមុនដែលបានផ្តល់រួចមកហើយយ៉ាងពិតប្រាកដ ឬ ជាការសន្យាថានិងផ្តល់នូវសេវានាពេលអនាគត់ ។

សហកម្មសិទ្ធិករទូទៅ ក៏អាចដាក់ភាគហ៊ុនជាចំណេះដឹង ឬ សកម្មភាពផ្សេងៗ ប៉ុន្តែមិនត្រូវរាប់បញ្ចូលនូវការប្រើប្រាស់ឥទ្ធិពលដែលទទួលបានពីមុខងារជាមន្ត្រីសាធារណៈ។ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ត្រូវបានគ្រប់គ្រង និងដឹកនាំដោយសហកម្មសិទ្ធិករទូទៅផ្ទាល់ ឬ តែងតាំងអ្នកគ្រប់គ្រង ឬ បណ្ណាធិការ។ បណ្ណាធិការនេះត្រូវបានជ្រើសតាំងដោយ សម្លេងជាឯកច្ឆ័ន្ទ ពីសមាជិកសហកម្មសិទ្ធិករទូទៅទាំងអស់នៃក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ ហើយបណ្ណាធិការ ត្រូវបានជ្រើសចេញពីក្នុងចំណោមម្ចាស់ហ៊ុន ឬ ជ្រើសរើសនូវតតិយជនណាម្នាក់។ សិទ្ធិ និងអំណាចរបស់បណ្ណាធិការ គឺមានកំណត់នៅក្នុងលក្ខន្តិកៈក្រុមហ៊ុន តែក្នុងករណីដែលនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ពុំមានចែងនោះទេ គេសម្មត់ថាសិទ្ធិអំណាចរបស់បណ្ណាធិការ ត្រូវមានពេញមួយកម្មវត្ថុនៃក្រុមហ៊ុន ។ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅដូចជាក្រុមហ៊ុនពាណិជ្ជកម្មផ្សេងទៀតដែរត្រូវបានកំណត់ដោយនាមករណ៍ក្រុមហ៊ុន។ នាមករណ៍នេះ ធ្វើឡើងដោយដាក់ឈ្មោះសហកម្មសិទ្ធិករទូទៅម្នាក់ ឬ ច្រើននាក់ និង ដាក់ឈ្មោះថា "ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ"។

ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅមិនអាចធ្វើការបោះចេញនូវមូលបត្រ ឬអាជ្ញាប័ណ្ណទៅឲ្យតតិយជនបានឡើយ។ ហើយដោយហេតុថាក្រុមហ៊ុនប្រភេទនេះ ឈរលើគោលការណ៍ រាប់អាន

បុគ្គល ហេតុដូច្នេះនូវរាល់ ការទទួលសមាជិកហ៊ុនថ្មីណាមួយ គឺត្រូវតែមានការសម្រេចជាឯកច្ឆ័ន្ទពីសហកម្មសិទ្ធិករទូទៅទាំងអស់។ ទាក់ទិននឹងលក្ខខណ្ឌនេះ យើងសង្កេតឃើញថាក្រុមហ៊ុននេះងាយស្រួលដល់ការរំលាយដោយហេតុថា បើក្នុងករណីដែលក្រុមហ៊ុននេះ និង ត្រូវបានបាត់បង់សមាជិកហ៊ុនណាម្នាក់ ឬ ករណីដែលភាគហ៊ុនទាំងអស់នៃក្រុមហ៊ុនត្រូវបានធ្លាក់ទៅលើតែបុគ្គលតែម្នាក់ នោះក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងត្រូវបានរំលាយ។ ម្យ៉ាងទៀត ក្រុមហ៊ុននេះអាចនឹងត្រូវរំលាយដោយហេតុចម្បងពីរយ៉ាងគឺ ដោយមូលហេតុដែលមានចែងក្នុងកិច្ចសន្យា និងតាមរយៈសេចក្ដីសម្រេចរបស់តុលាការ។

**២. ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត**

ក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត ជាក្រុមហ៊ុនដែលបង្កើតឡើង តាមកិច្ចសន្យារវាង បុគ្គលពីរនាក់ ឬច្រើននាក់ ក្នុងការធ្វើពាណិជ្ជកិច្ចរួមគ្នា ដែលក្នុងនោះមានសមាជិក០២(ពីរ)ប្រភេទ គឺសហកម្មសិទ្ធិករទូទៅ និងសហកម្មសិទ្ធិករមានកម្រិត[6]។ សហកម្មសិទ្ធិករទូទៅ គឺជាអ្នកដឹកនាំក្រុមហ៊ុនសហកម្មសិទ្ធ ដែលជាអ្នកទទួលខុសត្រូវចំពោះក្រុមហ៊ុនរួម និងគ្មានកម្រិត[7]។ សហកម្មសិទ្ធិករទូទៅមានសិទ្ធិក្នុងការគ្រប់គ្រងពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនសហកម្មសិទ្ធិ។ រីឯសហកម្មសិទ្ធិករមានកម្រិត ទទួលខុសត្រូវលើបំណុលរបស់ខ្លួនត្រឹមតែកម្រិតនៃភាគហ៊ុន (ទឹកប្រាក់) ដែលខ្លួនបានដាក់តែប៉ុណ្ណោះ ហើយនឹងគ្មានសិទ្ធិចូលរួមក្នុងការគ្រប់គ្រងក្រុមហ៊ុនឡើយ។ សហកម្មសិទ្ធិករនីមួយៗមានសិទ្ធិក្នុងការផ្ទេរភាគហ៊ុនដូចដែលបានផ្ដល់ឲ្យដោយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ត្រូវចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ហើយនាមករណ៍ក្រុមហ៊ុន ត្រូវដាក់បញ្ចូលឈ្មោះរបស់សមាជិកមួយរូប ឬ ច្រើនហើយត្រូវបញ្ជាក់ថា "ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត"។ ក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត អាចរំលាយតាមការសម្រេចរបស់សហកម្មសិទ្ធិករទាំងអស់ ឬ តាមសេចក្ដីសម្រេចរបស់តុលាការស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**កថាភាគទី២. ក្រុមហ៊ុនមូលធន**

**១. សហគ្រាសឯកត្តបុគ្គលទទួលខុសត្រូវមានកម្រិត**

សហគ្រាសឯកត្តបុគ្គលទទួលខុសត្រូវមានកម្រិតគឺជាប្រភេទក្រុមហ៊ុនមួយនៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលមានម្ចាស់ភាគហ៊ុនតែម្នាក់គត់ ដូចនេះមានន័យថាភាគហ៊ុន១០០

[6] មាត្រា ៦៤នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[7] មាត្រា ៧៥ និង ៨២ នៃច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

(មួយរយ) ភាគរយ ត្រូវបានគ្រប់គ្រងដោយម្ចាស់ហ៊ុនតែម្នាក់គត់[8]។ សហគ្រាសឯកត្តបុគ្គល គឺជាសហគ្រាសមួយ ដែលបានបង្កើតឡើងហើយ បានធ្វើប្រតិបត្តិការដោយបុគ្គលតែម្នាក់ដែលជាម្ចាស់នៃមូលធនទាំងអស់ និងទទួលខុសត្រូវរាល់ការប្រតិបត្តិការរបស់ខ្លួន។ អង្គភាពឯកកម្មសិទ្ធិ មិនតម្រូវឲ្យមានលក្ខន្តិកៈ ឬបទបទបញ្ជាផ្ទៃក្នុងទេ។ ស្ថានការណ៍បែបនេះ ត្រូវបានគេប្រៀបធៀបរូបវន្តបុគ្គលម្នាក់ ដែលបានដឹកនាំការប្រតិបត្តិការពាណិជ្ជកិច្ចរបស់ក្រុមហ៊ុនឯកកម្មសិទ្ធិទៅ និង ឯកកម្មសិទ្ធិករម្នាក់។ រូបវន្តបុគ្គលបែបនេះ មិនមានការបាត់បង់ស្ថានភាពស្របច្បាប់របស់ខ្លួននោះទេ ទោះបីជាវាមិនបានចុះបញ្ជីក្រុមហ៊ុនក៏ដោយ។

ការក្លាយជាម្ចាស់សហគ្រាសឯកបុគ្គលគឺជា នីតិវិធីត្រង់បំផុតក្នុងការបង្កើតអាជីវកម្ម ដោយសារតែវាមានភាពឆាប់រហ័ស និងងាយស្រួលក្នុងការចុះបញ្ជី ដោយមានការបំពេញបែបបទតិចតួចជាងការបង្កើត និងដំណើរការក្រុមហ៊ុនផ្សេងៗទៀត។ ម្ចាស់ហ៊ុនអាចធ្វើការផ្ទេរភាគហ៊ុនមួយផ្នែកឬទាំងស្រុងទៅឲ្យបុគ្គលណាមួយបានហើយករណីដែលក្រុមហ៊ុន មានម្ចាស់ភាគហ៊ុនចាប់ពី២(ពីរ) នាក់ឡើងទៅ នោះសហគ្រាសឯកបុគ្គលនេះ និង ក្លាយទៅជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតវិញ។ ម្ចាស់សហគ្រាសឯកបុគ្គលត្រូវផ្តល់នូវដើមទុនចាប់ផ្តើមដំបូងទាំងអស់ ដែលជាញឹកញាប់ ដើមទុននេះអាចពាក់ព័ន្ធនឹងកម្ចីធនាគារ ដោយការដាក់បញ្ចាំផ្ទះរបស់សហគ្រាស កម្ចីដែលមានការធានាពីមិត្តភ័ក្តិ ឬក្រុមគ្រួសារ។ ម្ចាស់សហគ្រាសប្រភេទនេះ អាចនឹងត្រូវក្សៃយធនដោយម្ចាស់បំណុល ប្រសិនបើអាជីវកម្មនេះមិនបានសងបំណុលរបស់ខ្លួននោះទេ។ នៅក្នុងសហគ្រាសឯកបុគ្គល រាល់គណនី កិច្ចសន្យា ទ្រព្យសម្បត្តិ និងអាជ្ញាប័ណ្ណទាំងអស់ត្រូវដាក់ឈ្មោះរបស់ឯកកម្មសិទ្ធិករ ដែលជាម្ចាស់ (ម្ចាស់សហគ្រាសឯកបុគ្គល/ជាសហគ្រិន)។ ម្ចាស់សហគ្រាសឯកបុគ្គល មានឯករាជ្យភាពក្នុងការពិនិត្យលើអាជីវកម្ម និងមានសិទ្ធិលើប្រាក់ចំណេញទាំងអស់ ។ ប្រាក់ចំណេញដែលត្រូវជាប់ពន្ធដោយផ្ទាល់ ហើយកិច្ចការអាជីវកម្មទាំងអស់ នៅចម្រុះគ្នាជាមួយនឹងកិច្ចការផ្ទាល់ខ្លួនរបស់វា។ ម្ចាស់សហគ្រាសឯកបុគ្គលជា អ្នកទទួលខុសត្រូវដោយខ្លួនឯងចំពោះបំណុល និង កាតព្វកិច្ចទាំងអស់នៃអាជីវកម្មរបស់ខ្លួន ។

តែទោះបីជាយ៉ាងណាក៏ដោយ ម្ចាស់សហគ្រាសឯកបុគ្គល មិនមានលក្ខណៈសម្បត្តិជានីតិបុគ្គលដាច់ដោយឡែកដូចលក្ខណៈនីតិបុគ្គលនៃក្រុមហ៊ុនមូលធនឡើយ។ ហេតុដូច្នេះម្ចាស់ សហគ្រាសឯកបុគ្គល ជាអ្នកទទួលខុសត្រូវ ផ្ទាល់ចំពោះបំណុល និងកាតព្វកិច្ចទាំងអស់នៃអាជីវកម្មរបស់ខ្លួន។ ម្ចាស់សហគ្រាសឯកបុគ្គលដែលជារូបវន្តបុគ្គល (ជាបុគ្គលធម្មតាមិនបំលែងទៅជានីតិ

[8] មាត្រា ៧៧ និង ៧៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

បុគ្គល) នោះគឺជាអង្គភាពអាជីវកម្ម[9]។ នាមករណ៍ត្រូវដាក់បញ្ចូលពាក្យ "ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត" សម្រាប់ការយកមកប្រើប្រាស់ក្នុងពាណិជ្ជកិច្ច។

សហគ្រាសឯកត្តបុគ្គលអាចនឹងត្រូវបានរំលាយដោយម្ចាស់ភាគហ៊ុនផ្ទាល់ ឬ តាមរយៈសេចក្តីសម្រេចរបស់តុលាការ ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ សហគ្រាសឯកបុគ្គលអាចធ្វើអាជីវកម្មដោយមិនចាំបាច់ចុះបញ្ជីពាណិជ្ជកម្មបានតែស្ថានភាពបែបនេះ ជាការអនុវត្តពាណិជ្ជកម្មដោយរំលោភទៅលើច្បាប់។ ក្នុងព្រះរាជាណាចក្រកម្ពុជា មានតែសហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកម្រិតតែមួយប៉ុណ្ណោះ ដែលជាទម្រង់ដាច់ដោយឡែកនៃក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត ដែលមានម្ចាស់ភាគហ៊ុនតែម្នាក់គត់[10]។

## ២. ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត គឺជាប្រភេទក្រុមហ៊ុនមូលធនមួយ ដែលមានម្ចាស់ភាគហ៊ុនចាប់ពី ០២នាក់ រហូតដល់ ៣០នាក់។ ម្ចាស់ភាគហ៊ុននៃក្រុមហ៊ុននេះ អាចជានីតិបុគ្គល ឬរូបវន្តបុគ្គល ដែលមានកាតព្វកិច្ច និងទទួលខុសត្រូវ ត្រឹមកម្រិតនៃដើមទន់របស់ខ្លួន[11]។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវបានគ្រប់គ្រងដោយអភិបាលមួយរូប ឬច្រើនដែលអភិបាលពុំចាំបាច់តែជាម្ចាស់ភាគហ៊ុននោះទេ ។ ម្ចាស់ភាគហ៊ុននីមួយៗ មានសិទ្ធិក្នុងការផ្ទេរភាគហ៊ុនរបស់ខ្លួនដូចដែលបានផ្តល់ឲ្យដោយលក្ខន្តិកៈ និង បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន និងត្រូវគោរពតាមវិធានច្បាប់។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ត្រូវចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ហើយនាមករណ៍ក្រុមហ៊ុនត្រូវបញ្ជាក់ថា"ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត"[12]។ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតអាចនឹងត្រូវរំលាយតាមការសម្រេចចិត្តរបស់សមាជិកហ៊ុនទាំងអស់ ឬតាមសេចក្តីសម្រេចរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា។

## ៣. ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត វាមានទម្រង់ស្រដៀងគ្នាទៅនឹង ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលម្ចាស់ភាគហ៊ុននីមួយៗនៃក្រុមហ៊ុននេះ ទទួលខុសត្រូវត្រឹមតែ

---

[9] សូមមើលសៀវភៅណែនាំសម្រាប់នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្ម និងការធ្វើអាជីវកម្មដោយអនុលោមតាមច្បាប់ របស់ក្រសួងពាណិជ្ជកម្ម។

[10] សូមមើលសៀវភៅស្តីពី នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនថ្មី, ប្រាក់ បូរ៉េត, បោះពុម្ពលើកទី១ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧)។

[11] មាត្រា ៨៦ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[12] មាត្រា ៦៧ និង ៦៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

ដើមទុនដែលខ្លួនបានដាក់តែប៉ុណ្ណោះ ។ ក៏ប៉ុន្តែក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវមានអភិបាលគ្រប់គ្រងក្រុមហ៊ុនយ៉ាងតិច ០៣ (បី) រូបឡើយទៅ ហើយលក្ខណៈពិសេសនោះ គឺវាអាចបោះនូវមូលប័ត្រលក់ជាសាធារណៈបាន[13]។

ជាទូទៅចំពោះធនាគារ និង ក្រុមហ៊ុនធានារ៉ាប់រងត្រូវបានបង្កើតឡើងតាមទម្រង់ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតនេះ។ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចមានម្ចាស់ភាគហ៊ុនច្រើន លើកលែងតែពាណិជ្ជកិច្ចមួយចំនួន ដែលមានការកម្រិតម្ចាស់ភាគហ៊ុន។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយក្រុមប្រឹក្សាភិបាលដែលមានអភិបាលយ៉ាងតិច០៣រូប។ អភិបាលអាចត្រូវបានជ្រើសតាំងពីក្នុងចំណោមម្ចាស់ភាគហ៊ុនទាំងអស់ ឬជ្រើសរើតតិយជនណាម្នាក់។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ត្រូវចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ហើយនាមករណ៍ត្រូវបន្ថែមពាក្យថា "ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត"[14]។ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតអាចនឹងត្រូវរំលាយតាមសេចក្តីសម្រេចរបស់ម្ចាស់ភាគហ៊ុនទាំងអស់ ឬដោយតាមសេចក្តីសម្រេចរបស់តុលាការ។

**កថាភាគទី៣. ក្រុមហ៊ុនពាណិជ្ជកម្មបរទេស**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាប្រភេទក្រុមហ៊ុនមួយដែលបង្កើតឡើងក្រោមច្បាប់បរទេសហើយបានមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា[15]។ ក្រុមហ៊ុនបរទេសត្រូវចាត់ទុកថាកំពុងធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ បានធ្វើសកម្មភាពនានាដូចខាងក្រោម៖

- ជួលការិយាល័យ ជួលកន្លែងផលិត ឬកែច្នៃ ឬសេវាដែលមានរយៈពេលចាប់ពី០១ (មួយ) ខែឡើងទៅ
- ជួលបុគ្គលិកសម្រាប់បម្រើការងារឲ្យក្រុមហ៊ុន ដែលមានរយៈពេលចាប់ពី០១ ខែ(មួយ) ឡើងទៅ
- ធ្វើសកម្មភាពណាមួយដ៏ទៃទៀតដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតិចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេស[16] ។

[13] មាត្រា ៨៧ និង ១១៨ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[14] មាត្រា ៩២នៃច្បាប់ សហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[15] មាត្រា២៧០ នៃច្បាប់ សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)។

[16] មាត្រា២៧២ នៃច្បាប់ សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)។

ក្រុមហ៊ុនដែលធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះបីជាស្ថិតនៅក្នុងរូបភាពណាមួយក៏ដោយត្រូវស្ថិតនៅក្រោមច្បាប់និងយុត្តាធិការតុលាការនៃព្រះរាជាណាចក្រកម្ពុជា ហើយគ្រប់ក្រុមហ៊ុនទាំងអស់ត្រូវតែបំពេញទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា[17]។ ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានតាមបែបបទផ្សេងៗ ស្ថិតនៅក្រោមរូបភាព ជាការិយាល័យតំណាង[18] សាខាក្រុមហ៊ុន និង បុត្តសម្ព័ន្ធ[19]។

### ១. ការិយាល័យតំណាងក្រុមហ៊ុនបរទេស ឬទីស្នាក់ការក្រុមហ៊ុនពាណិជ្ជកម្មបរទេស

ការិយាល័យតំណាងក្រុមហ៊ុនគឺជា ភ្នាក់ងាររបស់ក្រុមដើម ដែលវាពុំមានបុគ្គលភាពដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ ។ ការិយាល័យតំណាងពាណិជ្ជកម្មត្រូវបាន គ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ដែលត្រូវបានជ្រើសរើសដោយក្រុមហ៊ុនមេ[20] នាមករណ៍របស់ការិយាល័យតំណាង ដាច់ខាតត្រូវតែជានាមករណ៍របស់ក្រុមហ៊ុនដើមនៅបរទេស ហើយមានបញ្ជាក់ពាក្យថា "ការិយាល័យតំណាង" នៅខាងមុខ ឬខាងក្រោយ[21]។

ការិយាល័យតំណាងអាចធ្វើសកម្មភាពត្រឹមកម្រិតដូចជា ៖

- ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឲ្យអតិថិជនទាំងអស់ស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន
- ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម នឹងផ្តល់ព័ត៌មានទាំងនេះជូនទៅ ក្រុមហ៊ុនដើមនៅបរទេស
- ស្រាវជ្រាវទីផ្សារនៅក្នុងព្រះជាណាចក្រកម្ពុជា
- ឃោសនាផលិតផល តាំងពិព័រណ៍បង្ហាញផលិតផលនៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ដ៏ទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- ទិញនិងរក្សាទុកទំនិញមួយចំនួនសម្រាប់គោលដៅបម្រើឲ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម
- ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្រុងស្រុក ដើម្បីបម្រើការងារ

[17] មាត្រា២៧៣ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)

[18] ការិយាល័យតំណាងអាចមានលក្ខណៈពីរ គឺការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម។

[19] មាត្រា២៧១ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[20] មាត្រា២៧៥ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)។

[21] មាត្រា២៧៦ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)។

- ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុក ក្នុងនាមឲ្យក្រុមហ៊ុនដើម ហើយពុំអាចធ្វើសកម្មភាពទិញ-លក់និងធ្វើសេវាជាអាជីពប្រចាំឬសកម្មភាពពាក់ព័ន្ធ និងប្រតិ បត្តិការផលិតកែច្នៃ និងសាងសង់ក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ[22]។
  - ការិយាល័យតំណាងក្រុមហ៊ុនបរទេស ឬ ទីភ្នាក់ងារក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចនឹងត្រូវបានរំលាយគ្រប់ពេលវេលា តាមសេចក្តីសម្រេចរបស់ក្រុមហ៊ុនមេរបស់វា ឬ ដោយសេចក្តីសម្រេចរបស់តុលាការ។

### ២. សាខាក្រុមហ៊ុនបរទេស

សាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេសគឺជា សាខាក្រុមហ៊ុនមួយដែលមានទីស្នាក់ការចុះបញ្ជីក្រុមហ៊ុនដើមនៅឯបរទេស ហើយនឹងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុង ដោយក្រុមហ៊ុនដើម ទាំងទ្រព្យសម្បត្តិ និងការទទួលខុសត្រូវលើកាតព្វកិច្ច។ ចំពោះនាមករណ៍របស់សាខានេះ ត្រូវដាក់នាមករណ៍របស់ក្រុមហ៊ុនមេ ដោយសរសេរពាក្យថា "សាខាក្រុមហ៊ុន"។ សាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាទម្រង់នៃក្រុមហ៊ុនពាណិជ្ជកម្មមួយក្នុងប្រទេសកម្ពុជា ដោយក្រុមហ៊ុនមេនៅឯបរទេស ហើយក្រុមហ៊ុនមេបរទេស និងត្រូវទទួលខុសត្រូវលើការខាតបង់ និងបំណុលសាខារបស់ខ្លួនទាំងស្រុង។ សាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេសមិនតម្រូវឲ្យចុះបញ្ជីពិសេសណាមួយសម្រាប់ការធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជាទេ។ ក៏ប៉ុន្តែសាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវតែអនុលោមតាមលក្ខខណ្ឌចុះបញ្ជីនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ព្រមទាំងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងព្រមទាំងលិខិតបទដ្ឋានដែលពាក់ព័ន្ធនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។

សាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាមធ្យោបាយមួយនៃក្រុមហ៊ុនដែលបានបង្កើតនៅបរទេស និងបានបង្កើតកន្លែងអាជីវកម្មក្នុងប្រទេសកម្ពុជា ។

**ចរិតលក្ខខណ្ឌសំខាន់ៗនៃសាខាក្រុមហ៊ុនបរទេសមាន ៖**

- សាខាក្រុមហ៊ុនវាគឺជាកន្លែងដែលក្រុមហ៊ុនក្រៅប្រទេស ដំណើរការអាជីវកម្ម
- នាមករណ៍របស់សាខា ត្រូវតែជានាមករណ៍របស់ក្រុមហ៊ុនដើម ដោយគ្រាន់តែបន្ថែមពាក្យ "សាខា" នៅពីលើ ឬខាងមុខឈ្មោះនេះ
- ទីស្នាក់ការចុះបញ្ជីសាខាក្រុមហ៊ុនត្រូវតែមានទីស្នាក់ការចុះបញ្ជីក្នុងព្រះរាជាណាចក្រកម្ពុជា

[22] មាត្រា២៧៤ នៃច្បាប់សហគ្រាសពាណិជ្ជកម្ម (១៩, មិថុនា, ២០០៥)។

– ការចុះបញ្ជីសាខាក្រុមហ៊ុនមួយ ត្រូវបានបង្កើតឡើងដោយការដាក់ឯកសារចាំបាច់ និងបង់កម្រៃរដ្ឋបាលនៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ។

ការគិតពន្ធ និងលក្ខខណ្ឌផ្លូវច្បាប់ចំពោះការិយាល័យ សាខា ជាទូទៅត្រូវស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់ និង ពន្ធអាករដូចគ្នាទៅនឹងក្រុមហ៊ុនដែលបង្កើតនៅក្នុងប្រទេសកម្ពុជាដ៏ទៃទៀត។ ការអនុលោមតាមច្បាប់ជាបន្តចំពោះសាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវបានតម្រូវដោយច្បាប់ដោយតម្រូវឲ្យផ្ញើនូវផលរបរ គណនី និងកាតព្វកិច្ចផ្សេងៗទៀតជាប្រចាំ។ សាខាក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចនឹងត្រូវបានរំលាយនៅពេលណាក៏បាន ទៅតាមសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម។

### ៣. បុត្តសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស

បុត្តសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជា ក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនបរទេស ("ក្រុមហ៊ុនមេ") នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១ (ហាសិបមួយ) ភាគរយត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ[23]។ ដូចនោះមានន័យថា បុត្តសម្ព័ន្ធត្រូវបានបង្កើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ហើយគ្រប់គ្រងដោយច្បាប់កម្ពុជា ចំណែកឯក្រុមហ៊ុនដើម ដែលជាអ្នកបង្កើតនូវបុត្តសម្ព័ន្ធ គឺស្ថិតនៅបរទេស និងស្ថិតនៅក្រោមច្បាប់បរទេស ហើយដែលកាន់កាប់ភាគហ៊ុននៃក្រុមហ៊ុនបុត្តសម្ព័ន្ធយ៉ាងតិច ៥១ ភាគរយ ។

បុត្តសម្ព័ន្ធមានប្រភេទផ្សេងៗគ្នា ដែលអាចដូចនឹងក្រុមហ៊ុនមេ ឬក្រុមហ៊ុនមេ ទៅតាមកម្រិតដែលច្បាប់បានកំណត់។ ជាក់ស្តែងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម បានធ្វើការបែងចែកប្រភេទក្រុមហ៊ុនពាណិជ្ជកម្ម ជាពីរប្រភេទគឺ ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន ។ ក្រុមហ៊ុនសហកម្មសិទ្ធិមានពីរប្រភេទគឺ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិទទួលខុសត្រូវមានកម្រិត ។ ចំណែកឯកក្រុមហ៊ុនមូលធន មានពីរប្រភេទគឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និងក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ។ ដូចនេះ បុត្តសម្ព័ន្ធក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចនឹងមានទ្រង់ ទ្រាយទៅតាមប្រភេទណាមួយនៃក្រុមហ៊ុនដែលបានរៀបរាប់ទាំងនេះ ។ ជារួមបុត្តសម្ព័ន្ធគឺជាក្រុមហ៊ុន សហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនដែលគ្រប់គ្រងដោយក្រុមហ៊ុនសហកម្មសិទ្ធិ ឬក្រុមហ៊ុនមូលធនមួយផ្សេងទៀតហៅថាក្រុមហ៊ុនមេ[24]។

[23] មាត្រា ២៨៣ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

[24] មាត្រា ២ ចំនុចទី៤ នៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម(១៩, មិថុនា, ២០០៥)។

ចំពោះសញ្ជាតិក្រុមហ៊ុនពាណិជ្ជកម្មបរទេស (បុត្តសម្ព័ន្ធ) តាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម វាពុំអាចទទួលបានសញ្ជាតិខ្មែរទេ ព្រោះច្បាប់បានទទួលស្គាល់បុគ្គលភាពគតិយុត្តសញ្ជាតិខ្មែរក្នុងករណីដែលក្រុមហ៊ុន ដែលមានទីស្នាក់ការចុះបញ្ជីពាណិជ្ជកម្ម និងទីកន្លែងធ្វើអាជីវកម្មនៅកម្ពុជា ហើយចំពោះអត្ថប្រយោជន៍នៃភាគហ៊ុនចាប់ពី ៥១ ភាគរយឡើងទៅ ត្រូវតែជាកម្មសិទ្ធិកាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ តែបុត្តសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេសវិញគឺភាគហ៊ុនរបស់វាចំនួនចាប់ពី ៥១ (ហាសិបមួយ) ភាគរយឡើងទៅត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុនបរទេស ។ ដោយវាជាក្រុមហ៊ុនឯករាជ្យពីក្រុមហ៊ុនមេ ដូច្នេះ នូវរាល់ការគ្រប់គ្រងក្រុមហ៊ុននេះវាបានបង្កើតឲ្យមានអភិបាល មហាសន្និបាត និងមានសវនករដាច់ដោយឡែកពីក្រុមហ៊ុនមេរបស់វា។ ចំពោះការរំលាយបុត្តសម្ព័ន្ធក្រុមហ៊ុនបរទេស វាមានលក្ខណៈដូចទៅនឹងការរំលាយក្រុមហ៊ុនទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផងដែរ ដោយលក្ខខណ្ឌនៃការរំលាយ និង ការជម្រះបញ្ជីគឺត្រូវអនុវត្តទៅតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម និងទៅតាមប្រភេទនៃក្រុមហ៊ុនដែលបុត្តសម្ព័ន្ធនោះបានបង្កើតឡើង។

## ផ្នែកទី២. ភារកិច្ចរបស់អ្នកស្នើសុំចុះបញ្ជីក្នុងការចុះបញ្ជីក្រុមហ៊ុនថ្មីមួយ

អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មសំដៅលើ បុគ្គលទាំងឡាយណាដែលច្បាប់ផ្តល់សិទ្ធិ និងកាតព្វកិច្ចទៅឲ្យ ក្នុងការចុះបញ្ជីក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មមួយ។ បុគ្គលទាំងនោះអាចជាសហកម្មសិទ្ធិករ ឯកកម្មសិទ្ធិករ ស្ថាបនិក អភិបាល ម្ចាស់ភាគហ៊ុន បណ្ណាធិកា ឬ អ្នកតំណាងស្របច្បាប់នៃក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មនោះ។ ចំពោះការស្នើសុំចុះបញ្ជីក្រុមហ៊ុន សហគ្រាសថ្មីមួយឲ្យបានជោគជ័យ អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវឆ្លងកាត់ ០៣ (បី) ដំណាក់កាលគឺៈ ទី១ (មួយ) គឺការបំពេញបែបបទសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម (កថាភាគទី១), ទី២ (ពីរ) ការអនុវត្តការចុះបញ្ជីជាក់ស្តែងនៅលើប្រព័ន្ធ (កថាភាគទី២) និង ទី៣ (បី) គឺ ដំណាក់កាលនៃការទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បីធ្វើការផ្ទៀងផ្ទាត់ និងតម្កល់ទុកឯកសារដើម (កថាភាគទី៣)។

### កថាភាគទី១. ការបំពេញបែបបទសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

#### ១. ប្រមូលឯកសារដែលពាក់ព័ន្ធសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម

១.១. សម្រាប់ការចុះបញ្ជីក្រុមហ៊ុនមូលធន

ក្រុមហ៊ុនមូលធនមានពីរប្រភេទគឺ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត និង ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត។ ក្រុមហ៊ុនមូលធនអាចធ្វើការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបាន លុះត្រាតែមានឯកសារតម្រូវដូចខាងក្រោមៈ

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក កិច្ចសន្យាជួលផ្ទះឬអាគារ លិខិតប្រៃសណីយ៍ ជាដើម
- លក្ខន្តិកៈក្រុមហ៊ុន
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ក្រុមហ៊ុន និងអភិបាល
- រូបថត ៤×៦ របស់ម្ចាស់ហ៊ុន និង អភិបាល
- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការសាធារណៈ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល ៖
    - ច្បាប់ចម្លងឯកសារគតិយុត្តនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើម ដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញាតិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
    - សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុន[25]។

១.២. ឯកសារសម្រាប់ការចុះបញ្ជីសាខា ឬការិយាល័យតំណាង

ឯកសារសម្រាប់ការចុះបញ្ជីសាខា ឬ ការិយាល័យតំណាងក្រុមហ៊ុនពាណិជ្ជកម្មបទេសមានដូចជា៖

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យបត្រទឹកភ្លើង កិច្ចសន្យាជួលផ្ទះ ឬអាគារ ឬលិខិតប្រៃសណីយ៍ ជាដើម
- ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់
- សេចក្តីសម្រេចរបស់ក្រុមហ៊ុនដើមបង្កើតសាខា ឬ ការយាល័យតំណាង និង តែងតាំងនាយកសាខា
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់នាយកការិយាល័យតំណាង ឬសាខា
- រូបថត ៤×៦ របស់នាយកការិយាល័យតំណាង ឬសាខា

[25] ប្រការ៣ នៃប្រកាសលេខ ២៩៩ ព.ណ ចបព.ប្រក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥។

- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់នាយកការិយាល័យតំណាង ឬសាខា ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

១.៣. ឯកសារសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ

ក្រុមហ៊ុនសហកម្មសិទ្ធិមានពីរប្រភេទគឺ ក្រុមហ៊ុនសហកម្មសិទ្ធិទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធិមានកម្រិត ហើយឯកសារតម្រូវសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិតាមប្រព័ន្ធស្វ័យប្រវត្តិកម្មរួមមាន៖

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក កិច្ចសន្យាជួលផ្ទះ ឬអគារ ឬលិខិតប្រៃសណីយ៍ ជាដើម
- កិច្ចសន្យាក្រុមហ៊ុន
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់សហកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រងក្រុមហ៊ុន
- រូបថត ៤×៦ របស់សហកម្មសិទ្ធិករ
- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់សហកម្មសិទ្ធិករ ឬអ្នកគ្រប់គ្រង ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ករណីសហកម្មសិទ្ធិករជានីតិបុគ្គល ៖
    - ច្បាប់ចម្លងឯកសារគតិយុត្តនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ដែលទទួលស្គាល់ដោយច្បាប់
    - សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ[26]។

១.៤. ការចុះបញ្ជីសហគ្រាសឯកបុគ្គល

- ដើម្បីធ្វើការចុះបញ្ជីចំពោះសហគ្រាសឯកបុគ្គលបាន លោកអ្នកត្រូវរៀបចំឯកសារដូចជា៖

- ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជា វិក័យបត្រអគ្គិសនី វិក័យបត្រទឹក កិច្ចសន្យាជួលផ្ទះឬអាគារ លិខិតប្រៃសណីយ៍ ជាដើម

[26] ច្បាប់វិសោធនកម្មស្តីពីច្បាប់វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៨, វិច្ឆិកា ១៩៩៩។

- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ
- រូបថត ៤×៦ របស់ឯកកម្មសិទ្ធិករ
- សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់ឯកកម្មសិទ្ធិករថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

**២. ការបង្កើតគណនីនៅធនាគារ**

បន្ទាប់ពីការប្រមូលឯកសារ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មបានគ្រប់ហើយ អ្នកចុះបញ្ជីត្រូវតម្រូវឲ្យ បើកគណនីនៅធនាគារពាណិជ្ជណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ មុននិងធ្វើការដាក់ស្នើសុំចុះបញ្ជីក្រុមហ៊ុន សហគ្រាសរបស់ខ្លួន។ ការដែលតម្រូវឲ្យបង្កើតគណនីនៅធនាគារនៅមុនពេលស្នើសុំចុះបញ្ជីពាណិជ្ជកម្ម គឺដោយសារតែការទូទាត់កម្រៃសេវា ដែលត្រូវបង់ចូលថវិការដ្ឋ តម្រូវឲ្យធ្វើតាមប្រព័ន្ធអេឡិកត្រូនិចរបស់ធនាគារ ដោយផ្អែកតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៨៣ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ[27]។ ដូច្នេះដើម្បីអាចធ្វើការទូទាត់តាមប្រព័ន្ធអេឡិកត្រូនិចបាន អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវតែមានគណនីនៅធនាគារពាណិជ្ជកម្មណាមួយ ក្នុងព្រះរាជាណាចក្រកម្ពុជា ជាមុនសិន ។ ជាក់ស្តែងមានធនាគារចំនួន៣ (បី) ដែលអាចធ្វើការបើកគណនី និងដែលមានការទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្មគឺ ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា និង ធនាគារពាណិជ្ជកម្មនៃកម្ពុជា ហើយគណនីនេះត្រូវតែមានតម្កល់ប្រាក់សម្រាប់ធ្វើការទូទាត់កម្រៃរដ្ឋបាល។

ទោះបីជាយ៉ាងនេះក្តី ដើម្បីសម្រួលដល់ការចុះបញ្ជី ក្រសួងពាណិជ្ជកម្មបានអនុញ្ញាតឲ្យធ្វើការចុះបញ្ជីពាណិជ្ជកម្មដោយមិនចាំបាច់មានគណនីធនាគារជាមុនបាន ដោយអនុញ្ញាតិអោយអ្នកស្នើសុំទៅធ្វើការទូទាត់ដោយផ្ទាល់នៅជាមួយមន្ត្រីហិរញ្ញវត្ថុធនាគារដោយគោរពទៅតាមលក្ខខណ្ឌនីតិវិធីមួយចំនួន[28]។ ត្រង់នេះមានន័យថា អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មក៏មិនតម្រូវឲ្យបើកគណនីនៅធនាគារ ដើម្បីប្រើប្រាស់ សម្រាប់បង់កម្រៃរដ្ឋបាលក៏បានដែរ ដែលនេះគឺជាជម្រើសទី ២ (ពីរ) នៃការទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ដែលផ្តល់ឲ្យដោយក្រសួងពាណិជ្ជកម្ម។ ក៏ប៉ុន្តែចំពោះការបង្កើតគណនីសម្រាប់បញ្ជាក់ការតម្កល់ដើមទុនវិញ គឺជាដាច់ខាតត្រូវតែមាន។

---

[27] ប្រកាសស្តីពីនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មលេខ ២៩៩ ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥។

[28] មានបកស្រាយនៅចំនុចខាងក្រោមស្តីពីប្រតិបត្តិការជាក់ស្តែងនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក។

## កថាភាគទី២. ការអនុវត្តការចុះបញ្ជីជាក់ស្តែងនៅលើប្រព័ន្ធស្វ័យប្រវត្តិកម្ម

ដើម្បីដំណើរការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម ក្នុងការចុះបញ្ជីពាណិជ្ជកម្មបាន លោកអ្នកតម្រូវឲ្យមានកុំព្យូទ័រ ឬឧបករណ៍ឆ្លាតវៃ ដែលមានតភ្ជាប់ទៅកាន់ប្រព័ន្ធអ៊ិនធឺណែតរួចជាស្រេច។ ប្រព័ន្ធនេះ វាបានផ្តល់នូវនីតិវិធីចុះបញ្ជីក្រុមហ៊ុនថ្មីមួយ ដែលមានលក្ខណៈដូចទៅនឹងនីតិវិធីចាស់ដែរ ដោយវាគ្រាន់តែមានការផ្លាស់ប្តូរបរិបទការងារ ដែលពីមុនប្រើប្រាស់ដោយដៃ មកប្រើប្រាស់ជំនួសវិញដោយឧបករណ៍អេឡិកត្រូនិច និង សេវាកម្មជាស្វ័យប្រវត្តិតែប៉ុណ្ណោះ ដោយចំពោះការបំពេញឯកសារដែលតម្រូវសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មគឺ ត្រូវឆ្លងកាត់ការធ្វើឡើងដោយផ្ទាល់ដៃដ៏ដែល។ ត្រង់នេះមានន័យថាបែបបទចំពោះការចុះបញ្ជីក្រុមហ៊ុន សហគ្រាសថ្មីមួយ វាតម្រូវឲ្យអ្នកស្នើសុំត្រូវធ្វើជាពីរដងក្នុងការបំពេញឯកសារ គឺធ្វើការបំពេញឯកសារដោយផ្ទាល់ដៃនៅលើក្រដាសផង និង ការបំពេញឯកសារជាអេឡិកត្រូនិចផង។ ចំពោះលក្ខណៈពិសេសនៃប្រព័ន្ធនេះគឺវាមិនតម្រូវឲ្យអ្នកស្នើសុំ ទៅកាន់ក្រសួងពាណិជ្ជកម្មដើម្បីធ្វើការស្នើសុំចុះបញ្ជីពាណិជ្ជកម្មនោះទេ ដោយពួកអាចធ្វើការស្នើសុំចុះបញ្ជីបានគ្រប់ពេលវេលាគ្រប់ទីកន្លែងតាមរយៈប្រព័ន្ធនេះបាន ។

ជាក់ស្តែងដើម្បីធ្វើការឈ្មោះក្រុមហ៊ុន សហគ្រាស ថ្មីមួយបានអ្នកស្នើសុំ ត្រូវតែបង្កើតនូវគណនីមួយ នៅលើគេហទំព័រចុះឈ្មោះជាអ្នកប្រើប្រាស់សេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មតាមគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មជាមុនសិន ហើយបន្ទាប់មកទើបលោកអ្នកអាចធ្វើប្រតិបត្តិការលើប្រព័ន្ធដើម្បី ចុះបញ្ជីពាណិជ្ជកម្មបាន។

### ១. ការបង្កើតគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម

ដើម្បីអាចប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្មបាន លោកអ្នកត្រូវតែបង្កើតគណនីដើម្បីប្រើប្រាស់មួយជាមុនសិន។ ជាក់ស្តែងដើម្បីបង្កើតគណនីនេះ លោកអ្នកត្រូវចូលទៅកាន់គេហទំព័រ www.businessregistration.moc.gov.kh ដើម្បីធ្វើការចុះឈ្មោះ ។ នៅលើផ្ទាំងមុខងារនៃគេហទំព័រ លោកអ្នកត្រូវចុចលើពាក្យថា ចុះឈ្មោះ (Register) ។ នៅលើទំព័រចុះឈ្មោះជាអ្នកប្រើប្រាស់ លោកអ្នកត្រូវបំពេញព័ត៌មានដូចជា ឈ្មោះគណនី លេខកូដសម្ងាត់ និងព័ត៌មានដែលត្រូវដាក់បង្ហាញនៅលើគេហទំព័រ ដូចជា ឈ្មោះ អាស័យដ្ឋាន និងថ្ងៃខែឆ្នាំកំណើត ហើយជាចុងក្រោយគឺត្រូវបំពេញព័ត៌មានសម្រាប់ទំនាក់ទំនង ដូចជាអាសយដ្ឋានអ៊ីម៉ែល (Email) លេខទូរស័ព្ទ និងអាសយដ្ឋានស្នាក់នៅ។ សូមចងចាំថានៅរាល់សញ្ញាផ្កាយពណ៌ក្រហម គឺជាសញ្ញាបង្ហាញថាវាជាព័ត៌មានចាំបាច់ដែលត្រូវតែបំពេញ។ បន្ទាប់ពីបំពេញព័ត៌មានបានគ្រប់គ្រាន់ហើយ លោកអ្នកត្រូវចុចលើប៊ូតុង បង្កើត (Great) ។ បន្ទាប់ពីបង្កើតគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្ម បានសម្រេច

ជោគជ័យហើយប្រព័ន្ធនេះ នឹងបង្ហាញនូវផ្ទាំងមុខងារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មដល់លោកអ្នកដោយស្វ័យប្រវត្តិ ។

## ២. ការត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

### ២.១. របៀបបំពេញ និងដាក់ស្នើពាក្យសុំត្រួតពិនិត្យនឹងបម្រុងទុកនាមករណ៍

ដើម្បីធ្វើការត្រួតពិនិត្យនាមករណ៍ក្រុមហ៊ុនរបស់លោកអ្នក នៅលើទំព័រមុខងារ សូមចុចលើកពាក្យថា "បម្រុងទុកឈ្មោះក្រុមហ៊ុន (Reserve a Company Name)"។ នៅលើផ្ទាំងមុខងារនេះវាមានបង្ហាញពី ថ្ងៃខែឆ្នាំ ដែលអ្នកស្នើសុំបម្រុងទុកនាមករណ៍ និងថ្ងៃខែឆ្នាំ ផុតកំណត់សម្រាប់ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនរបស់លោកអ្នក។ យ៉ាងណាមិញដើម្បីបម្រុងទុកនូវនាមករណ៍នេះ លោកអ្នក ត្រូវជ្រើសយកនូវប្រភេទក្រុមហ៊ុនណាមួយដើម្បីចុះឈ្មោះ ដោយរួមទាំងដាក់ឈ្មោះក្រុមហ៊ុននោះជាភាសាខ្មែរ។ បន្ទាប់មកសូមចុចលើពាក្យ Validate name ហើយចំពោះឈ្មោះក្រុមហ៊ុនជាភាសាអង់គ្លេស លោកអ្នកត្រូវប្រាកដថា វាត្រូវបានបញ្ចប់ដោយពាក្យបញ្ជាក់ពីទ្រង់ទ្រាយក្រុមហ៊ុនដែលលោកអ្នកបានជ្រើសរើសខាងលើនោះ[29]។ បន្ទាប់មកលោកអ្នកត្រូវតែបញ្ជូននាមករណ៍នោះទៅកាន់មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បី ត្រួតពិនិត្យ ដោយលើចុចលើប៊ូតុង Submit។ ប្រសិនបើក្រោយពេលដែលមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម បានត្រួតពិនិត្យថាត្រឹមត្រូវហើយ (មានន័យថានាមករណ៍អាចប្រើប្រាស់បាន)ក្រសួងពាណិជ្ជកម្មតម្រូវឲ្យលោកអ្នកបង់កម្រៃសេវារដ្ឋបាលសម្រាប់ការបម្រុងទុកនាមករណ៍នោះ។ ប្រព័ន្ធនេះបានផ្តល់នូវភាពងាយស្រួល ដោយអាចឲ្យលោកអ្នកអាចធ្វើការទូទាត់កម្រៃនេះបាន តាមរយៈធនាគាពាណិជ្ជកម្មណាមួយ ដូចជាធនាគារអេស៊ីលីដា និងធនាគារពាណិជ្ជជាដើម ដោយការទូទាត់នេះធ្វើឡើយតាមរយៈប្រព័ន្ធស្វ័យប្រវត្តិ (Online)។

### ២.២.ការទូទាត់កម្រៃសេវាសម្រាប់ការតម្កល់ទុកនាមករណ៍

ការទូទាត់សេវារដ្ឋបាលតាមរយៈគណនីធនាគារគឺថា លោកអ្នកត្រូវតែធ្វើការជ្រើសរើសធនាគារណាមួយដែលលោកអ្នក ប្រាកដថាបានបង្កើតគណនី និង បានតម្កល់ប្រាក់មួយចំនួនរួចជាស្រេចសម្រាប់ដើម្បីធ្វើការទូទាត់។ តែបច្ចុប្បន្ននេះលោកអ្នកអាចធ្វើការទូទាត់ដោយផ្ទាល់ជាមួយធនាគារដៃគូរណាមួយរបស់ក្រសួងពាណិជ្ជកម្មបាន[30] ។

---

[29] ពាក្យបញ្ជាក់ទ្រង់ទ្រាយក្រុមហ៊ុនរួមមាន General Partnership ,Limited Partnership (Ltd partnership), Sole Proprietorship (EURL),Public Limited Company (PLC) និង Private Limited Company (Co,.Ltd) ។

[30]សូមមើលលម្អិតនៅក្នុងសេចក្តីជូនដំណឹងស្តីពីនីតិវិធីនៃការទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្មលេខ ១៦១៥ ព.ណ ចបព. ប្រក ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៧។

ដើម្បីធ្វើការទូទាត់ នៅលើទំព័រមុខងារ សូមធ្វើការជ្រើសយកធនាគារណាមួយដើម្បីទូទាត់ រួចចុចលើប៊ូតុង Proceed ដើម្បីបន្ត។ វាយបញ្ចូលលេខគណនីរបស់លោកអ្នក រួចធ្វើការបញ្ជាក់លេខគណនីនោះម្តងទៀតហើយចុចប៊ូតុង Next និងចុចប៊ូតុង Request ដើម្បីទទួលបានលេខសម្ងាត់។ បន្ទាប់មកនៅក្នុងប្រអប់ OTP សូមបញ្ចូលនូវលេខកូដសម្ងាត់នោះ ហើយចុចប៊ូតុង Verify រួចចុចប៊ូតុង Ok នោះលោកអ្នកនឹងឃើញសារអេឡិកត្រូនិចមួយ ដែលសារនេះបញ្ជាក់ថាប្រព័ន្ធនៃការទូទាត់របស់លោកអ្នក បានទទួលជោគជ័យហើយ។ ប្រសិនបើការដាក់ស្នើនាមករណ៍ប្រព្រឹត្តទៅបានជោគជ័យហើយ សូមចុចលើប៊ូតុង Back to Merchant ដើម្បីត្រលប់ទៅកាន់ទំព័រចុះបញ្ជីពាណិជ្ជកម្មវិញ នៅពេលនោះវានឹងលោតផ្ទាំងទិដ្ឋភាពមួយ ដែលផ្ទាំងនេះបង្ហាញបញ្ជាក់ពីការទូទាត់របស់លោកអ្នក ហើយនៅលើផ្ទាំងមុខងារនោះ សូមចុចលើពាក្យថា Here នៅពេលនោះបង្កាន់ដៃនឹងត្រូវបានផ្ញើរជូនទៅកាន់គណនី អ៊ីម៉ែល (Email) របស់លោកអ្នក។ បង្កាន់ដៃនេះបញ្ជាក់ពីការទូទាត់ប្រាក់ទៅឲ្យក្រសួងពាណិជ្ជកម្ម និងចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ហើយលោកអ្នកក៏អាចធ្វើការបោះពុម្ពចេញនូវលិខិតបញ្ជាក់នេះ ដើម្បីរក្សាទុកធ្វើជាអំណះអំណាងបានផងដែរ។

ដើម្បីបញ្ជាក់ឲ្យបានពិតប្រាកដថា អ្នកបានស្នើសុំរួចរាល់ឬនៅ សូមចុចលើប៊ូតុង Ok ដើម្បីត្រលប់ទៅកាន់ទំព័រមុខងារចុះបញ្ជីពាណិជ្ជកម្មដើមវិញ នៅពេលនោះនៅលើទំព័រ My Unfinished Business នោះនឹងឃើញថាការស្នើសុំត្រួតពិនិត្យនាមករណ៍របស់លោកអ្នក បានទទួលជោគជ័យហើយ ដោយ Status នៃការបម្រុងទុកនាមករណ៍របស់អ្នក ស្មើរនឹងពាក្យ View ។ នាមករណ៍នេះត្រូវបានរក្សាទុក និងការពារមិនឲ្យអ្នកផ្សេងទៀតប្រើប្រាស់នាមករណ៍ដែលដូច ឬ ស្រដៀងនិងនាមករណ៍នេះបានឡើយក្នុងរយៈពេល ៣០ថ្ងៃ ហើយលោកអ្នកអាចធ្វើការពន្យាការបម្រុងទុកនាមករណ៍នេះបាន ក្នុងរយៈពេល ៣០ ថ្ងៃបន្តទៀតដោយការដាក់ពាក្យសុំ។ បើក្នុងករណីការបំពេញព័ត៌មាននេះ ត្រូវបានធ្វើជំនួយដោយមន្ត្រីនៃក្រសួងពាណិជ្ជកម្ម នោះការទូទាត់កម្រៃសេវា ត្រូវធ្វើការទូទាត់ដោយផ្ទាល់ នៅបញ្ជរនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

### ៣. ការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនថ្មីមួយ

ការចុះបញ្ជីក្រុមហ៊ុនគឺ វាមានលក្ខណៈខុសគ្នា ទៅតាមប្រភេទនៃក្រុមហ៊ុននីមួយៗ ដូច្នេះប្រសិនបើលោកអ្នកចង់ធ្វើការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនប្រភេទណាមួយ ដូចជាការចុះជាសហគ្រាសឯកត្តបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ ក្រុមហ៊ុនបរទេស ឬក៏ក្រុមហ៊ុនមូលធនជាដើម នោះលោកអ្នកត្រូវតែបំពេញនូវព័ត៌មានទៅតាមទម្រង់នៃប្រភេទនៃក្រុមហ៊ុននោះ។ ពាក្យស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានផ្តល់ឲ្យដោយនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដែលមាន ៤ ទម្រង់ គឺ

ទម្រង់សម្រាប់ការចុះបញ្ជី ក្រុមហ៊ុន សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងពាក្យសុំសម្រាប់ការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មបរទេស ។ នៅក្នុងប្រព័ន្ធនេះតម្រូវឲ្យលោកអ្នក ធ្វើការបំពេញព័ត៌មានទាំងអស់ ដែលមាននៅក្នុងពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ទៅតាមប្រភេទនៃក្រុមហ៊ុននីមួយៗ ដោយធ្វើការបំពេញលើគំរូអេឡិកត្រូនិចមួយ ដែលមាននៅក្នុងប្រព័ន្ធស្រាប់ (គំរូប្រតិវេទន៍អេឡិកត្រូនិច) ហើយរួមទាំងត្រូវធ្វើការបញ្ចូលនូវឯកសារយោងដែលពាក់ព័ន្ធនឹងការចុះបញ្ជីរក្រុមហ៊ុននេះ ។ នៅក្នុងករណីនេះ ខ្ញុំនឹងលើយកការចុះបញ្ជីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតថ្មីមួយ មកធ្វើការបង្ហាញ។ ដើម្បីធ្វើការចុះបញ្ជីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត នៅលើផ្ទាំងមុខងារសូមជ្រើសយកពាក្យថា "បញ្ចូលក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត (Incorporate a private limited company)"។ ដើម្បីចុះបញ្ជីក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិតថ្មីមួយនៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម លោកអ្នកត្រូវបំពេញព័ត៌មានចំនួន ៩ ដំណាក់កាលដូចខាងក្រោម៖

៣.១.ការបញ្ចូលព័ត៌មានទូទៅ

ប្រសិនបើក្រុមហ៊ុននេះ ទាន់បានត្រួតពិនិត្យ និងបម្រុងទុកនាមករណ៍ជាមុនទេ នោះលោកអ្នកត្រូវតែបំពេញព័ត៌មាន នៅក្នុងប្រអប់ដែលបានបង្ហាញស្រាប់នៅលើប្រព័ន្ធ ដើម្បីធ្វើការស្នើសុំពិនិត្យនាមករណ៍របស់លោកអ្នកមុនសិន។ តែផ្ទុយទៅវិញបើលោកអ្នកបានធ្វើការតម្កល់ទុកនាមករណ៍រួចរាល់ហើយ នោះលោកអ្នកអាចចុចយកនាមករណ៍នោះមកប្រើប្រាស់ផ្ទាល់តែម្តងបាន។ បន្ទាប់ពីបានបញ្ចូលនាមករណ៍រួចហើយនោះ បន្ទាប់មកត្រូវបញ្ចូលអនុ សារណៈ ឬលក្ខន្តិកៈក្រុមហ៊ុន ដោយចុះលើប៊ូតុង Upload ហើយធ្វើការជ្រើសរើសកម្មវត្ថុអាជីវកម្ម និងសកម្មភាពអាជីវកម្មចម្បងដូចមានកំណត់ក្នុងលក្ខន្តិកៈក្រុមហ៊ុននោះ។ បន្តរមកទៀត ត្រូវបញ្ចូលនូវតម្លៃចារឹកលើប័ណ្ណ ឬ តម្លៃនៃមួយភាគហ៊ុនដែលបានកំណត់នៅក្នុង លក្ខន្តិកៈក្រុមហ៊ុន ហើយប្រសិនបើមានព័ត៌មានអំពីបុគ្គលិកនៅក្នុងក្រុមហ៊ុននោះ ត្រូវបញ្ចូលចំនួនបុគ្គលិក និងឯកសារបញ្ជាក់តួនាទីរបស់ពួកគេ ។ ចុចប៊ូតុង Next step ដើម្បីបន្តទៅកាន់ដំណាក់កាលទី ២ គឺការបំពេញព័ត៌មានអាសយដ្ឋានក្រុមហ៊ុន។

៣.២. ការបំពេញព័ត៌មានអាសយដ្ឋានរបស់ក្រុមហ៊ុន

ក្នុងដំណាក់កាលនេះលោកអ្នកត្រូវបញ្ចូលព័ត៌មាន អាសយដ្ឋានក្រុមហ៊ុន ដោយធ្វើការ Upload នូវព័ត៌មានបញ្ជាក់អាសយដ្ឋានទាំងនោះដែលអាចជា វិក័យបត្រទឹក ភ្លើង ឬក៏កិច្ចសន្យា

ជួលផ្ទះជាដើម រួចបញ្ចូលមន្ថែមនូវ អាសយដ្ឋាន Email ឬលេខទូរស័ព្ទ បន្ទាប់មកចុចប៊ូតុង Next ដើម្បី បន្តទៅកាន់ដំណាក់កាលទី៣ គឺការបញ្ចូលព័ត៌មានអភិបាល។

៣.៣.ការបញ្ចូលព័ត៌មានអភិលក្រុមហ៊ុន

ក្នុងដំណាក់កាលនៃការបំពេញព័ត៌មានអភិបាលក្រុមហ៊ុន លោកអ្នកអាចធ្វើការបំពេញទៅតាមការកំណត់នៅលើប្រព័ន្ធដែលមានស្រាប់ ឬ បើសិនជាម្ចាស់គណនីជាអភិបាលក្រុមហ៊ុន ត្រូវចុចលើពាក្យថាបន្ថែមខ្ញុំជាអភិបាល (Add me as director) រួចចុចលើពាក្យដែលអះអាងថាខ្លួនមិនមានជាប់ទោសពៃរ៍ ឬ ជាមន្ត្រីសាធារណៈដែលធ្វើការនៅក្នុងស្ថាប័នរដ្ឋណាមួយ ហើយដើម្បីបញ្ជាក់ថា ព័ត៌មានដែលបានផ្តល់ពិតជាត្រឹមត្រូវប្រាកដមែន ។ ប្រសិនបើអភិបាលនៅក្នុងកក្រុមហ៊ុនរបស់លោកអ្នកមានច្រើនជាងមួយរូប លោកអ្នកត្រូវបន្ថែមព័ត៌មានអំពីអភិបាលទាំងនោះដោយចុចលើប៊ូតុង បន្ថែមអភិបាលផ្សេងទៀត (Add another director) និងធ្វើការបញ្ចូលនូវ ឯកសារយោង រួចចុចប៊ូតុង បន្ត (Continue) ដើម្បីទៅកាន់ដំណាក់កាលនៃការបស់ញ្ចូលព័ត៌មានម្ចាស់ភាគហ៊ុន និងការកាន់កាប់ភាគហ៊ុន។

៣.៤.ការបញ្ចូលព័ត៌មានម្ចាស់ហ៊ុន និងការកាន់កាប់ភាគហ៊ុន

ប្រសិនបើក្រុមហ៊ុនរបស់លោកអ្នក មានប្រភេទភាគហ៊ុនច្រើនជាងមួយ សូមចុចលើពាក្យថា Yes រួចបញ្ចូលព័ត៌មានអំពីប្រភេទភាគហ៊ុនទាំងនោះ ។ សូមធ្វើការជ្រើសរើសប្រភេទម្ចាស់ភាគហ៊ុន ដែលអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ហើយធ្វើការបំពេញព័ត៌មានអំពីម្ចាស់ភាគហ៊ុនទាំងនោះ។ ចុចទៅលើពាក្យ "Select form list of director" ប្រសិនបើម្ចាស់ភាគហ៊ុនដូចគ្នាទៅនឹងក្រុមប្រឹក្សាភិបាល ឬ ក៏ចុចលើប៊ូតុង "Add me as shareholder" ប្រសិនបើម្ចាស់គណនីជាម្ចាស់ភាគហ៊ុន។ បញ្ចូលព័ត៌មាន និងឯកសារបញ្ជាក់អត្តសញ្ញាណ និងចំនួនភាគហ៊ុនដែលម្ចាស់ភាគហ៊ុនរូបនេះកាន់កាប់ ។ ចុចប៊ូតុង "Add another shareholder" ប្រសិនបើមានសមាសភាពម្ចាស់ហ៊ុនផ្សេងទៀត។ ចុចប៊ូតុង "Next step" ដើម្បីទៅកាន់ដំណាក់កាលចុងក្រោយ គឺ ការត្រួតពិនិត្យព័ត៌មានដែលលោកអ្នកបានបញ្ចូលក្នុងដំណាក់កាលទាំងបួន។ លោកអ្នកអាចធ្វើការកែប្រែព័ត៌មានទាំងនោះបានដោយចុចនៅលើប៊ូតុង Edit ដែលនៅខាងស្តាំដៃ។ បើក្នុងករណីដែលយល់ឃើញថានៅមានចំណុចណាមួយដែលត្រូវពិចារណា លោកអ្នកអាចចុចលើប៊ូតុង "Save and Exit" ហើយពេលនោះប្រព័ន្ធ និងធ្វើការរក្សាទុកនូវទិន្នន័យដែលលោកអ្នកបានបញ្ចូលរយៈពេល ១៥ ថ្ងៃ ។ ចុចប៊ូតុង "Submit" ដើម្បីទៅដល់ដំណាក់កាលទូទាត់ប្រាក់កម្រៃសុំចុះបញ្ជីពាណិជ្ជកម្ម។

### ៤. ការទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម

ដូចការទូទាត់ប្រាក់សម្រាប់ការបង់កម្រៃសេវារដ្ឋបាល សម្រាប់ការតម្កល់ទុកនាមករណ៍ លោកអ្នក អាចធ្វើការទូទាត់បានតាមរយៈប្រព័ន្ធទូទាត់ប្រាក់ស្វ័យប្រវត្តិ (Online) របស់ធនាគារអេស៊ីលីដា (ACLEDA BANK) ។ នីតិវិធីទូទាត់ Online ជាបឋមគឺ លោកអ្នកត្រូវមានគណនីធនាគារអេស៊ីលីដាជាមុន ដើម្បីធ្វើការទូទាត់ ដោយមិនចាំបាច់មកកាន់នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នៅក្រសួងពាណិជ្ជកម្មដើម្បីធ្វើការផ្ទៀងផ្ទាត់នោះទេ ។ ប៉ុន្តែលោកអ្នកក៏អាចធ្វើការទូទាត់ដោយផ្ទាល់ដៃតាមរយៈធនាគារបានផងដែរ ដោយលោកអ្នកត្រូវគោរពតាមលក្ខខណ្ឌមួយចំនួន។

**ការទូទាត់ដោយផ្ទាល់មាត់តាមរយៈដៃគូរធនាគារ (Offline)**

លោកអ្នកអាចធ្វើការទូទាត់ប្រាក់បានតាមលេខគណនីរបស់ក្រសួងពាណិជ្ជកម្មនៅធនាគារណាមួយដូចខាងក្រោម៖

- ធនាគារពាណិជ្ជកម្មនៃកម្ពុជា (FTB)
  .KHR: 001-01-290-000094-0 . USD: 010-30-63-000937-8
- ធនាគារកាណាឌីយ៉ា (CANADIA BANK)
  .KHR: 001-000-333-88-22 .USD: 001-000-333-55-88
- ធនាគារអេស៊ីលីដា (ACLEDA BANK)
  .KHR: 001--02-076702-22 .USD: 001-02-076702-18

**នីតិវិធីទូទាត់ ដោយផ្ទាល់ដៃ (Offline)**

ជំហានទី១៖ បំពេញបែបបទក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មរហូតដល់ទំព័របង់កម្រៃសេវា។

ជំហានទី២៖ Print Screen ទំព័របង់កម្រៃសេវាដើម្បីធ្វើជាឯកសារយោងទៅធនាគារណាមួយខាងលើ។

ជំហានទី៣៖ លោកអ្នកត្រូវយកវិក័យបត្រទូទាត់ប្រាក់ (Bank Receipt) ពីធនាគារមកកាន់ការិយាល័យនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ ដែលមានទីតាំងនៅក្រសួងពាណិជ្ជកម្មជាន់ផ្ទាល់ដីដើម្បីផ្ទៀងផ្ទាត់។

ជំហានទី៣៖ បន្ទាប់ពីការធ្វើការផ្ទៀងផ្ទាត់រួចរាល់ លោកអ្នកត្រូវ ចូលទៅក្នុងទំព័រក្រុមហ៊ុន (Company Profile) ម្តងទៀតដើម្បីដាក់ស្នើតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online)[31]។

[31] សូមមើលនៅក្នុងសេចក្តីជូនដំណឹងលេខ១៦១៥ ព.ណ ចបពចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៧ ស្តីពីនីតិវិធីទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ម្យ៉ាងទៀត បើក្នុងករណីដែលការបំពេញព័ត៌មាន ត្រូវបានធ្វើជំនួយដោយមន្ត្រីនៃក្រសួងពាណិជ្ជកម្ម នោះការទូទាត់កម្រៃសេវា ត្រូវធ្វើឡើងដោយផ្ទាល់នៅបញ្ជរនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។

### ៥. ការបោះពុម្ពចេញនូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម

ដោយសារតែការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម មិនតម្រូវឲ្យអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ទៅកាន់ក្រសួងដោយផ្ទាល់ ហេតុដូចនេះចំពោះវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក៏ត្រូវបានចេញឲ្យដោយផ្ទាល់តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មដល់អតិថិជន និងអនុញ្ញាតឲ្យក្រុមហ៊ុន សហគ្រាស អាចធ្វើការស្នើសុំការបោះពុម្ពចេញនូវវិញ្ញាបនបត្រនេះបានដោយខ្លួនឯងបានផងដែរ។ ការបោះពុម្ពចេញនូវវិញ្ញាបនបត្រនេះ លោកអ្នកអាចប្រើប្រាស់នូវម៉ាស៊ីនបោះពុម្ពពណ៌ (Colure Printer) របស់លោកអ្នកបាន ឬស្នើសុំទៅកាន់មន្ទីពាណិជ្ជកម្មគ្រប់រាជធានី/ខេត្ត ឬ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីធ្វើការបញ្ជាក់។ វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មថ្មីនេះមានសុពលភាពមិនកំណត់ និងមានដាក់ QR កូដ សម្រាប់ផ្ទុកទិន្នន័យព័ត៌មានរបស់ក្រុមហ៊ុនផងដែរ។

## កថាភាគទី៣. ការយកឯកសារទៅកាន់ក្រសួងពាណិជ្ជកម្មដើម្បីត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងតម្កល់ទុក

ក្រោយពីបានបញ្ចប់ការប្រតិបត្តិការជាក់ស្តែងនៅលើប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) រួចរាល់ហើយ ឬក្រោយពីទទួលបានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ពីប្រព័ន្ធស្វ័យប្រវត្តិកម្មរួចហើយ ក្នុងកំឡុងពេល ៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃទទួលបានវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវមកកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងតម្កល់ទុកឯកសារ[32] លើកលែងការចុះបញ្ជីចំពោះសហគ្រាសឯកបុគ្គល[33]។ ឯកសារដែលតម្រូវឲ្យយកមកផ្ទៀងផ្ទាត់ និងតម្កល់ទុករួមមានដូចខាងក្រោម៖

---

[32] លោកអ្នកត្រូវយកឯកសារច្បាប់ដើមទាំងអស់ដែលមាន សម្រាប់ការចុះបញ្ជីរបស់យើង ទៅកាន់នាយយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដោយក្នុងនោះចំពោះលក្ខន្តិកៈក្រុមហ៊ុន កិច្ចសន្យាបង្កើតក្រុមហ៊ុន និងសេចក្តីសម្រេចរបស់ក្រុមហ៊ុនមេ ត្រូវតែធ្វើឡើងជា ៤ ច្បាប់ ដែល២ច្បាប់ ត្រូវដម្កល់ទុកនៅនាយកដ្ឋានចុះបញ្ជីពាណានិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម និង២ច្បាប់ទៀតសម្រាប់ក្រុមហ៊ុន។

[33] យោងតាមប្រកាសលេខ២៥៩ ពណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ដោយហេតុថានៅក្នុងប្រកាសនេះ មិនបានតម្រូវឲ្យសហគ្រាសឯកបុគ្គលយកឯកសារមកតម្កល់ទុកឡើង។

**១. ចំពោះក្រុមហ៊ុនមូលធន**

ក្នុងកំឡុងពេល៣០ (សាមសិប) អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនមូលធន ត្រូវមកកាន់ក្រសួងពាណិជ្ជកម្ម ក្នុងម៉ោងធ្វើការដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងតម្កល់ទុកឯកសារ ។ ឯកសារសម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ គឺជាឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ហើយដែលបានបញ្ជូនមកកាន់ក្រសួងពាណិជ្ជកម្ម តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។ រីឯចំពោះឯកសារដែលតម្រូវឲ្យធ្វើការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មរួមមាន៖

- លក្ខន្តិកៈច្បាប់ដើមចំនួន ០២(ពីរ) ច្បាប់
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល៖
    - សេចក្តីសម្រេចសម្រាប់បង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលក្រុមហ៊ុន ច្បាប់ដើមចំនួន ១(មួយ) ច្បាប់ ។
- លិខិតច្បាប់ដើមបញ្ជាក់អំពីគណនីរបស់ក្រុមហ៊ុនដែលបានបើកនៅធនាគារណាមួយ ចំនួន ០១(មួយ) ច្បាប់ ។

**២. ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ**

ចំពោះក្រុមហ៊ុនសហកម្មសិទ្ធិ ក្រោយពីបានធ្វើការដាក់ស្នើសុំចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបានជោគជ័យហើយ ក្នុងកំឡុងពេល៣០ (សាមសិប) អ្នកស្នើសុំចុះបញ្ជី ត្រូវមកកាន់ក្រសួងពាណិជ្ជកម្មក្នុងម៉ោងធ្វើការ ដើម្បីធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងតម្កល់ទុកឯកសារ។ ឯកសារសម្រាប់ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ គឺជាឯកសារទាំងអស់ដែលពាក់ព័ន្ធនិងការចុះបញ្ជីពាណិជ្ជកម្ម ហើយដែលបានបញ្ជូនមកកាន់ក្រសួងពាណិជ្ជកម្ម តាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម។ ចំពោះឯកសារដែលតម្រូវឲ្យធ្វើការតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មរួមមាន៖

- កិច្ចសន្យាក្រុមហ៊ុន ច្បាប់ដើមចំនួន ០២ ច្បាប់
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល៖
    - សេចក្តីសម្រេចសម្រាប់បង្កើតក្រុមហ៊ុន និងតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករច្បាប់ដើមចំនួន ០១ ច្បាប់។

**៣. ចំពោះក្រុមហ៊ុនពាណិជ្ជកម្មបរទេស**

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសដែលរួមមានសាខា ការិយាល័យតំណាង ហ៊ុនបរទេស ក្នុងកំឡុងពេល៣០ (សាមសិប) អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវមកកាន់ក្រសួងពាណិជ្ជកម្មក្នុងម៉ោងធ្វើការ ដើម្បីធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងតម្កល់ទុកឯកសារ។ ឯកសារសម្រាប់ការត្រួតពិនិត្យនិង

ផ្ទៀងផ្ទាត់គឺជាឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្ម ហើយដែលបានបញ្ជូនមកកាន់ក្រសួងពាណិជ្ជកម្មតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម។

សាខា ការិយាល័យតំណាង និងបុគ្គលសម្ព័ន្ធក្រុមហ៊ុនបរទេសត្រូវប្រគល់ទៅឲ្យនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចជា លិខិតតែងតាំងអ្នកតំណាង ឬនាយកគ្រប់គ្រងសារខាក្រុមហ៊ុន ឬ សេចក្ដីសម្រេចបង្កើតសាខាក្រុមហ៊ុន ច្បាប់ដើមដើម្បីធ្វើការតម្កល់ទុក[34] ។

### ផ្នែកទី៣. ភារកិច្ចរបស់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម

មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មមានតួនាទី៣ សំខាន់ៗ ក្នុងការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនថ្មីមួយដូចជា៖ រៀបចំប្រព័ន្ធសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម (កថាភាគទី១) ជួយបំពេញព័ត៌មាន និងត្រួតពិនិត្យឯកសារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម (កថាភាគទី២) និងការធ្វើការផ្ទៀងផ្ទាត់នឹងតម្កល់ទុកឯកសារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម(កថាភាគទី៣)។

#### កថាភាគទី ១. រៀបចំប្រព័ន្ធសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មកន្លងមកបានផ្ដួចផ្ដើម គម្រោងផែនការមេបច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មានវិទ្យា (ICT master plan) ឡើង សំដៅកសាងហេដ្ឋរចនាសម្ព័ន្ធ បច្ចេកវិទ្យាដ៏ទំនើបមួយ ដែលមាននិរន្តរភាព ក្នុងការបំពេញភារកិច្ចប្រចាំថ្ងៃរបស់ខ្លួន ជាពិសេសគឺដើម្បីសម្រួលដល់ការ ផ្ដល់សេវាសាធារណៈរបស់ខ្លួនឲ្យកាន់តែមានភាពងាយស្រួល។

គម្រោង ICT master plan នេះបានទទួលហិរញ្ញប្បទានពីម្ចាស់ជំនួយពហុភាគី តាម រយៈគម្រោងគាំទ្រកិច្ចអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP) ដែលត្រូវបានអនុវត្តតាំងពីឆ្នាំ ២០១១ រហូតដល់បច្ចុប្បន្ន។ ចំពោះការរៀបចំប្លង់មេ ICT master plan ជាដំបូងក្រសួងពាណិជ្ជកម្មត្រូវរៀបចំតម្លើងនូវគ្រឿងម៉ាស៊ីនរបស់វាជាមុនសិន (Install Hardware) ដែលជាមូលដ្ឋាននៃការទ្រទ្រង់នូវគម្រោងកម្មវិធីប្រព័ន្ធ (Software) ដែលនឹងត្រូវធ្វើនៅពេលក្រោយទៀត និងដើម្បីឲ្យប្រព័ន្ធស្វ័យប្រវត្តិកម្មអាចដំណើរការទៅបានយ៉ាងរលូន។ ត្រង់នេះមានន័យថា ICT master plan មានធាតុផ្សំដ៏សំខាន់ពីរគឺទី១ (មួយ) គ្រឿងម៉ាស៊ីន (Hardware) និង ទី២ (ពីរ) កម្មវិធីផ្ទែកទន់ (Software)។ លក្ខណៈពិសេសមួយរបស់ប្រព័ន្ធនេះគឺ វាមានភាពរីចម្រើនជាស្វ័យ ប្រវត្តិ ដោយខ្លួនឯងនៅពេលដែលយើងធ្វើការដាក់បញ្ចូលបន្ថែមនូវប្រព័ន្ធកម្មវិធីអ្វីមួយ នៅក្នុងវា ដែលយើងមិនចាំបាច់ធ្វើការផ្លាស់ប្ដូរ ឬ បន្ថែមនូវគ្រឿងម៉ាស៊ីន ឬ ក៏កម្មវិធីទ្រទ្រង់អ្វីទៀតនោះឡើយ។

[34] បើក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលឯកសារទាំងនេះ ក្នុងថេរៈវេលា ៣០ (សាមសិប) ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់ការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្មនេះបាន ។

គម្រោងនេះបានប្រមូលផ្តុំទៅដោយធាតុផ្សំសំខាន់ៗចំនួន ៤ (បួន) គឺ: ទី១ (មួយ) គម្រោងពាក់ព័ន្ធ និងការបញ្ចូលសេវាពាណិជ្ជកម្មនៅក្នុងប្រព័ន្ធ ICT ទី២ (ពីរ) ការរៀបចំប្រព័ន្ធរដ្ឋបាលទៅតាមប្រព័ន្ធអេឡិកត្រូនិច ទី៣ (បី) ការស្តុក និងរក្សាទុកនូវព័ត៌មានទាក់ទងនឹងពាណិជ្ជកម្មទាំងអស់នៅក្នុង ICT master plan និងទី៤ (បួន) គឺការរៀបកែលម្អប្រព័ន្ធគេហទំព័ររបស់ក្រសួង និងប្រព័ន្ធអ៊ិនធឺណែតនៅក្នុងនាយកដ្ឋាន ក៏ដូចជានៅក្នុងក្រសួងពាណិជ្ជកម្មទាំងមូល។

ចំពោះការរៀបចំប្រព័ន្ធឯកសារ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មវិញ ទៀតសោត ត្រូវបានធ្វើឡើង និងត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធជាទម្រង់ស្វ័យប្រវត្តិជាឯកសារទម្រង់អេឡិកត្រូនិច និងជាប្រភេទឯកសារទូទៅ ដែលត្រូវបានបំលែងពីឯកសារជាក្រដាសស្នាមដើម ដូចជា វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង បង្កាន់ដៃបង់កម្រៃសេវារដ្ឋបាលជាដើម ។ ចំណែកឯកសារជាទម្រង់ស្វ័យប្រវត្តិវិញ សំដៅដល់ទម្រង់ឯកសារ ទាំងឡាយណា ដែលត្រូវបានរៀបចំជាស្វ័យប្រវត្តិ និង ដែលមានដាក់នៅក្នុងប្រព័ន្ធស្រាប់ សម្រាប់បំពេញព័ត៌មានរបស់ក្រុមហ៊ុន សហគ្រាសដែលធ្វើឡើងជាទម្រង់អេឡិកត្រូនិច។

ជាទូទៅគំរូប្រតិវេទន៍ដែលក្រសួងបានផ្តល់ទៅឲ្យអតិថិជន ដើម្បីបំពេញព័ត៌មាន និងដាក់ស្នើមកកាន់ក្រសួងពាណិជ្ជកម្មដើម្បីធ្វើការត្រួតពិនិត្យ និងសម្រេច បច្ចុប្បន្នត្រូវបានរៀបចំឡើងជាទម្រង់ស្វ័យប្រវត្តនេះ។

យ៉ាងណាមិញ ចំពោះការផ្តល់សេវាកម្មចុះបញ្ជីក្រុមហ៊ុនថ្មីមួយ ក៏ដូចច្នោះដែរ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ជាបឋមត្រូវតែរៀបចំឯកសារសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មទាំងអស់ ហើយត្រូវធ្វើការបញ្ចូននូវឯកសារទាំងនោះទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។ ជាក់ស្តែងមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម បានធ្វើការផ្តល់ឲ្យនូវឯកសារ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មទាំងនោះ ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួង ជាពិសេសនៅក្នុងគេហទំព័ររបស់ក្រសួងពាណិជ្ជកម្មផ្ទាល់ ដើម្បីផ្តល់នូវភាពងាយស្រួលដល់អតិថិជន ក្នុងការទាញយកមកប្រើប្រាស់ និងបំពេញ សម្រាប់ធ្វើការស្នើសុំចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មបាន។

**កថាភាគទី២. ការជួយបំពេញព័ត៌មាន និងត្រួតពិនិត្យឯកសារ**

ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម មិនបានធ្វើការកែទម្រង់នូវនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មនោះទេ ពោលគឺដោយវាគ្រាន់តែផ្លាស់ប្តូរនូវការងារ នីតិវិធីនៃការចុះបញ្ជីដោយដៃ មកធ្វើការចុះបញ្ជីតាមរយៈប្រព័ន្ធអេឡិកត្រូនិចតែប៉ុណ្ណោះ។ ការចុះបញ្ជីពាណិជ្ជកម្មគឺត្រូវបាន

ធ្វើឡើងនៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដែលនាយកដ្ឋាននេះ មានការិយាល័យចំនួន៥(ប្រាំ)[35]ដែលមានមន្ត្រីទទួលបន្ទុកផ្សេងៗគ្នាទៅតាមមុខងាររបស់ខ្លួន។

ដោយការសិក្សារបស់ខ្ញុំផ្តោតសំខាន់តែទៅលើការចុះបញ្ជីចំពោះក្រុមហ៊ុនថ្មីមួយដូចនេះ នៅក្នុងចំនុចនេះ ខ្ញុំនឹងធ្វើការបង្ហាញតែភារកិច្ចរបស់មន្ត្រីដែលទទួលបន្ទុកចុះបញ្ជី ចំពោះក្រុមហ៊ុនថ្មីមួយតែប៉ុណ្ណោះ។

**១.ភារកិច្ចមន្ត្រីទទួលបន្ទុកបញ្ជរ**

មន្ត្រីទទួលបន្ទុកបញ្ជរគឺជា មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដែលមានភារកិច្ចដូចជា៖

- ត្រួតពិនិត្យ និង ផ្តល់យោបល់ការងារចុះបញ្ជីពាណិជ្ជកម្ម
- ទទួលពាក្យស្នើសុំគ្រប់ប្រភេទ
- ពិនិត្យពាក្យស្នើសុំ និង ខ្លឹមសារចាំបាច់មួយចំនួន (ប៉ុន្តែមិនលម្អិត និងស៊ីជម្រៅទេ)
- ពិនិត្យផ្ទៀងផ្ទាត់ឯកសារចុះបញ្ជីតាមតាងរាងឯកសារតម្រូវ (Check list)
- ពិនិត្យការចុះហត្ថលេខាគ្រប់គ្រាន់ឬទេ
- ចេញលិខិតទទួលពាក្យសុំ និងកំណត់ថ្ងៃទទួលឯកសារវិញ
- ចេញបញ្ជាការបង់កម្រៃសេវាតាមមុខសញ្ញាស្នើសុំទៅអ្នកស្នើសុំ
- ធ្វើបញ្ជីឈ្មោះក្រុមហ៊ុន សហគ្រាសដែលបានស្នើសុំ និងបញ្ជូនឯកសារតាមមុខសញ្ញាទៅបញ្ជរក្រោយ។

**២. ភារកិច្ចមន្ត្រីចុះលេខកាលប្បវត្តិ និងចម្លងចូលសំណុំពាក្យសុំ**

មន្ត្រីទទួលចុះលេខកាលប្បវត្តិ និងចម្លងចូលសំណុំពាក្យសុំគឺជាមន្ត្រីនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដែលមានភារកិច្ចដូចជា[36]៖

- ពិនិត្យឯកសារត្រង់ចំនុចទ្រង់ទ្រាយក្រុមហ៊ុន
- ពិនិត្យឯកសារត្រង់ចំនុចម្ចាស់ភាគហ៊ុន
- ចុះលេខកាលប្បវត្តិលើបញ្ជីកាលប្បវត្តិ និងចម្លងចូលសំណុំពាក្យសុំ (លេខ......ថ្ងៃខែឆ្នាំម៉ោង............តម្កល់)
- ផ្តល់អត្តលេខសម្គាល់ (ID Number) ជូនក្រុមហ៊ុន/សហគ្រាស

[35] ប្រកាសលេខ ១៩១ ព.ណ ចបព ប្រក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម។

[36] ចំណាំ៖ រាល់ការត្រួតពិនិត្យនិងអនុញ្ញាតទាំងអស់គឺត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិក។

- បញ្ជូនទិន្នន័យពាក់ព័ន្ធនឹងបញ្ជីកាលប្បវត្តិក្នុងប្រព័ន្ធកុំព្យូទ័រ។

**៣. ភារកិច្ចមន្ត្រីប្រថាប់ត្រា និងបែងចែកឯកសារ**

មន្ត្រីប្រថាប់ត្រា និងបែងចែកឯកសារគឺជា មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដែលមានភារកិច្ចដូចជាៈ

- ពិនិត្យលើឯកសារ ផ្ទៀងផ្ទាត់ការបំពេញទម្រង់ពាក្យសុំ ឯកសារសារ និង លក្ខន្តិកៈ
- បំពេញលេខថ្ងៃខែឆ្នាំ ម៉ោង លើគំរូ ទម្រង់ និងលក្ខន្តិកៈ
- ផ្ទៀងផ្ទាត់ខ្លឹមសារទាំងឡាយដែលច្បាប់តម្រូវ ជួយពិនិត្យអក្ខរាវារុទ្ធ បន្ថែមលើវិញ្ញាបនប័ត្រ និងគោលការណ៍។

**៤. ភារកិច្ចមន្ត្រីទទួលបន្ទុករៀបចំឯកសារ**

មន្ត្រីទទួលបន្ទុករៀបចំឯកសារគឺជា មន្ត្រីនៃការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដែលមានភារកិច្ចដូចជាៈ

- ពិនិត្យលើឯកសារ ផ្ទៀងផ្ទាត់ការបំពេញទម្រង់ ជាមួយលក្ខន្តិកៈ និងឯកសារយោង
- បំពេញលេខថ្ងៃខែឆ្នាំ ម៉ោង លើគំរូ ទម្រង់ និងលក្ខន្តិកៈ
- ផ្ទៀងផ្ទាត់ខ្លឹមសារទាំងឡាយដែលច្បាប់តម្រូវ ជួយពិនិត្យអក្ខរាវារុទ្ធ បន្ថែមលើវិញ្ញាបនបត្រ និងគោលការណ៍។

**៥. ភារកិច្ចមន្ត្រីបោះពុម្ពគោលការណ៍ និងវិញ្ញាបនបត្រ**

មន្ត្រីបោះពុម្ពគោលការណ៍ គឺជាមន្ត្រីនៃការិយាល័យចុះបញ្ជីពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដែលមានភារកិច្ចដូចជាៈ

- ប្រមូលទិន្នន័យរបស់ក្រុមហ៊ុន សហគ្រាសទាំងអស់ព្រមទាំងឯកសារយោងដែលមានដូចជា លក្ខន្តិកៈ អាសយដ្ឋាន ទម្រង់ លេខកាលប្បវត្តិ លេខទូរស័ព្ទ អត្តសញ្ញាណ និងផ្សេងៗ នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បោះពុម្ពគោលការណ៍ ពិនិត្យ និងផ្ទៀងផ្ទាត់ឡើងវិញជាមួយនឹងការបញ្ជូននូវគោលការណ៍

**៦. ភារកិច្ចមន្ត្រីបញ្ជូនឯកសារ**

មន្ត្រីទទួលបន្ទុកបញ្ជូនឯកសារ គឺជា មន្ត្រីនៃការិយាល័យព័ត៌មាននៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មដែលមានភារកិច្ចដូចជាៈ

- កត់ត្រាឈ្មោះឯកសារដែលបានបញ្ជូន
- ពិនិត្យចំនួនឯកសារដែលបានបញ្ជូន

- ប្រគល់ និងទទួលឯកសារពីប្រធានការិយាល័យ ប្រធាននាយកដ្ឋាន អគ្គនាយដ្ឋាន និងថ្នាក់ដឹកនាំចុះហត្ថលេខា
- រៀបចំថតចម្លងឯកសារគោលការណ៍ដើម្បីចម្លងជូនអតិថិជន និងថ្នាក់ដឹកនាំ
- បញ្ជូនឯកសារទៅបោះត្រាក្រសួងពាណិជ្ជកម្ម
- បញ្ជូនឯកសារទៅកាន់នាយកដ្ឋានរដ្ឋបាល ដើម្បីចុះលេខចេញ និងដកផ្ញើរតាមក្រសួង
- បញ្ជូនឯកសារជូនការិយាល័យតម្កល់ឯកសារ ដើម្បីចេញជូនសាមីអ្នកស្នើសុំ និងរក្សាទុកក្នុងឃ្លាំងឯកសារ(Data Center)។

### ៧.ភារកិច្ចមន្ត្រីទទួលបន្ទុកតម្កល់ឯកសារ

មន្ត្រីទទួលបន្ទុកតម្កល់ឯកសារ គឺជាមន្ត្រីការិយាល័យតម្កល់ឯកសារនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មក្រសួងពាណិជ្ជកម្ម ដែលមានភារកិច្ចដូជា៖

- រក្សាទុកឯកសារ
- រៀបចំឯកសារតាមលំដាប់នៃអត្តលេខ (តាមបណ្តាឆ្នាំ)
- ស្រាវជ្រាវឯកសារជូនថ្នាក់ដឹកនាំ និងសំណូមពរដល់អ្នកស្នើសុំ
- ចូលរួមផ្តល់មតិយោបល់លើឯកសារ ថតចម្លង និងបញ្ជាក់ឯកសារ ។

## កថាភាគទី៣. ការផ្ទៀងផ្ទាត់ និង ដម្កល់ទុកឯកសារ

### ១. ការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារដើម

បន្ទាប់ពីបានធ្វើការទទួល និងសម្រេចចុះបញ្ជីចំពោះក្រុមហ៊ុន តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរួចរាល់ហើយ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវតម្រូវឲ្យ អ្នកស្នើសុំចុះបញ្ជីក្រុមហ៊ុនទាំងអស់ មកកាន់ក្រសួងពាណិជ្ជកម្ម ដើម្បីធ្វើការត្រួត ពិនិត្យ ពីភាពត្រឹមត្រូវនៃឯកសារជាអេឡិកត្រូនិច ដែលពួកគេបានធ្វើការបញ្ជូនទៅក្នុងប្រព័ន្ធ និងបានផ្ញើរមកកាន់ក្រសួងតាម រយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម ។ ការនេះគឺធ្វើឡើងក្នុងគោលដៅ ដើម្បីធានាឲ្យមានភាពកាន់តែច្បាស់លាស់ ចំពោះឯកសារចុះបញ្ជីពាណិជ្ជកម្មទាំងនោះ។

ក្នុងការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ក្រសួងពាណិជ្ជកម្មបានបង្កើតនូវបញ្ជរមួយ ដែលជាការិយាល័យ សម្រាប់ទទួល នឹងធ្វើការត្រួតពិនិត្យចំពោះឯកសារទាំងនេះ។ បើក្នុងករណីដែលក្រសួងពាណិជ្ជកម្ម រកឃើញកំហុសណាមួយចំពោះឯកសារ នោះក្រសួង និងមិនទទួលនូវឯកសារទាំងនោះឡើយ។ ក្នុងករណីនេះ ខាងក្រសួងតម្រូវឲ្យ អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ទៅធ្វើការកែតម្រូវ ដោយត្រូវធ្វើការរៀបចំសារជាថ្មី នូវឲ្យសារទាំងនោះ ទាំងក្នុងប្រព័ន្ធ និងទាំងឯកសារច្បាប់

ដើម រួចធ្វើការដាក់ស្នើ និងយកមកកាន់ក្រសួង ដើម្បីធ្វើការត្រួតពិនិត្យសារជាថ្មីម្តងទៀត ឬក្រសួងធ្វើការបដិសេធចោលនូវការចុះបញ្ជីនេះទាំងស្រុងតែម្តង បើក្នុងករណីដែលក្រសួងរកឃើញថាមានឯកសារក្លែង។

មួយវិញទៀត បើក្នុងករណីដែលឯកសារទាំងនោះ មានកំហុសត្រង់ចំនុចសំខាន់ណាមួយ ដូចជាត្រង់ព័ត៌មានអភិបាល ឬម្ចាស់ហ៊ុន ព័ត៌មានស្តីពីភាគហ៊ុន ឬដើមទុនជាដើមនេះ ខាងក្រសួងពាណិជ្ជកម្ម និងបើកធ្វើការត្រួតពិនិត្យពិសេស ហើយត្រង់នេះអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មអាច និងមានបញ្ហាប្រឈម ដោយអាចនឹងត្រូវតម្រូវឲ្យធ្វើការបង់កម្រៃសេវាណាមួយថ្មី ចំពោះការកែប្រែនេះ ឬក៏ត្រូវបានក្រសួងធ្វើការបដិសេធ ចំពោះការចុះបញ្ជីក្រុមហ៊ុននោះតែម្តង។

**២. ការតម្កល់ទុកឯកសារដើម**

ក្រោយពេលដែលក្រសួងពាណិជ្ជកម្ម ទទួលបានឯកសារដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់បានរួចចប់សព្វគ្រប់ហើយ ប្រសិនបើឃើញថាឯកសារទាំងនោះមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវហើយ ក្រសួងពាណិជ្ជកម្ម និងទទួលទុកឯកសារមួយចំនួន ដើម្បីតម្កល់។ ឯកសារដែលក្រសួងត្រូវទទួលតម្កល់ទាំងអស់ត្រូវតែជាច្បាប់ដើម ហើយចំពោះលក្ខន្តិកៈក្រុមហ៊ុន និងកិច្ចសន្យាបង្កើតក្រុមហ៊ុនត្រូវធ្វើឡើយជា ៤ (បួន) ច្បាប់ ដោយចំនួន ២ (ពីរ) ច្បាប់ត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម[37]។ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ត្រូវធ្វើការបោះត្រាក្រសួងពាណិជ្ជកម្ម ដើម្បីជាការបញ្ជាក់ពីភាពត្រឹមត្រូវ ហើយត្រូវធ្វើការតម្កល់ទុកជាច្បាប់ដើម (Hardware) នូវឯកសារទាំងនោះ។

[37] មានបកស្រាយនៅក្នុងកថាខណ្ឌទី ៣ ស្តីពីការមកកាន់ក្រសួងពាណិជ្ជកម្មដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ឯកសារ នៃផ្នែកទី២ ក្នុងជំពូកទី១ ខាងលើ។

# ជំពូកទី២

# កំណែទម្រង់ពាក់ព័ន្ធ និងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច

ក្រោយពីបានឆ្លងកាត់ការបង្ហាញពីសញ្ញាណទូទៅនៃផលវិបាក នៃការចុះបញ្ជីពាណិជ្ជកម្មរួមមក លោកអ្នកបានយល់ច្បាស់ពីប្រព័ន្ធនេះហើយទាំងរបៀបប្រើប្រាស់ និងនីតិវិធីនៃការចុះបញ្ជី ក៏ប៉ុន្តែលោកអ្នកពុំទាន់បានដឹងច្បាស់លាស់ថាប្រព័ន្ធនេះ បានធ្វើកំណែទម្រង់យ៉ាងដូចម្តេចខ្លះនោះទេ? ហេតុដូច្នោះនៅក្នុងជំពូកនេះ ខ្ញុំនឹងលើបង្ហាញពីកំណែទម្រង់នានា ដែលពាក់ព័ន្ធនឹងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះមកធ្វើការបកស្រាយ ដែលក្នុងនោះមាន ៖ (ផ្នែកទី១) កំណែទម្រង់ជាទូទៅ និង (ផ្នែកទី២) កំណែទម្រង់ផ្សេងៗទៀតដែលពាក់ព័ន្ធ ។

## ផ្នែកទី១. កំណែទម្រង់ទូទៅ

ក្រោយពីការសិក្សាទៅលើប្រព័ន្ធស្វ័យប្រវត្តិកម្មនេះរួចមក យើងឃើញថា ប្រព័ន្ធនេះវាបានធ្វើការផ្លាស់ប្តូរនូវទម្រង់នៃការចុះបញ្ជីពាណិជ្ជកម្មចំនួន២ (ពីរ) គឺ កំណែទម្រង់បរិបទ ការងារ (កថាភាគទី១) និង កំណែទម្រង់ចំពោះឯកសារ (កថាភាគទី២)។

### កថាភាគទី១: បរិបទការងារ

#### ១. ចំពោះអ្នកស្នើ សុំចុះបញ្ជីពាណិជ្ជកម្ម

ការចុះបញ្ជីពាណិជ្ជកម្ម គឺផលលំបាកមួយ ដែលធ្វើឲ្យអ្នកស្នើសុំចុះបញ្ជីមានការលំបាកជាមួយនឹងនីតិវិធីដ៏ស្មុគស្មាញ ជាពិសេសចំពោះការរៀបចំឯកសារ និងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម។ ទទឹមនឹងភាពស្មុគស្មាញទាំងនេះ ការដែលដាក់ចេញនូវប្រព័ន្ធនៃការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិចគឺបាននាំមកនូវផលលវិបាកបន្ថែមទៀតដល់អ្នកស្នើសុំចុះបញ្ជី ដោយប្រព័ន្ធនេះបានបន្ថែមនូវកាតព្វកិច្ចថ្មីមួយទៀតដល់ពួកគេ។ កាតព្វកិច្ចថ្មីដែលបន្ថែមមកលើអ្នកស្នើសុំចុះបញ្ជីតាមរយៈប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មនេះគឺការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានវិទ្យាដើម្បីចុះបញ្ជីពាណិជ្ជកម្ម។ ប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មថ្មីនេះ បានធ្វើឲ្យ បរិបទនៃការបំពេញការងារចំពោះការចុះបញ្ជីពាណិជ្ជកម្មរបស់អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មមានការផ្លាស់ប្តូរ ដែលក្នុងនោះមាន៖

១.១. ការផ្លាស់ប្តូរចំពោះការរៀបចំឯកសារ

កាលពីមុន(ប្រព័ន្ធចាស់) ឯកសារត្រូវបានធ្វើឡើងដោយផ្ទាល់ដៃ និង ជាលិខិតស្នាម ហើយត្រូវដាក់ជូនទៅកាន់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដោយផ្ទាល់ដៃ។ តែផ្ទុយទៅវិញចំពោះប្រព័ន្ធស្វ័យប្រវត្តិកម្មនេះគឺមានលក្ខណៈខុសស្រលៈពីមុន ដោយនូវរាល់ឯកសារចុះបញ្ជីពាណិជ្ជកម្មទាំងអស់ តម្រូវឲ្យអ្នកចុះបញ្ជីធ្វើឡើងជាពីរទម្រង់ គឺទម្រង់លិខិតស្នាម និងទម្រង់

អេឡិកត្រូនិច ហើយត្រូវបញ្ជូនទៅក្នុប្រព័ន្ធនូវឯកសារជាទម្រង់អេឡិកត្រូនិច និង ធ្វើការផ្ទេរទិន្នន័យនេះទៅកាន់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ដោយមិនចាំ បាច់ទៅកាន់ក្រសួងពាណិជ្ជកម្មឡើយ។ ត្រង់នេះបង្ហាញឲ្យឃើញថា ចំពោះការរៀបចំឯកសារត្រូវបានផ្លាស់ប្តូរ ដោយអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មត្រូវធ្វើឡើងជា ២ (ពីរ)ដង។ ការដែលតម្រូវឲ្យរៀបចំឯកសារសម្រាប់ ការចុះបញ្ជីពាណិជ្ជកម្ម នៅតែបន្តធ្វើឡើងជាទម្រង់លិខិតស្នាមដ៏ដែលនេះ ដោយសារតែបច្ចុប្បន្ន ឯកសារទម្រង់អេឡិកត្រូនិច ពុំទាន់មានការទទួលស្គាល់ពីអានុភាពគតិយុត្តរបស់វានៅឡើង ពោលគឺមិនមានច្បាប់ណាមួយទទួលស្គាល់នោះទេ។

១.២.ការអនុវត្តជាក់ស្តែងចំពោះការចុះបញ្ជីពាណិជ្ជកម្ម

បើយើងធ្វើការប្រៀបធៀបប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ជាមួយនិងប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មចាស់ យើងសម្គាល់ឃើញច្បាស់ថាវាមានលក្ខណៈខុសពីគ្នាស្ទើរទាំងស្រុងចំពោះបរិបទការងារនៃការចុះបញ្ជីពាណិជ្ជកម្ម ហើយជាពិសេសនោះ គឺចំពោះបែបបទនីតិវិធីនៃការស្នើសុំចុះបញ្ជីពាណិជ្ជកម្មនេះ។ ប្រព័ន្ធស្វ័យប្រវត្តិកម្មបានកែទម្រង់លើប្រព័ន្ធនៃការចុះបញ្ជីចាស់ ដោយបានកែតម្រូវ ឲ្យអ្នកចុះបញ្ជីពាណិជ្ជកម្មផ្លាស់ប្តូរនូវទម្រង់នៃការចុះបញ្ជីដោយដៃផ្ទាល់ជាមួយមន្ត្រីនៃក្រសួងពាណិជ្ជកម្ម ដូរមកធ្វើការស្នើសុំដោយផ្ទាល់វិញជាមួយនិងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម ។

ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មថ្មីនេះ បានផ្តល់ឲ្យនូវភាពស្មុគស្មាញថ្មីមួយដល់អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ដោយពួកគេត្រូវ ចំណាយពេលវេលា ក៏ដូចជាថវិកាក្នុងការសិក្សាស្វែយល់បន្ថែមអំពីប្រព័ន្ធនេះ និង ថែមទាំងបញ្ហាមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ដូចជាការប្រើប្រាស់សេវាកម្មអ៊ិនធឺណែត (Internet) ការប្រើប្រាស់ឧបករណ៍អេឡិកត្រូនិច ការប្រើប្រាស់ឯកសារអេឡិកត្រូនិចជាដើម។

១.៣. ការគ្រប់គ្រងព័ត៌មានសហគ្រាស ក្រុមហ៊ុន

ប្រព័ន្ធស្វ័យប្រវត្តិកម្មបានផ្តល់ទៅឲ្យអ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ជាពិសេសចំពោះម្ចាស់សហគ្រាស ក្រុមហ៊ុនពាណិជ្ជកម្មនូវទម្រង់ថ្មីមួយ ដែលអាចឲ្យពួកគេធ្វើការគ្រប់គ្រងទិន្នន័យ ព័ត៌មាន សហគ្រាស ក្រុមហ៊ុនរបស់ខ្លួនបានដោយផ្ទាល់នៅលើប្រព័ន្ធនេះ។ ពាណិជ្ជករដែលជាម្ចាស់សហគ្រាស ឬអ្នកគ្រប់គ្រងក្រុមហ៊ុនទាំងអស់ អាចធ្វើការគ្រប់គ្រងទិន្នន័យក្រុមហ៊ុន សហគ្រាសរបស់ខ្លួនបាន តាមរយៈគណនីផ្ទាល់ខ្លួន ដែលបានបង្កើតឡើងជាមួយនិងប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។ គណនីនេះ គឺជាគណនីដំបូងដែលបានបង្កើតឡើង សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដូចនេះពេលបង្កើតគណនីដំបូងដើម្បីប្រើប្រាស់ប្រព័ន្ធនេះ ជាលើកដំបូង

អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្មត្រូវប្រាកដថា ឈ្មោះគណនីដែលត្រូវបានដាក់ គឺជាឈ្មោះរបស់ម្ចាស់សហគ្រាស ឬអ្នកគ្រប់គ្រងក្រុមហ៊ុននោះ ឬជាឈ្មោះដែលមានការយល់ព្រមពីក្រុមហ៊ុន ដែលបានអនុញ្ញាតិឲ្យដាក់។

បើក្នុងករណីដែលការស្នើសុំចុះបញ្ជីក្រុមហ៊ុន សហគ្រាសទាំងឡាយណា ដែលបានធ្វើឡើងដោយអ្នកតំណាង មុននឹងធ្វើការដាក់ឈ្មោះគណនី អ្នកតំណាងដោយអាណត្តិនោះ ត្រូវតែពិភាក្សា និងទទួយការសម្រេចពីអាណត្តិទាយកជាមុនសិន។ ការកំណត់ឈ្មោះ គណនីនេះមានសារសំខាន់ណាស់ ព្រោះថាឈ្មោះដែលត្រូវបានដាក់នេះ និងត្រូវបានតម្កល់ទុកនៅក្នុងប្រព័ន្ធរហូតដល់ក្រុមហ៊ុននេះត្រូវបានលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ហើយឈ្មោះនេះមិនអាចធ្វើការផ្លាស់ប្តូរបាននោះទេ ។

ចំពោះការគ្រប់គ្រង និងប្រើប្រាស់គណនី គឺត្រូវធ្វើឡើងដោយម្ចាស់គណនីនេះផ្ទាល់ ឬក៏ប្រគល់សិទ្ធិទៅឲ្យបុគ្គលណាម្នាក់ ដើម្បីគ្រប់គ្រងជំនួស ហើយការគ្រប់គ្រងគណនីនេះ គឺដាច់ខាតត្រូវតែជាការសម្ងាត់។ អ្នកគ្រប់គ្រងគណនី អាចនឹងត្រូវបានផ្លាស់ប្តូរដោយហេតុនៃប្រការណាមួយ ដូចជា ការទទួលមរណៈភាព ការបាត់បង់សមត្ថភាព ឬអលទ្ធភាព ដោយការដកហូតសិទ្ធិ ឬ ដោយការលះបង់សិទ្ធិ និងដោយកត្តាមួយចំនួនទៀតជាអាទិ៍។ ក្នុងករណីនេះ អ្នកស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវមកកាន់ក្រសួងពាណិជ្ជកម្ម ដើម្បីដាក់ពាក្យស្នើសុំផ្លាស់ប្តូរគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។ ក្រោយពេលដែលក្រសួងធ្វើការសម្រេចលើពាក្យសុំនេះហើយក្រសួងពាណិជ្ជកម្ម នឹងធ្វើការផ្ទេរទិន្នន័យ សហគ្រាស ហ៊ុនដែលបានស្នើសុំនោះ ទៅក្នុងគណនីថ្មីដែលបានដាក់ជូននៅក្នុងពាក្យសុំនោះ។ ចំពោះការស្នើសុំធ្វើការផ្លាស់ប្តូរគណនីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មតម្រូវឲ្យបង់កម្រៃសេវារដ្ឋបាល ដូចដែលបានកំណត់ដោយក្រសួងពាណិជ្ជកម្ម។

### ២. ចំពោះមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម

២.១. ការផ្លាស់ប្តូរទម្រង់ការងារ

ការធ្វើការកំណែទម្រង់នូវប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្ម ពីប្រព័ន្ធចាស់ដែលធ្វើឡើងដោយដៃ មកប្រព័ន្ធថ្មីដែលធ្វើឡើងដោយប្រព័ន្ធស្វ័យប្រវត្តិ បានធ្វើឲ្យទម្រង់ការងារទូទៅរបស់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្មមានការផ្លាស់ប្តូរ ។ ជាទូទៅប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មថ្មីនេះ អាចដំណើរការទៅបានលុះត្រាណា ប្រព័ន្ធការងាររបស់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មត្រូវបានរៀបចំរួចរាល់ជាមុនសិន។ យ៉ាងណាមិញ មុនការដាក់ឲ្យដំណើរការ នូវប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ក្រសួងពាណិជ្ជកម្មបានធ្វើការកែទម្រង់នូវបែបបទការងារ

មន្ត្រីរបស់ខ្លួន ជាពិសេសនោះគឺ ចំពោះមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម។ ការធ្វើកំណែទម្រង់នេះមានពីរគឺ ទី១ (មួយ) ការធ្វើកំណែម្រង់ការិយាល័យ ដោយបានធ្វើការបំពាក់នូវសម្ភារៈឧបករណ៍ដែលពាក់ព័ន្ធ ក្នុងការបម្រើដល់ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ដូចជា ការបំពាក់ម៉ាស៊ីនកុំព្យូទ័រ ប្រព័ន្ធអ៊ិធឺណែតជាដើម និងទីពីរ (២) គឺ ការធ្វើកំណែទម្រង់ចំពោះការអនុវត្តការងារជាក់ស្តែង ដោយក្រសួងបានផ្តល់ទៅឲ្យ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនូវកាតព្វកិច្ចថ្មីមួយ គឺការអនុវត្តន៍ ការងារជាក់ស្តែងត្រូវធ្វើឡើងតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម[38]។

ចំពោះការផ្គត់ផ្គង់សំភារៈការិយាល័យចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានធ្វើឡើងក្រោមកិច្ចឧបត្ថមពីម្ចាស់ជំនួយពហុភាគី (MTDF) ដែលបានផ្តល់ឲ្យមកក្រសួងពាណិជ្ជកម្មតាមរយៈធនាគារពិភពលោក (WORLD BANK) ចាប់តាំងពីឆ្នាំ២០១១ មក។ កិច្ចជំនួយឧបត្ថមនេះ គឺធ្វើឡើងដើម្បីរៀបចំនូវគម្រោងផែនការមេព័ត៌មានវិទ្យា និងទូគមនាគម៍មួយ ដើម្បីធ្វើការបង្កើត និងផ្គត់ផ្គង់នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ធ្វើការចុះបញ្ជីនៅតាមស្ថាប័ននានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅធ្វើបច្ចុប្បន្នភាព នូវការផ្តល់សេវាសាធារណៈទាំងនោះ ឲ្យកាន់តែមានភាពប្រសើរឡើង ស្របតាមទិសដៅ ក្នុងការទាក់ទាញវិនិយោគ នៅក្នុងប្រទេសកម្ពុជា។

២.២. ការផ្តល់សេវាកម្មចុះបញ្ជីពាណិជ្ជកម្ម

កាលពីមុនការចុះបញ្ជីពាណិជ្ជកម្មត្រូវបានធ្វើឡើងដោយផ្ទាត់ដៃ ដោយមន្ត្រីទទួល បន្ទុកចុះបញ្ជីពាណិជ្ជកម្ម ត្រូវធ្វើការទំនាក់ទំនងដោយផ្ទាល់ជាមួយអតិថិជន ក្នុងការផ្តល់ព័ត៌មាន ការទទួលពាក្យសុំ ឯកសារ និងធ្វើការត្រួពិនិត្យលើឯកសារជាលិខិតស្នាមទាំងនោះដោយផ្ទាល់ដៃ។ តែផ្ទុយមកវិញក្រោយពីការដាក់ឲ្យអនុវត្តនូវប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច ទម្រង់ការងារពីមុនទាំងនោះ ត្រូវបានធ្វើការផ្លាស់ប្តូរទាំងស្រុង។ តាមរយៈការប្រើប្រាស់នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម អាចធ្វើការទំនាក់ទំនងជាមួយអតិថិជនបានតាមរយៈប្រព័ន្ធអេឡិកត្រូនិច អ៊ីម៉ែល ឬ លេខទូរស័ព្ទ។

ចំពោះការទទួលពាក្យសុំ ឯកសារ និងការត្រួតពិនិត្យឯកសារ ត្រូវបានធ្វើឡើងដោយផ្ទាល់តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ដោយឯកសារទាំងនោះ គឺជាឯកសារទម្រង់អេឡិកត្រូនិច (PDF)។ របៀបនៃការទទួលពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានធ្វើឡើងតាមរយៈការផ្ទេរទិន្នន័យ

[38] របាយការណ៍សរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំ ២០១៦ និងទិសដៅអនុវត្តការងារពាណិជ្ជកម្មឆ្នាំ ២០១៧ របស់ក្រសួងពាណិជ្ជកម្ម ចំនុច១.១.២.២.។

ពីអ្នកប្រើប្រាស់ម្នាក់ (អតិថិជន) ទៅកាន់អ្នកប្រើប្រាស់ម្នាក់ទៀត (មន្ត្រីទទួលបន្ទុក) តាម រយៈប្រព័ន្ធស្វ័យប្រវត្តិកម្ម ហើយចំពោះការសម្រេចសេក្តីលើពាក្យសុំ ត្រូវបានធ្វើឡើងក្រោមរូបភាព នៃនីតិវិធីថ្មីមួយ ដោយក្នុងនោះ គេធ្វើការបែងចែក និងបញ្ជូនឯកសារទៅកាន់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម តាមផ្នែកនីមួយៗ តាមរយៈការផ្ទេរ ពីគណនីប្រើប្រាស់មួយ (មន្ត្រីទទួលឯកសារ) ទៅកាន់គណនីមួយទៀត (មន្ត្រីទទួលបន្ត) ដោយផ្ទាល់តាម រយៈប្រព័ន្ធ ដើម្បីធ្វើការបំពេញភារកិច្ចតាមតួនាទី សមត្ថកិច្ចរៀងៗខ្លួន។

មួយវិញទៀត ចំពោះការទូទាត់កម្រៃសេវារដ្ឋបាល ដែលធ្វើឡើងដោយផ្ទាល់ដៃពីមុន ត្រូវបានកែទម្រង់ផងដែរ ដោយក្រសួងបានរៀបចំឲ្យមានការទូទាត់តាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ។ ពាក់ព័ន្ធនឹងការទូទាត់ប្រាក់តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (Online) ក្រសួងពាណិជ្ជកម្ម បានធ្វើការសហប្រតិបត្តិការជាមួយធនាគារមួយចំនួន ដើម្បីសម្របសម្រួលនូវប្រព័ន្ធរួមមួយ ក្នុងការដំណើរការទូទាត់ប្រាក់នេះ។ សរុបសេចក្តីមក ចំពោះការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចថ្មីនេះ វាគឺជាការផ្តល់នូវទម្រង់សេវាកម្មក្នុងការចុះបញ្ជីតាមបែបថ្មីមួយ ហេតុដូចនេះមានន័យថា ទម្រង់នៃការផ្តល់សេវាកម្មពាណិជ្ជកម្មត្រូវបានផ្លាស់ប្តូរ។

២.៣. ចំពោះការគ្រប់គ្រងបញ្ជីពាណិជ្ជកម្ម

បញ្ជីពាណិជ្ជកម្ម ត្រូវបានគ្រប់គ្រងដោយមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម[39]។ ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម បានផ្តល់ទៅឲ្យក្រសួងពាណិជ្ជកម្ម នូវទម្រង់បញ្ជីពាណិជ្ជកម្មថ្មីមួយគឺ "បញ្ជីពាណិជ្ជកម្មអេឡិកត្រូនិច" ដែលបញ្ជីថ្មីនេះបានផ្តល់ឲ្យនូវភាពជាស្វ័យប្រវត្តិកម្មមួយ ដល់មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ចំពោះការផ្តល់សេវាកម្មចុះបញ្ជីពាណិជ្ជកម្មរបស់ខ្លួន ដោយពួកគាត់អាចធ្វើដំណើរការនីតិវិធីរបស់ខ្លួនបាននៅលើប្រព័ន្ធដោយផ្ទាល់។ មួយវិញទៀត ដោយនូវរាល់ព័ត៌មានទាំងអស់របស់ក្រុមហ៊ុន សហគ្រាស គឺត្រូវបានទទួល និងតម្កល់ទុកជាទម្រង់អេឡិកត្រូនិច នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដូចនេះ នូវរាល់ការទទួលឯកសារ ការពិគ្រោះយោបល់ ការទំនាក់ទំនងជាមួយអតិថិជន និងការផ្តល់នូវអត្តលេខដល់ក្រុមហ៊ុន សហគ្រាស គឺត្រូវបានធ្វើឡើងដោយផ្ទាល់នៅលើប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ហើយការគ្រប់គ្រងទិន្នន័យ ក៏ត្រូវបានធ្វើឡើងដោយផ្ទាល់ជាមួយប្រព័ន្ធនេះផងដែរ។

ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម ត្រូវបានគ្រប់គ្រង និងផ្តល់ឲ្យដោយក្រុមហ៊ុនផ្តល់សេវាចុះបញ្ជីពាណិជ្ជកម្មលំដាប់ថ្នាក់ពិភពលោកមួយឈ្មោះ Foster Moore ដែលមានទី

[39] មាត្រា១០ នៃច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (២៦ ខែ មិថុនា ឆ្នាំ១៩៩៥)។

ស្នាក់កណ្តាលនៅប្រទេស នូវែលហ្សេឡង់ ( NEW ZEALAND )។ Foster Moore មានប្រទេសជាអតិថិជន សរុប១៨ (ដប់ប្រាំបី) ក្នុងចំណោមនោះ ប្រទេសកម្ពុជា ក៏បានក្លាយជាអតិថិជនរបស់ Foster Moore កាលពីដើមឆ្នាំ ២០១៦ ផងដែរ។ កម្ពុជាទទួលយកសេវាកម្មស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មនេះ គឺក្នុងគោលបំណង ដើម្បីបង្កើតឲ្យបានទ្បង នូវប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មមួយ ក្នុងចក្ខុវិស័យដើម្បីធ្វើការអភិវឌ្ឍន៍ វិស័យពាណិជ្ជកម្មនៅកម្ពុជា ឲ្យមានលក្ខណៈកាន់តែប្រសើរឡើងស្របតាមការប្រកួតប្រជែងផ្នែកទីផ្សារពាណិជ្ជកម្មបច្ចុប្បន្ននៅក្នុងតំបន់ និងនៅក្នុងសាកលលោក។ Foster Moore បានផ្តល់ឲ្យកម្ពុជា ក៏ដូចជាប្រទេសដែលជាអតិថិជនផ្សេងៗទៀត នូវកម្មវិធីចុះបញ្ជីពាណិជ្ជកម្មមួយដែលមានឈ្មោះថា ″កាតាលិស (CATALYSTTM)″ ដែលជាកម្មវិធីមួយ មានមុនងារក្នុងការ ជម្រុញឲ្យមានដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មឡើង[40] ។

មួយវិញទៀត ដើម្បីសម្រួល ដល់ការគ្រប់គ្រងបញ្ជីពាណិជ្ជកម្មអេឡិកត្រូនិចនេះ ក្រសួងពាណិជ្ជកម្មបានរៀបឡើងចំនូវ Data Center មួយបំពាក់នៅក្នុងក្រសួង ដើម្បីធ្វើការស្តុកទុកនូវទិន្នន័យពាណិជ្ជកម្មទាំងអស់ ដែលពាក់ព័ន្ធនិងការចុះបញ្ជីពាណិជ្ជកម្ម។

Data Center គឺជាម៉ាស៊ីនមេ ដែលបានបង្កើតឡើង ដោយគម្រោង ICT master plan ក្នុងការរៀបចំ នូវប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ក្រសួងពាណិជ្ជកម្មឡើង ដើម្បីយកទៅប្រើប្រាស់សម្រាប់ការផ្តល់សេវាពាណិជ្ជកម្មរបស់ខ្លួន។

**កថាភាគទី ២. ការប្រែប្រួលចំពោះឯកសារ**

**១. ចំពោះទម្រង់ប្រតិវេទន៍**

ប្រតិវេទន៍គឺជា ទម្រង់ព័ត៌មានទាំងអស់ របស់ក្រុមហ៊ុន សហគ្រាស ដែលច្បាប់តម្រូវឲ្យបំពេញ និងផ្តល់មកកាន់ក្រសួងជាការដាច់ខាត ក្នុងការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនសហគ្រាស និងដើម្បីធ្វើការតម្កល់ទុក ឬជាកម្រងឯកសារមួយដែលធ្វើឡើងដើម្បី ជូនតំណឹងអំពីព័ត៌មានក្រុមហ៊ុនសហគ្រាស ទៅកាន់ក្រសួងពាណិជ្ជកម្ម។ តាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មគំរូប្រតិវេទន៍ ត្រូវតែសរសេរលើលិខិតគំរូមួយ ដែលបានផ្តល់ឲ្យដោយក្រសួងពាណិជ្ជកម្ម[41]។ ក្រោយពីពេលដែលធ្វើការបំពេញនូវព័ត៌មានទាំងអស់គ្រប់គ្រាន់ហើយ មុននិងធ្វើការបញ្ជូនមកកាន់ក្រសួងពាណិជ្ជកម្ម សមាជិក្រុមប្រឹក្សាភិបាល ឬម្ចាស់ភាគហ៊ុនណាម្នាក់ត្រូវតែ

[40] ព័ត័មានលម្អិត សូមចូលទៅកាន់គេហទំព័រ www.fostermoore.com

[41] មាត្រា ១៧ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩។

ផ្តិតស្នាមមេដៃនៅលើគំរូប្រតិវេទន៍នោះ ដើម្បីជាការបញ្ជាក់ អះអាងថា នូវរាល់ព័ត៌មានដែលខ្លួនបានបំពេញ គឺពិតជាត្រឹមត្រូវ និងមិនមានក្លែងបន្លំ។ ផ្ទុយមកវិញ បច្ចុប្បន្នតាមរយៈការធ្វើកំណែទម្រង់របស់ក្រសួងពាណិជ្ជកម្ម ដោយការធ្វើការផ្លាស់ប្តូរនូវទម្រង់នៃការចុះបញ្ជីពាណិជ្ជកម្ម ពីការធ្វើឡើងលើក្រដាស់ស្នាម មកធ្វើឡើងជាអេឡិកត្រូនិចវិញ វាបាននាំឲ្យទម្រង់ប្រតិវេទន៍នេះ ត្រូវបានផ្លាស់ប្តូរផងដែរ ។ នៅក្នុងការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម ទម្រង់គំរូប្រតិវេទន៍ត្រូវបានផ្តល់ឲ្យជាលក្ខណៈ អេឡិកត្រូនិចរួចជាស្រេចនៅក្នុងប្រព័ន្ធដែលអ្នកស្នើសុំចុះបញ្ជីអាចធ្វើការបំពេញវាបានដោយផ្ទាល់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម និងអាចធ្វើការបញ្ជូននូវគំរូប្រតិវេទន៍នេះមកកាន់ក្រសួងពាណិជ្ជកម្ម បានតាមរយៈប្រព័ន្ធនេះ ដោយមិនចាំបាច់មានផ្តិតស្នាមមេដៃ របស់អភិបាល ឬ ម្ចាស់ភាគហ៊ុនណាមួយនោះឡើយ។

**២.ចំពោះវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម**

វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកកម្ម គឺជាទម្រង់នៃឯកសារគតិយុត្តមួយដែលបញ្ជាក់អំពីអត្តសញ្ញានៃក្រុមហ៊ុន សហគ្រាសនីមួយៗ និង ជាឯកសារដែលបញ្ជាក់ពីនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន សហគ្រាសផងដែរ។ វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម មានបង្ហាញបញ្ជាក់អំពី ឈ្មោះក្រុមហ៊ុន សហគ្រាសដែលបានចុះបញ្ជី លេខចុះបញ្ជីពាណិជ្ជកម្ម និង បញ្ជាក់អំពីទ្រង់ទ្រាយក្រុមហ៊ុន សហគ្រាសផងដែរ។

យ៉ាងណាមិញតាមរយៈការធ្វើកំណែទម្រង់ និងការធ្វើបច្ចុប្បន្នភាពការងារ ចុះបញ្ជីពាណិជ្ជកម្ម តាមរយៈការអនុវត្តការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្រសួងពាណិជ្ជកម្មបានសម្រេចលុប នូវទម្រង់វិញ្ញាបនបត្រចាស់ដែលមានសុពលភាពត្រឹម ៣ (បី) ឆ្នាំ ដោយធ្វើការចេញនូវទម្រង់វិញ្ញាបនបត្រថ្មី មកជំនួសវិញ ដែលវិញ្ញាបនបត្រថ្មីនេះ គ្មានរយៈពេលសុពលភាពកំណត់ឡើយ ហើយនិងចេញឲ្យតាមរយៈប្រព័ន្ធស្វ័យប្រវត្តិ។ វិញ្ញាបនបត្រថ្មីនេះមានលក្ខណៈសម្បត្តិ ពីរដែលខុសពីមុនគឺ ទ្រង់ទ្រាយ និងមុខងាររបស់វា។ ចំពោះទ្រង់ទ្រាយគឺ វិញ្ញាបនបត្រថ្មីនេះបានដាក់បញ្ចូលបន្ថែមនូវ QR កូដ ដែលជាឧបករណ៍អេឡិកត្រូនិចមួយសម្រាប់ផ្ទុកព័ត៌មាន និងទិន្នន័យរបស់ក្រុមហ៊ុន។ ចំពោះមុខងារ វិញ្ញាបនបត្រនេះមានដូចជា ការផ្តល់នូវសុពលភាពគ្មានការកំណត់ ការដែលអាចផ្តល់នូវភាពងាយស្រួលដល់ក្រុមហ៊ុន សហគ្រាសក្នុងការទាញយកទិន្នន័យក្រុមហ៊ុនសហគ្រាសរបស់ខ្លួនបាន តាមរយៈ QR កូដ ដែលមានស្រាប់នៅលើវិញ្ញាបនបត្ររបស់ខ្លួន[42]។

[42] យោងពីរបាយការណ៍ប្រចាំឆ្នាំ ២០១៦ របស់ក្រសួងពាណិជ្ជកម្ម

## ផ្នែកទី២. កំណែទម្រង់ផ្សេងៗដែលទាក់ទងនិងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច

នៅក្នុងផ្នែកនេះ ខ្ញុំនិងធ្វើការលើកបង្ហាញលោកអ្នក ពីការធ្វើកំណែទម្រង់មួយចំនួនទៀត ដែលពាក់ព័ន្ធ នឹងការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិច ដែលក្នុងនោះ រួមមាន ការចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (កថាភាគទី១) ការតម្កល់ប្រតវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (កថាភាគទី២) និងក្រុមការងាររួមរៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម (កថាភាគទី៣)។

### កថាភាគទី១. ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

#### ១. ភាតព្វកិច្ចក្នុងការចុះបញ្ជីក្រុមហ៊ុនពាណិជ្ជកម្មសារឡើងវិញ

កំណត់រាល់ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យ បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយណាដែលបានចុះបញ្ជីពាណិជ្ជកម្មមុនថ្ងៃទី ០៤ ខែមករា ឆ្នាំ២០១៦ មកចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម តាមគេហទំព័រ www.businessregistration.moc.gov.kh ដើម្បីឲ្យការផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យ ការបំពេញទម្រង់បែបបទនៃលិខិតជូនដំណឹងដ៏ទៃទៀត ព្រមទាំងឯកសារចាំបាច់ត្រូវផ្ញើរជូន ឬចេញដោយក្រសួងពាណិជ្ជកម្មអាចទៅបានតាមប្រព័ន្ធអេឡិកត្រូនិច[43]។

អភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាស ត្រូវបំពេញព័ត៌មាន និង បញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យ ប្រវត្តិកម្ម សម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវ។ អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាស ដែលបានចុះបញ្ជីសារឡើងវិញរួចហើយ នឹងទទួលបានលេខចុះបញ្ជី និងទទួលបាននូវវិញ្ញាបនបត្រថ្មីមួយ ដែលផ្តល់ឲ្យដោយក្រសួងពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ដោយពុំមានកំណត់សុពលភាព[44]។ ការចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ត្រូវធ្វើឡើង ចាប់ពីថ្ងៃទី ០៤ ខែមករា ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៦ ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើង ។

ប្រសិនបើ អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងអស់ មិនទាន់បានចុះបញ្ជីក្រុមហ៊ុនរបស់ខ្លួនសារឡើងវិញ ក្នុងចន្លោះពីថ្ងៃទី០៤ ខែមករា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៦

[43] ប្រការ១ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

[44] ប្រការ២ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

ត្រូវតែបម្រុងទុកនាមករណ៍ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីជៀសវាងការបាត់បង់ឈ្មោះក្រុមហ៊ុនរបស់ខ្លួន ដែលបានចុះបញ្ជីមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ។ នាមករណ៍បម្រុងទុកនេះ មានសុពលភាព ៣ (បី) ខែ និងអាចស្នើសុំពន្យាបាន ០៣ ខែ បន្តទៀតបានដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។ ការបម្រុងនាមករណ៍ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចមុន ថ្ងៃទី ០៤ ខែមករា ឆ្នាំ ២០១៦ ត្រូវបញ្ចូលឯកសារវិញ្ញាបនបត្រដែលបានចុះបញ្ជីចាស់របស់ខ្លួនចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ក្នុងករណីដែលអភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាសមិនអាចបំពេញព័ត៌មាន និងបញ្ចូលឯកសារទាំងអស់ ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ចុះបញ្ជីពាណិជ្ជកម្ម តាមលក្ខខណ្ឌតម្រូវដោយខ្លួនឯងបាន អាចអញ្ជើញមកក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្ម ជួយបំពេញព័ត៌មាន និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មជំនួសបាន[45]។ ក្នុងករណី អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសមិនបានចុះបញ្ជីសារឡើងវិញតាមកាលបរិច្ឆេទកំណត់ នោះការចុះបញ្ជីសារឡើងវិញនៅ អាចបន្តបានរហូតដល់ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៦ តែត្រូវបង់សេវាកម្រៃសាធារណៈពេញលេញដូចការចុះបញ្ជីចំពោះក្រុមហ៊ុនថ្មីដែរ[46]។ ប្រសិនបើអភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាស មិនបានចុះបញ្ជីសារឡើងវិញមុនថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៦ នោះ ក្រសួងពាណិជ្ជកម្ម និងធ្វើលិខិតបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីជម្រះការតព្វកិច្ចពន្ធដារ និងបញ្ជូនទៅតុលាការដើម្បីអនុវត្តតាមនីតិវិធី[47]។

ការទូទាត់កម្រៃសេវារដ្ឋបាលដែលត្រូវបង់ចូលជាចវិការរដ្ឋ ត្រូវធ្វើតាមប្រព័ន្ធអេឡិកត្រូនិចរបស់ធនាគារស្របតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៤៣ សហវ. ប្រក ចុះថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។ ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចរាល់។ ក្នុងករណី ស្ថាបនិក អភិបាល ឬ ម្ចាស់ហ៊ុន អញ្ជើញមកនាយកដ្ឋានចុះបញ្ជីពណិកជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រី

[45] ប្រការ៣ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

[46] ប្រការ៤ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

[47] ប្រការ៥ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

ចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មជំនួស ការទូទាត់កម្រៃសេវា ត្រូវធ្វើដោយផ្ទាល់ នៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈ របស់ក្រសួងពាណិជ្ជកម្ម[48]។ ទោះបីជាយ៉ាងណាក៏ដោយ ការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញនេះនៅមិនទាន់បានបញ្ចប់ឡើង ដោយក្រសួងបានធ្វើការពន្យាបន្តការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញនេះ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧[49] ។

### ២. ឯកសារតម្រូវសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញ

ឯកសារសម្រាប់ការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធអេឡិកត្រូនិច រួមមាន ៖

- ឯកសារបញ្ជាក់អាសយដ្ឋានបញ្ជាក់ទីស្នាក់ការក្រុមហ៊ុនដូចជា ប័ណ្ណកម្មសិទ្ធិដីធ្លី កិច្ចសន្យាជួលផ្ទះឬ វិក័យបត្រទឹកភ្លើងជាដើម
- លក្ខន្តិកៈក្រុមហ៊ុន
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មចុងក្រោយ
- ប័ណ្ណប៉ាតង់ ឬវិក័យបត្របញ្ជាក់ការបង់ពន្ធប៉ាតង់ដែលចេញដោយនាយកដ្ឋានពន្ធដារ
- ឯកសារបញ្ជាក់អត្តសញ្ញាណរបស់សមាជិកក្រុមប្រឹក្សា ឬម្ចាស់ភាគហ៊ុនដែលមានដូចជាអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែន
- ក្នុងករណីម្ចាស់ភាគហ៊ុនជានីតិបុគ្គល
- វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនដើម
- លក្ខន្តិកៈក្រុមហ៊ុនដើម
- លិខិតតែងតាំងអ្នកតំណាងដែលចេញដោយក្រុមហ៊ុនមេ
- លិខិតធានាអះអាងនូវព័ត៌មានដែលបានបំពេញ និង មានបញ្ជាក់ដោយសមាសភាពក្រុមប្រឹក្សាភិបាលណាម្នាក់
- សេចក្តីប្រកាសថាមិនមែនជាអ្នករាជការសាធារណៈ ឬជាប់ទោសពៃរ៍ណាមួយ និងមានបញ្ជាក់ពីសមាសភាពក្រុមប្រឹក្សាភិបាល

---

[48] ប្រការ៦ នៃប្រកាសលេខ ៣០០ ពណ ចបព.ប្រក ចុះថ្ងៃទី ២៩, ១២, ២០១៥ ស្តីពី ការចុះបញ្ជីក្រុមហ៊ុន សហគ្រាសសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

[49] បើយោងតាមសេចក្តីជូនដំណឹងចុងក្រោយរបស់ក្រសួងពាណិជ្ជកម្ម លេខ២៧២៩ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការបន្តការចុះក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដែលតម្រូវឲ្យក្រុមហ៊ុន សហគ្រាស ដែលមិនទាន់បានចុះបញ្ជីសារឡើងវិញស្របតាមប្រកាសលេខ ៣០០ ព.ណ ចបព.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ មកធ្វើការចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្មបានរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧។

– ឯកសារបញ្ជាក់អំពីតួនាទី និងចំនួនបុគ្គលិកប្រសិនបើមាន។

### ៣.នីតិវិធីនៃការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

ការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម គឺដូចជានីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនថ្មីមួយដែរ ដោយក្នុងនោះ មានការរៀបចំឯកសារជាទម្រង់អេឡិកត្រូនិច ការបង្កើតគណនីសម្រាប់ប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ការអនុវត្តជាក់ស្តែងលើប្រព័ន្ធដែលមានការបញ្ចូលព័ត៌មាន និងការបញ្ចូលនូវឯកសារដោយ Upload ទៅតាមដំណាក់កាលនីមួយៗ និងការបោះពុម្ពចេញនូវវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្មជាដើមបានដូចគ្នា។ ជារួមមានន័យថា ការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មគឺវាមានលក្ខណៈដូចគ្នានូវគ្រប់ការប្រើប្រាស់នូវសេវាកម្មចុះបញ្ជីពាណិជ្ជកម្មទាំងអស់ដែលធ្វើឡើងតាមប្រព័ន្ធដ៏ទៃៗផ្សេងទៀតដែរ ដោយចំពោះការចុះបញ្ជីពាណិជ្ជកម្មទាំងនោះ ទៀតសោត វាមានលក្ខណៈខុសគ្នាតែទៅលើនីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រភេទនីមួយៗរបស់វាតែប៉ុណ្ណោះ។ ក្នុងនោះការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម តម្រូវឲ្យបង្កើតនូវគណនីដើម្បីប្រើប្រាស់ ដូចគ្នាទៅនឹងការចុះបញ្ជីចំពោះក្រុមហ៊ុនថ្មីមួយដែរ ហើយមិនត្រឹមតែប៉ុណ្ណោះគណនីនេះមានលក្ខណៈពិសេស ដែលអាចអនុញ្ញាតឲ្យលោកអ្នកយកទៅប្រើប្រាស់សម្រាប់ដំណើរការ ចុះបញ្ជីពណិជ្ជកម្មផ្សេងៗទៀតបានគ្រប់កាលៈទេសៈ ពោលគឺគណនីនេះ គឺជាប្រភេទនៃគណនីតែមួយនៃប្រព័ន្ធស្វ័យប្រវត្តិកម្ម។

## កថាភាគទី២ ៖ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

### ១. នីតិវិធីក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

រាល់ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនពាណិជ្ជកម្មបរទេស ដែលបានចុះបញ្ជីពាណិជ្ជកកម្ម នៅក្រសួងពាណិជ្ជកម្ម មានកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ដែលទាក់ទងទៅនឹងស្ថានភាពក្រុមហ៊ុន។ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រូវធ្វើឡើងតាមរយៈប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម និងតាមរយៈគេហទំព័រ www.businessregistration.moc.gov.kh[50]។ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លើភាពត្រឹមត្រូវ នៃបច្ចុប្បន្នភាពព័ត៌មានចុះបញ្ជីពាណិជ្ជកម្ម បំពេញព័ត៌មាន និងភ្ជាប់ឯកសារផ្សេងៗ តាមទម្រង់ដែលមានស្រាប់ នៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម។ ក្នុងករណីព័ត៌មានមិនត្រឹមត្រូវ

[50] ប្រការ១ នៃប្រកាសលេខ១០៧ ពណ.ចបព.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការបន្តពន្យាពេលការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ឬមានព័ត៌មានត្រូវកែប្រែ អ្នកគ្រប់គ្រងក្រុមហ៊ុន ត្រូវធ្វើការកែប្រែសម្រួលក្នុងផ្ទាំងព័ត៌មានក្រុមហ៊ុនជាមុនសិន មុននឹងចុចបញ្ជូនមកក្រសួងពាណិជ្ជកម្ម[51]។

### ២. ទម្រង់ឯកសារសម្រាប់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

ព័ត៌មាន និងសំណុំឯកសារតម្កល់ប្រតិវេទន៍ ដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម ជាទម្រង់អេឡិកត្រូនិច មានដូចខាងក្រោម៖

- ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំសម្រាប់ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត សាខា ឬតំណាងការិយាល័យក្រុមហ៊ុនបរទេស និងក្រុមហ៊ុនសហកម្ម
  - លេខអត្តសញ្ញាណកម្មសារពើពន្ធ
  - កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
  - ប័ណ្ណប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍ សម្រាប់រាល់សកម្មភាពអាជីវកម្ម ដែលកំពុងមានប្រតិបត្តិការ
  - ចំនួនបុគ្គលិក និងឯកសារភ្ជាប់ ស្តីពីតួនាទីនិយោជិកជាក់ស្តែង
  - អ៊ីម៉ែល ឬលេខទូរស័ព្ទក្រុមហ៊ុនដែលកំពុងប្រើប្រាស់
- ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត៖
  - លេខអត្តសញ្ញាណកម្មសារពើពន្ធ
  - កាលបរិច្ឆេទចុះបញ្ជីសារពើពន្ធ
  - បណ្ណប៉ាតង់នៃឆ្នាំដែលត្រូវប្រកាសប្រតិវេទន៍ សម្រាប់រាល់សកម្មភាពអាជីវកម្ម ដែលកំពុងមានប្រតិបត្តិការ[52]។

### ៣. កាតព្វកិច្ចក្នុងការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

កាលបរិច្ឆេទអំពីកាតព្វកិច្ចតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ សម្រាប់បណ្តាក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងនៃក្រុមហ៊ុនបរទេស នឹងត្រូវបានជូនតំណឹងតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទៅកាន់អាសយដ្ឋាននៃសារអេឡិកត្រូនិចរបស់ក្រុមហ៊ុន ដែលបានផ្តល់មកកាន់ក្រសួងពាណិជ្ជកម្មក្នុងពេលចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម នៅក្នុងខែទី ១១ (ដប់មួយ) គិតចាប់

[51] ប្រការ២ នៃប្រកាសលេខ១០៧ ពណ.ចបព.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការដម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ តាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

[52] ប្រប្រការ៣ នៃប្រកាសលេខ១០៧ ពណ.ចបព.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការដម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

ពីកាលបរិច្ឆេទចុះបញ្ជីតាមប្រព័ន្ធស្វ័យប្រវត្តិកម្មដំបូង។ ប្រព័ន្ធស្វ័យប្រវត្តិកម្ម និងបើកជូនសម្រាប់តម្កល់ប្រតិវេទន៍ប្រចាំឆ្នាំនៅខែទី ១២ (ដប់ពីរ) ហើយបន្តសម្រាប់រយៈពេល ០៣ (បី) ខែបន្ទាប់។ ក្នុងករណីដែលក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងក្រុមហ៊ុនបរទេស ខកខានពុំបានតម្កល់ប្រតិវេទន៍ក្នុងកំឡុងពេល ៣ (បី) ខែនេះ និងត្រូវទទួលការពិន័យ ដូចដែលមានកំណត់ដោយច្បាប់ និង ចែងក្នុងប្រការ៥នៃប្រកាសស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៧ [53]។

ក្រុមហ៊ុនពាណិជ្ជកម្ម សាខាក្រុមហ៊ុនបរទេស និង ការិយាលល័យតំណាងក្រុមហ៊ុនបរទេសទាំងឡាយណា ដែលមានការខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ត្រឹមថ្ងៃផុតកំណត់ នឹងត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល។ ក្នុងករណី ក្រុមហ៊ុន សាខាក្រុមហ៊ុនបរទេស និងការិយាល័យតំណាងកក្រុមហ៊ុនបរទេស ដែលខកខានមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ចាប់ពី ១ ឆ្នាំឡើងទៅ នឹងត្រូវបង់ប្រាក់ពិន័យ ព្រមទាំងបង់ថ្លៃសេវាប្រតិវេទន៍ប្រចាំឆ្នាំ ទៅតាមចំនួនឆ្នាំដែលខកខាន[54]។ ការបង់កម្រៃសេវា សម្រាប់ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំត្រូវធ្វើឡើងតាមប្រព័ន្ធអេឡិកត្រូនិច តាមរយៈធនាគារ[55]។

**កថាភាគទី៣ ៖ ក្រុមការងាររៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម**

ក្រុមការងារបង្កើតរៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួមត្រូវបានបង្កើតឡើង ក្នុងគោលដៅដើម្បីពង្រឹង និងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដារ និងដើម្បីធ្វើការគ្រប់គ្រងឲ្យបានកាន់តែប្រសើរឡើងនូវទិន្នន័យដែលបានចុះបញ្ជី។

**១. សមាសភាពក្រុមការងាររៀបចំយន្តការចុះបញ្ជីពានិជ្ជកម្មរួម**

ក្រុមការងារនេះមានសមាជិកចំនួន ១៤ (ដប់បួន) រូប ដែលមកពីក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលក្នុងនោះមាន ប្រធាន មួយ រូប សហប្រធាន ០១ (មួយ) រូប អនុប្រធាន០១ (មួយ) រូប និងសមាជិក ១១(ដប់មួយ) រូប។ សមាជិកម្នាក់ត្រូវបានជ្រើសរើស និងតែងតាំងពីស្ថាប័ន រៀងៗខ្លួន ក្នុងចំណោមមន្ត្រីដែលពាក់ព័ន្ធ ផ្នែកចុះបញ្ជី

[53] ប្រប្រការ៤ នៃប្រកាសលេខ១០៧ ពណ.ចបព.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការដម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

[54] ប្រប្រការ៥ នៃប្រកាសលេខ១០៧ ពណ.ចបព.ប្រក ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៧ ស្តីពីការដម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

[55] តាមប្រកាសរួមលេខ១៦៤៣ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងៗទៀតជាធរមាន[55]។

ពាណិជ្ជកម្ម ហើយប្រធាន សហប្រធាន និងអនុប្រធាន ត្រូវបានប្រកាសតែងតាំង ដោយប្រកាសអន្តរក្រសួងមួយ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[56]។

**២. ភារកិច្ចក្រុមការងាររៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្មរួម**

ក្រុមការងារនេះមានភារកិច្ចរៀបចំយន្តការចុះបញ្ជីរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម៖

- រៀបចំយន្តការ នីតិវិធី លិខិតបទដ្ឋាននានា ដើម្បីចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដាររួម
- រៀបចំតភ្ជាប់ប្រព័ន្ធ និងកម្មវិធីការងារ ដើម្បីអនុវត្តការចុះបញ្ជីរួម
- រៀបចំគម្រោងបច្ចេកទេស និងថវិកាដែលត្រូវការ សម្រាប់រៀបចំនិងដាក់អនុវត្តយន្តការចុះបញ្ជីរួម
- រៀបចំកិច្ចប្រជុំរួមជាប្រចាំឆ្នាំក្នុងរយៈពេលមួយខែម្តង ឬតាមការចាំបាច់ តាមការអញ្ជើញរបស់សហប្រធាន។ ក្រុមការងារអាចអញ្ជើញជំនាញការ និង អ្នកជំនាញរបស់តំណាងក្រសួង ស្ថាប័ន ចូលរួមផ្តល់យោបល់លើការងារពាក់ព័ន្ធ[57]។

[56] ប្រកា១ នៃប្រកាសអន្តរក្រសួងលេខ ៩០០ សហវ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ស្តីពី ការបង្កើតក្រុមការងារដើម្បីរៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុ។

[57] ប្រការ២ នៃប្រកាសអន្តរក្រសួងលេខ ៩០០ សហវ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការបង្កើតក្រុមការងារដើម្បីរៀបចំយន្តការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុ។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយបង្ហាញពីខ្លឹមសារនៃប្រធានបទស្តីពី ផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះរួមមក ខ្ញុំអាចធ្វើការសន្និដ្ឋានបានថា ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច គឺពិតជាមានផលវិបាកជាក់ស្តែងមួយចំនួន ពិតប្រាកដ មែន។ ដោយការចុះបញ្ជីពាណិជ្ជកម្មនេះ វាបានផ្តល់ឲ្យនូវប្រព័ន្ធស្វ័យប្រវត្តិកម្មមួយ ដែលជាទម្រង់ថ្មីបំផុត ក្នុងការប្រើប្រាស់ដើម្បីចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា ត្រង់នេះមានន័យថា ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្ម គឺជាបញ្ហាចម្បង ដែលនាំឲ្យមានផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិកត្រូនិចនេះ ហើយអ្វីដែលចោទនោះគឺ បញ្ហានៃការប្រើប្រាស់នូវប្រព័ន្ធនេះ ។ លើសពីនេះទៅទៀតការដាក់ឲ្យដំណើរការនូវប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិកនេះ មិនមែនកើតមានតែផលវិបាកទៅលើការប្រើប្រាស់ប្រព័ន្ធស្វ័យ ប្រវត្តកម្មនេះប៉ុណ្ណោះទេ ពោលគឺថែមទាំងមាននូវបញ្ហាមួយចំនួនផ្សេងទៀតផងដែរ ដូចជា នាំឲ្យមានការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញ និង ព្រមទាំងនាំឲ្យមានការធ្វើកំណែទម្រង់ផ្សេងៗទៀត ចំពោះ ក្រសួងពាណិជ្ជកម្ម ក៏ដូចជាចំពោះពាណិជ្ជករ ក្រុមហ៊ុន សហគ្រាសផងដែរ។ ដោយនិយាយជារួមមក គឺថាចំនុចដែលជា ផលវិបាកទាំងនេះ គឺវាបានកើតឡើងយ៉ាងជាក់ស្តែងចំពោះ ក្រសួងពាណិជ្ជកម្ម ជាពិសេសនាយកដ្ឋាចុះបញ្ជីពាណិជ្ជកម្មផ្ទាល់ និងព្រមទាំងចំពោះធុរជន ពាណិជ្ជករ និង វិនិយោគគិនដែលជាអ្នកចុះបញ្ជីយ៉ាងពិតប្រកដ ដែលទាំងនេះយើងអាចសម្គាល់ដឹងតាមរយៈសកម្មភាពរបស់ពួកគេ ចាប់តាំងពីការអនុវត្តដំបូង រហូតមកដល់ពេលបច្ចុប្បន្ន[58]។

ជាក់ស្តែង បើយើងពិនិត្យមើលទៅលើការចុះបញ្ជីពាណិជ្ជកម្មចំពោះក្រុមហ៊ុនថ្មីមួយវិញ យើងឃើញថា មានការលំបាកមួយចំនួនបានកើតមានឡើង ចំពោះទាំងអ្នកស្នើសុំចុះបញ្ជី និង ចំពោះទាំងមន្ត្រីទទួលបន្ទុកចុះបញ្ជីក្រុមហ៊ុន។ ដោយចំពោះអ្នកស្នើសុំចុះបញ្ជីក្រុមហ៊ុន ពួកគេជួបនូវការលំបាកមួយចំនួន ដោយសារការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិចនេះ គឺចំពោះការប្រើប្រាស់នូវប្រព័ន្ធដើម្បីចុះបញ្ជីពាណិជ្ជកម្ម ដោយហេតុថា ដើម្បីអាចធ្វើការចុះបញ្ជីក្រុមហ៊ុន អ្នកស្នើសុំចុះបញ្ជីត្រូវតែ ១ (មួយ) ចេះប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មនេះ ២ (ពីរ) ត្រូវរៀបចំឧបករណ៍សម្រាប់ដំណើរការ និងប្រើប្រាស់ប្រព័ន្ធ ទី៣ (បី) រៀបចំបម្លែង ឯកសារសម្រាប់ការចុះបញ្ជីក្រុមហ៊ុនទាំងអស់ទៅជាអេឡិកត្រូនិច ទី៤ (បួន) ការធ្វើប្រតិបត្តិការផ្ទាល់ជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មរបស់ក្រសួងពាណិជ្ជកម្ម និងទី៥ (ប្រាំ) ត្រូវយកឯកសារទៅផ្ទៀងផ្ទាត់ និងតម្កល់ទុកនៅក្រសួងពាណិជ្ជ

[58]គិតចាប់តាំងពីក្រសួងបានចេញសេក្តីប្រកាសលេខ៣០០ ពណ. ជបព. ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ មក។

កម្មទៀត ដែលចំណុចទាំងអស់នេះ គឺសុទ្ធសឹងតែមានភាពស្មុគស្មាញ និងពួកគេត្រូវធ្វើការចំណាយច្រើនទាំងប្រាក់កាស និងពេលវេលា។ ចំណែកឯ ចំពោះ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មវិញ យើងឃើញថា ពួកគាត់បានជួបប្រទះនូវការ លំបាកស្រដៀងគ្នាទៅ នឹងអ្នកស្នើសុំចុះបញ្ជីផងដែរ ដោយពួកគាត់មានការស្មុគស្មាញខ្លាំងជាមួយការប្រើប្រាស់ប្រព័ន្ធនេះ បូករួមទាំងការដែលតម្រូវឲ្យពួកគាត់ធ្វើការផ្លាស់ប្តូរ នូវបរិបទការងាររបស់ខ្លួន ពីការងារដែលប្រើប្រាស់ដោយផ្ទាល់ដៃ មកការងារដែលប្រើប្រាស់នូវប្រព័ន្ធអេឡិកត្រូនិចវិញ។ មួយវិញទៀតចំពោះការទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មវិញគឺកាន់តែលំបាក ដោយក្នុងនោះមានការតម្រូវឲ្យបង្កើតគណនីធនាគារមុន និងក្រោយមកក៏សម្រេចឲ្យមានការទូទាត់ដោយផ្ទាល់ដៃវិញ ដែលទាំងនេះគឺជាបញ្ហាប្រឈមមួយក្នុងការចុះបញ្ជី មិនត្រឹមតែប៉ុណ្ណោះយើងឃើញថាចំពោះការទូទាត់ Online នេះមិនបានប្រព្រឹត្តទៅបានរលូននោះទេ ដោយសារតែមានភាពរអាក់រអួលផ្នែកបច្ចេកទេស បូករួមទាំងការខ្វះខាត់ដៃគូរធនាគារដើម្បីសហការផងដែរ។ លើសពីនេះ ការប្រើប្រាស់ប្រព័ន្ធនេះ មន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មត្រូវតែមានគណនីផ្ទាល់ខ្លួន ប្រើប្រាស់ក្នុងការបំពេញភារកិច្ចរបស់ខ្លួនដូចជា ដើម្បីការទទួលឯកសារ តម្កល់ទុកឯកសារ និងប្រើប្រាស់សម្រាប់ការទំនាក់ទំនងផ្ទាល់ជាមួយអតិថិជនដែលត្រង់នេះ បានបង្កឲ្យមានផលវិបាកមួយចំនួន ដល់ពួកគាត់ ក្នុងការបំពេញភារកិច្ចក្នុងការចុះបញ្ជីពាណិជ្ជកម្មនេះ ដែលបញ្ហានេះ យើងឃើញថា វាបានកើតមានឡើងតាំងពីចាប់ផ្តើមអនុវត្តជាលើកដំបូងរបស់ពួកគាត់។ ចំពោះបញ្ហាទាំងនេះ គឺដោយសារតែពួកគាត់មិនទាន់ចេះប្រើប្រាស់នូវប្រព័ន្ធនេះ ហើយខ្វះខាតព័ត៌មានផ្នែកច្ចេកទេស និងការមិនទាន់ស្ទាត់ជំនាញក្នុងការប្រើប្រាស់ជាដើម ដែលនាំឲ្យពួកគាត់ត្រូវចំនាយពេលវេលា ក្នុងការរៀនពីរបៀប នៃការប្រើប្រាស់នៃប្រព័ន្ធនេះជាចាំបាច់បន្ថែម ដែលត្រង់នេះបានធ្វើឲ្យមានឱនភាពមួយចំនួន ដែលបានកើតមានឡើងក្នុងការអនុវត្តជាលើដំបូង។

លើសពីនេះទៀតយើងឃើញថា ប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មតាមព័ន្ធអេឡិកត្រូនិច មិនត្រឹមតែ មានផលវិបាកដល់ក្រុមហ៊ុន សហគ្រាសដែលធ្វើការចុះបញ្ជីថ្មីនោះទេ ពោល គឺវាថែមទាំងបាននាំឲ្យមានការចុះបញ្ជីសារឡើងវិញ ពោលវាតម្រូវឲ្យនូវរាល់ក្រុមហ៊ុនដែលបានធ្វើការចុះបញ្ជីពាណិជ្ជកម្មរួមរាល់មុនការអនុវត្តប្រព័ន្ធនេះទាំងអស់ តម្រូវឲ្យមកធ្វើការចុះបញ្ជីសារឡើងវិញតាមប្រព័ន្ធនេះ ដែលការនេះបានធ្វើឲ្យមានការជះឥទ្ធិពលទៅដល់ពាណិជ្ជករ និងវិនិយោគគិនផងដែរ ព្រោះពួកគេមិនចង់ធ្វើការចំណាយក្នុងការចុះបញ្ជីសារជាថ្មីនោះទេ។ មួយវិញទៀតក្រសួងពាណិជ្ជកម្ម ក៏បានដាក់ចេញនូវកំណែទម្រង់មួយទៀត ដែលពាក់ព័ន្ធ នឹងការចុះបញ្ជីពាណិជ្ជកម្ម តាម

ប្រព័ន្ធអេឡិកត្រូនិច គឺ ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។ មិនត្រឹមតែប៉ុណ្ណោះក្រសួងពាណិជ្ជកម្ម បានផ្តួចផ្តើមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបង្កើតឡើងនូវ ក្រុមការងាររួមរៀបចំ យន្តការចុះបញ្ជីពាណិជ្ជកម្មរួមមួយ រវាងក្រសួងពាណិជ្ជកម្ម និង នាយកដ្ឋានពន្ធដារ ដើម្បីសម្រួល និងដោះស្រាយនូវបញ្ហានានាដែលពាក់ព័ន្ធ និងការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះ ដែលត្រង់នេះសរបញ្ជាក់ឲ្យឃើញថា ការចុះបញ្ជីពាណិជ្ជកម្មនេះ គឺមិនទាន់មានដំណើរការប្រព្រឹត្តទៅបានល្អប្រសើរនៅឡើយទេ ។ ទទឹមនឹងនេះទៀត យើងឃើញថាក្រសួងពាណិជ្ជកម្ម មិនទាន់បានរៀបចំនូវរចនាសម្ព័ន្ធណាមួយឲ្យសមស្រប និងការប្រើប្រាស់ប្រព័ន្ធស្វ័ប្រវត្តិកម្មនេះទេ ដែលជាហេតុនាំឲ្យមន្ត្រីទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្មមានការលំបាក ដោយសារតែ ពួកគាត់ត្រូវបំពេញការងារបច្ចេកទេសផ្នែកចុះបញ្ជីពាណិជ្ជកម្មផង និង ត្រូវបំពេញការងារបច្ចេកវិទ្យាផ្នែកព័ត៌មានវិទ្យាផង ហេតុនេះដោយមកពីក្រសួងពាណិជ្ជកម្មមិនទាន់មានមន្ត្រីផ្នែកព័ត៌មានវិទ្យា ក្នុងការសម្រួលដល់កិច្ចការនេះនៅឡើង។

សរុបសេចក្តីមក យើងរកឃើញថាផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះមានចំនួន៤ (បួន) ធំៗគឺ ទីមួយ ផលវិបាកក្នុងការប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ទីពីរ ផលវិបាកចំពោះការទូទាត់កម្រៃរដ្ឋបាលតាមប្រព័ន្ធស្វ័យប្រវត្តិ ទីបី ផលវិបាកចំពោះការគ្រប់គ្រងប្រព័ន្ធនៃការចុះបញ្ជីតាមប្រព័ន្ធអេឡិកត្រូនិច និង ទី៤ (បួន) គឺ ផលវិបាកនៃការធ្វើកំណែទម្រង់នៃការចុះបញ្ជីតាមប្រព័ន្ធអេឡិក។

តែផ្ទុយមកវិញដោយទទឹមនឹងផលវិបាកទាំងនេះ យើងឃើញប្រព័ន្ធនៃការចុះបញ្ជីពាណិជ្ជកម្មអេឡិកត្រូនិចនេះ ក៏មានគុណសម្បត្តិជាច្រើនផងដែរ ដោយវាបានធ្វើការកាត់បន្ថយនូវអំពើពុករលួយ កាត់បន្ថយបែបបទនិងពេលវេលាជាដើម ដែលទាំងនេះគឺជាសញ្ញាណមួយល្អ ក្នុងការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មនៅក្នុងប្រទេសកម្ពុជា ឲ្យកាន់តែមានភាពរីកចម្រើនឡើង ស្របតាមកាលានុវត្តភាពនៃពិភពលោកបច្ចុប្បន្ន ដែលជាលក្ខណៈពិសេសមួយ សម្រាប់កម្ពុជា ក្នុងការប្រកួតប្រជែងនៅលើទីផ្សារនៅក្នុងតំបន់ ជាពិសេសទៅលើការទាក់ទាញវិនិយោគ។ ហើយមួយវិញទៀត តាមរយៈការធ្វើបច្ចុប្បន្នភាព ជាបន្តបន្ទាប់ និង ការបណ្តុះបណ្តាលភ្នាក់ងារ ពីរបៀបប្រើប្រាស់ប្រព័ន្ធនេះជាច្រើនមកនេះ ក្នុងមួយរយៈពេលនេះ យើងឃើញថាបញ្ហានៃការចុះបញ្ជីនេះ គឺមានលក្ខណៈល្អប្រសើរឡើងជាងមុន ផងដែរ។

# អនុសាសន៍

ឆ្លងកាត់ការសិក្សាស្រាវជ្រាវ លើប្រធានបទផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិច និងបូករួមទាំងបានធ្វើការបកស្រាយខាងលើរួចមក ខ្ញុំបានរកឃើញនូវចំនុនមួយចំនួនក្នុងការដោះស្រាយចំពោះបញ្ហាផលវិបាកនៃការចុះបញ្ជីពាណិជ្ជកម្មនេះដូចជា៖

១. រៀបចំនូវរចនាសម្ព័ន្ធ និង តួនាទីថ្មីជូនដល់មន្ត្រីនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីឲ្យមានលក្ខណៈសមស្រប និង ការអនុវត្តប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេះ ព្រោះថាពេលដែលដាក់ឲ្យអនុវត្តការចុះបញ្ជីពាណិជ្ជកម្មនេះ ជាលើដំបូងក្រសួងពុំទាន់បានធ្វើកំណាទម្រង់នូវរចនាសម្ព័ន្ធនៃនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនោះឡើយទេ ដែរជាហេតុនាំឲ្យមានការលំបាក់ដល់មន្ត្រីរបស់ខ្លួន។

២. រៀបចំភ្នាក់ងារចុះបញ្ជីពាណិជ្ជកម្មនៅតាមក្រុមហ៊ុន សហគ្រាស ដើម្បីផ្តល់ជាឱកាស និង ភាពងាយស្រួល ដល់ការចុះបញ្ជីពាណិជ្ជកម្មរបស់ខ្លួន ដែលការនេះ គឺធ្វើឲ្យអតិថិជនកាន់តែមានទំនុកចិត្តលើប្រព័ន្ធនៃការរចុះបញ្ជីនេះថែមទៀតផង។ មួយវិញទៀតត្រូវរៀបចំឲ្យមានផងដែរ នូវបញ្ជរព័ត៌មានថ្មីមួយស្រាប់ផ្តល់ព័ត៌មានដល់អតិថិជនក្នុងករណីដែលពួកគេមកធ្វើការទំនាក់ទំនងដោយផ្ទាល់។

៣. ធ្វើការគ្រប់គ្រងនូវប្រព័ន្ធព័ត៌មានវិទ្យារបស់ខ្លួន ដោយខ្លួនឯងដោយត្រូវបង្កើតនូវនាយកដ្ឋានព័ត៌មានវិទ្យាមួយនៅ ក្នុងក្រសួងពាណិជ្ជកម្ម ដើម្បីសម្រួលការប្រើប្រាស់ប្រព័ន្ធសេវាកម្មនៅក្នុងក្រសួងទាំងមូលឲ្យកាន់តែមានភាពប្រសើរឡើង ក្នុងការជម្រុញឲ្យរដ្ឋាភិបាលក្លាយទៅជារដ្ឋាភិបាលអេឡិកត្រូនិចមួយ (E-Government)។

៤. ត្រូវរៀបចំប្រព័ន្ធស្វ័យប្រវត្តិកម្ម ជូនដល់មន្ទី និងសាខាចុះបញ្ជីពាណិជ្ជកម្ម ខេត្ត-ក្រុងទាំងអស់ ដើម្បីផ្តល់នូវសេវាកម្មចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច ទៅដល់អាជីវកម្មទាំងអស់ដើម្បីប្រើប្រាស់ និងងាយស្រួលក្នុងការចេញអាជ្ញាប័ណ្ណអាជីវកម្មដល់អាជីវករផងដែរ។

៥. ត្រូវបង្កើតច្បាប់ស្តីពីពាណិជ្ជកម្មអេឡិកត្រូនិចឡើង ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ និង ដោះស្រាយវិវាទផ្នែកពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិចនេ៕

## ឯកសារយោង


១. ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០០៥។

២.ច្បាប់ស្តីពីច្បាប់វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្មលេខនស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ១៩៩៥។

៣.ច្បាប់វិសោនកម្មស្តីពីច្បាប់វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ១៨, វិច្ឆិកា ១៩៩៩។

៤. អនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម។

៥. ប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ នឹងការប្រពឹត្តទៅរបស់នាយកដ្ឋាចុះបញ្ជីពាណិជ្ជកម្ម។

៦.ប្រកាសលេខ ២៩៩ ពណ ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម.។

៧.ប្រកាសលេខ ៣០០ ពន ចបព ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ ២០១៥ ស្តីពីការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

៨.ប្រកាសលេខ ១០៧ ពណ ចបព ប្រក ចុះថ្ងៃទី ០៥ ខែមេសា ឆ្នាំ ២០១៧ ស្តី ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម។

៩. ប្រកាសអន្តរក្រសួងលេខ ៩១៦៧ ចុះថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៧ ស្តីពីកម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម។

១០.ប្រកាសអន្តរក្រសួងលេខ ៩០០ សហវ ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០១៧ ស្តីពី ការបង្កើតក្រុមការងារដើម្បីរៀបចំយន្តការ ចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហរញ្ញវត្ថុ។

១១. សេចក្តីជូនដំណឹងលេខ១៦១៥ ព.ណ ចបពចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១៧ ស្តីពីនីតិវិធីទូទាត់កម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

១២.របាយការណ៍បូកសរុបការងារពាណិជ្ជកម្មប្រចាំឆ្នាំ២០១៦ និងទិសដៅអនុវត្តការងារឆ្នាំ២០១៧នៃក្រសួងពាណិជ្ជកម្ម។

១៣. សៀវភៅនីតិពាណិជ្ជកម្ម លោកសាស្ត្រាចារ្យគង់ សាផន បោះពុម្ពលើកទី១ ឆ្នាំ ២០១២។

១៤. សៀវភៅស្តពី នីតិវិធីនៃការចុះបញ្ជីពាណិជ្ជកម្មក្រុមហ៊ុនថ្មីមួយ របស់លោកប្រាក់ បូរ៉េត បោះពុម្ពលើកទី ១ ឆ្នាំ ២០០៧។

១៥. សៀវភៅណែនាំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម និងប្រកបអាជីវកម្មអនុលោមតាមច្បាប់ ដែលចេញដោយក្រសួងពាណិជ្ជកម្ម។

១៦.គេហទំព័រ:

- www.moc.gov.com.kh
- www.businessregistration.moc.gov.com.kh
- www.fostermoore.com
- www.mef.gov.kh

# សម្រង់ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១ ៖

- ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម
- ប្រកាសស្តីពីការចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- ប្រកាស្តីការចុះបញ្ជីក្រុមហ៊ុនសារឡើងវិញតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ប្រកាសស្តីពីការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម
- ប្រកាសអន្តរក្រសួងស្តីពីការបង្កើតក្រុមការងារចុះបញ្ជីពាណិជ្ជកម្មរួមរវាងក្រសួងពាណិជ្ជកម្ម និងនាយកដ្ឋានពន្ធដានៃកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីជូនដំណឹងស្តីពីនីតិវិធីនៃការបង់កម្រៃសេវារដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្

## ឧបសម្ព័ន្ធ២ ៖

- ពាក្យសុំចុះបញ្ជីពាណិជ្ជកម្ម
- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម
- សម្រង់ក្រុមហ៊ុន
- តារាងកម្រៃរដ្ឋបាលសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម

## ឧបសម្ព័ន្ធ៣ ៖

- វិធីប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្មចុះបញ្ជីពាណិជ្ជកម្ម។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

លេខ ១៩៦ ព.ណ. ក.ប.ក ប្រ.ក                ភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៤

នាយកដ្ឋានស្ថិតិនិងព័ត៌មានពាណិជ្ជកម្ម
ចូល លេខ [illegible]
ថ្ងៃទី ២០ ខែ [illegible] ឆ្នាំ២០១៤
បញ្ជូន ..........

# ប្រកាស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

*******

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចំបាច់របស់ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា    ទូរស័ព្ទ / ទូរសារ:(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA    Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ១៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង កាន់កាប់ការចុះបញ្ជីពាណិជ្ជកម្ម និងគ្រប់គ្រងតាមដានសកម្មភាពពាណិជ្ជកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និង ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ផ្តល់សេវាពិនិត្យ និងរក្សាទុកការអនុញ្ញាតឱ្យប្រើប្រាស់នាមករណ៍ក្រុមហ៊ុន សហគ្រាស
- ផ្តល់សេវាប្រឹក្សាយោបល់ទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម និងផ្តល់ព័ត៌មានពាក់ព័ន្ធ
- គ្រប់គ្រងការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ទុកឯកសារ ការរក្សាទុកព័ត៌មាន ទិន្នន័យក្រុមហ៊ុន សហគ្រាស
- រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាននានា ស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ ការរំលាយ-ការលុបឈ្មោះ ការតម្កល់ប្រតិវេទន៍ និងការគ្រប់គ្រងសមត្ថភាពពាណិជ្ជកម្មរបស់ក្រុមហ៊ុន សហគ្រាស
- សម្របសម្រួល ដោះស្រាយវិវាទ ដែលទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម ការកែប្រែ និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាស
- ត្រួតពិនិត្យ តាមដាន ផ្ទៀងផ្ទាត់ព័ត៌មាន-ទិន្នន័យ ការអនុវត្តកាតព្វកិច្ចផ្លូវច្បាប់របស់ក្រុមហ៊ុន សហគ្រាស និងសហការជាមួយស្ថាប័នមានសមត្ថកិច្ចនានាក្នុងការអនុវត្តភារៈកិច្ច
- គ្រប់គ្រងមណ្ឌលរក្សាទុកឯកសារចុះបញ្ជីពាណិជ្ជកម្ម
- គ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់នាយកដ្ឋាន
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានជូនអតិថិជនទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- ណែនាំ តាមដាន និងត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីវិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំ។

**ប្រការ២៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៣៖**

នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មានការិយាល័យចំណុះចំនួន ៥ (ប្រាំ) ដូចខាងក្រោម៖
- ការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ
- ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម
- ការិយាល័យចុះបញ្ជីកែប្រែពាណិជ្ជកម្ម
- ការិយាល័យប្រតិវេទន៍ និងតាមដានអាជីវកម្ម
- ការិយាល័យតម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម

ការិយាល័យនីមួយៗ ដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។

**ប្រការ៤៖**

**ការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ** មានភារកិច្ចដូចតទៅ៖
- ប្រចាំការនៅបញ្ជរជួរមុខរបស់នាយកដ្ឋាន
- ទទួលព័ត៌មាន និងប្រឹក្សាយោបល់ជាមួយអតិថិជនអំពីនីតិវិធីចុះបញ្ជីពាណិជ្ជកម្ម
- រៀបចំ និងផ្សព្វផ្សាយលិខិតបទដ្ឋាន បញ្ញត្តិច្បាប់នានារបស់នាយកដ្ឋាន
- បំពេញការងាររដ្ឋបាលទូទៅ និងហិរញ្ញវត្ថុ
- ពិនិត្យ រក្សាទុកនិងបញ្ជូននាមករណ៍ទៅសុំការអនុញ្ញាតពីថ្នាក់ដឹកនាំ ដែលអតិថិជនស្នើសុំចុះបញ្ជីគ្រាដំបូង និងនាមករណ៍ស្នើសុំកែប្រែ
- ត្រួតពិនិត្យ ទទួល និងប្រគល់សំណុំឯកសារចុះបញ្ជីពាណិជ្ជកម្មជូនអតិថិជន
- កាន់កាប់បញ្ជីកាលប្បវត្តិ ( ផ្តល់អត្តលេខចុះបញ្ជី និងផ្តល់លេខរៀងកាលប្បវត្តិ ) លើគ្រប់ឯកសារទាំងអស់ដែលស្នើសុំតម្កល់ទុកក្នុងនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍ និងបូកសរុបពីគ្រប់ការិយាល័យសម្រាប់នាយកដ្ឋានប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៥៖**

ការិយាល័យចុះបញ្ជីពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖
- ផ្តល់យោបល់ជូនអតិថិជនពីនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្មថ្មី

- ចុះបញ្ជីពាណិជ្ជកម្មថ្មី នូវរាល់សហគ្រាសពាណិជ្ជកម្ម សហគ្រាសឯកបុគ្គល សហគ្រាសសាធារណៈ គ្រឹះស្ថានធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និង ក្រុមហ៊ុនធានារ៉ាប់រង ។ល។
- ចូលរួមរៀបចំ និងអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មនៃការចុះបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច
- បញ្ចូល និងគ្រប់គ្រងទិន្នន័យចុះបញ្ជីពាណិជ្ជកម្មទៅក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ (DATABASE SERVER )
- រៀបចំលិខិតបទដ្ឋានស្តីពីការចុះបញ្ជីពាណិជ្ជកម្មថ្មី
- ចូលរួមដោះស្រាយវិវាទដែលអាចកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្មថ្មី
- គ្រប់គ្រងការចុះបញ្ជីតាមបណ្តាខេត្ត-រាជធានី
- ធ្វើរបាយការណ៍ និងបូកសរុបស្ថិតិរាល់ការចុះបញ្ជីពាណិជ្ជកម្មថ្មី
- ស្រាវជ្រាវ និងផ្តល់ព័ត៌មានទាក់ទងនឹងការចុះបញ្ជីពាណិជ្ជកម្ម
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៦៖**

ការិយាល័យចុះបញ្ជីកែប្រែ មានភារកិច្ចដូចតទៅ៖

- ផ្តល់យោបល់ជូនអតិថិជនពីនីតិវិធីក្នុងការចុះបញ្ជីពាណិជ្ជកម្ម និងត្រួតពិនិត្យសំណុំឯកសារ លើរាល់ការសុំកែប្រែ ក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្ម គ្រប់ប្រភេទ
- ចុះបញ្ជីរាល់ការកែប្រែរបស់ក្រុមហ៊ុន សហគ្រាស ៖ សហគ្រាសពាណិជ្ជកម្ម សហគ្រាសឯកបុគ្គល សហគ្រាសសាធារណៈ ការិយាល័យតំណាង ឬសាខាក្រុមហ៊ុនបរទេស គ្រឹះស្ថានធនាគារ គ្រឹះស្ថានហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ចុះបញ្ជីរាល់ការប្តូរទ្រង់ទ្រាយ ចុះបញ្ជីការបង្កើត ឬការកែប្រែសាខាក្រុមហ៊ុនក្នុងស្រុក និងរាល់ការកែប្រែផ្សេងៗទៀត
- ការចេញវិញ្ញាបនប័ត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មឡើងវិញ
- គ្រប់គ្រងការបញ្ចូលទិន្នន័យរាល់ការកែប្រែរបស់បណ្តាក្រុមហ៊ុន សហគ្រាសពាណិជ្ជកម្មក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ ( DATABASE SERVER )
- រៀបចំលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងការលើការកែប្រែ
- ចូលរួមដោះស្រាយបញ្ហាបណ្តឹងវិវាទទាំងឡាយដែលកើតឡើងពីរាល់ការចុះបញ្ជី-ពាណិជ្ជកម្មនិងរក្សាទុកនូវរាល់ឯកសារដែលពាក់ព័ន្ធ
- ធ្វើរបាយការណ៍ និងផ្តល់ស្ថិតិសហគ្រាសពាណិជ្ជកម្ម ដែលបានធ្វើការកែប្រែ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

## ប្រការ៧៖

កាវិយាល័យប្រតិវេទន៍ និងតាមដានអាជីវកម្ម មានភារកិច្ចដូចតទៅ៖

- តាមដាន និងត្រួតពិនិត្យការអនុវត្តន៍ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម បញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- គ្រប់គ្រងលើការងារបំពេញប្រតិវេទន៍ប្រចាំឆ្នាំ ការសុំផ្អាកឬបន្តសកម្មភាពអាជីវកម្ម ការរំលាយ-ការលុបឈ្មោះក្រុមហ៊ុន សហគ្រាស ការបញ្ចូលទិន្នន័យ ព័ត៌មាន និងវាយតម្លៃ កំណត់នូវស្ថានភាពក្រុមហ៊ុន សហគ្រាស-ក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ (DATABASE SERVER)
- ចេញលិខិតបញ្ជាក់ការបានបំពេញឬមិនបានបំពេញប្រតិវេទន៍ប្រចាំឆ្នាំតាមការចាំបាច់
- រៀបចំ និងផ្សព្វផ្សាយ លិខិតបទដ្ឋាន សេចក្តីជូនដំណឹង ប្រកាស និងចាត់វិធានការនានា ដែលពាក់ព័ន្ធទៅនឹងការមិនបានតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ ការផ្តល់ព័ត៌មានមិនពិត និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាសពីបញ្ជីពាណិជ្ជកម្ម
- សហការជាមួយស្ថាប័នមានសមត្ថកិច្ចដើម្បីពិនិត្យតាមដាន និងចុះធ្វើសម្រង់ព័ត៌មានទាក់ទងនឹងការអនុវត្តកាតព្វកិច្ចរបស់ក្រុមហ៊ុន សហគ្រាសតាមច្បាប់និងបទប្បញ្ញត្តិនានា
- ទទួលបន្ទុកការងារផាកពិន័យចំពោះក្រុមហ៊ុន សហគ្រាសដែលមិនគោរពច្បាប់ពាណិជ្ជកម្មជាធរមាន
- ចូលរួមដោះស្រាយវិវាទដែលកើតឡើងពីការចុះបញ្ជីពាណិជ្ជកម្ម និងការលុបឈ្មោះក្រុមហ៊ុន សហគ្រាសចេញពីបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍ និងផ្តល់ស្ថិតិនៃការបំពេញប្រតិវេទន៍ ការផ្អាកឬបន្តសកម្មភាពអាជីវកម្ម និងការលុបឈ្មោះសហគ្រាសពាណិជ្ជកម្ម ព្រមទាំងរៀបចំរបាយការណ៍វិវាទ
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

## ប្រការ៨៖

ការិយាល័យតម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម មានភារកិច្ចដូចតទៅ៖

- គ្រប់គ្រង ថែរក្សា ត្រួតពិនិត្យ តាមដានសំណុំឯកសារដែលបានអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្ម និងតម្កល់ទុកក្នុងឃ្លាំងឯកសារ
- គ្រប់គ្រងទិន្នន័យចុះបញ្ជីពាណិជ្ជកម្មក្នុងប្រព័ន្ធរក្សាទុកទិន្នន័យ(DATABASE SERVER) និងបញ្ចេញទិន្នន័យចុះបញ្ជីពាណិជ្ជកម្មលើគេហទំព័រ
- ផ្តល់ព័ត៌មានតាមរយៈឯកសារដែលបានតម្កល់ទុក ឬផ្តល់ឯកសារ ជាក់ស្តែងក្នុងករណីចាំបាច់ ដោយមានការអនុញ្ញាតពីប្រធាននាយកដ្ឋាន និងអគ្គនាយកសេវាពាណិជ្ជកម្ម

- ទទួលបញ្ជាក់លើច្បាប់ថតចម្លងសំណុំឯកសារចុះបញ្ជីពាណិជ្ជកម្ម
- បញ្ជាក់នីតិបុគ្គលិកលក្ខណៈនិងសម្រង់ព័ត៌មានអំពីការចុះបញ្ជីរបស់ក្រុមហ៊ុនសហគ្រាសពាណិជ្ជកម្ម
- ផ្តល់ព័ត៌មានជូនដល់អតិថិជន និង ចេញវិញ្ញាបនប័ត្របញ្ជាក់
- ចូលរួមដោះស្រាយវិវាទដែលអាចកើតមានឡើងពីការចុះបញ្ជីពាណិជ្ជកម្ម
- ធ្វើរបាយការណ៍បូកសរុបការងារការិយាល័យជូននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀត តាមការកំណត់របស់ថ្នាក់ដឹកនាំនាយកដ្ឋាន។

**ប្រការ៩៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ចាន់ ប្រាជ្ញសុីម

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# រចនាសម្ព័ន្ធនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម

ប្រធាននាយកដ្ឋាន
ចុះបញ្ជីពាណិជ្ជកម្ម

↓

អនុប្រធាននាយកដ្ឋាន
ចុះបញ្ជីពាណិជ្ជកម្ម

↓

- ការិយាល័យ ព័ត៌មាន និង ទំនាក់ទំនងសាធារណៈ
- ការិយាល័យ ចុះបញ្ជីពាណិជ្ជកម្ម
- ការិយាល័យ ចុះបញ្ជីកែប្រែពាណិជ្ជកម្ម
- ការិយាល័យ ប្រតិវេទន៍ និងតាមដានអាជីវកម្ម
- ការិយាល័យ តម្កល់ឯកសារបញ្ជីពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ២១៣ ព.ណ ចបព.ប្រក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

# ប្រកាស
# ស្តីពី
# ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចំបាច់ក្នុងទិសដៅកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ ។



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
ទូរស័ព្ទ / ទូរសារៈ (៨៥៥) -២៣ ៨៦៦ ៤៦៩
Phone/Facsimile: (855)-23 866 469

# សម្រេច

**ប្រការ១៖**

រាល់ពាណិជ្ជករ និងក្រុមហ៊ុនពាណិជ្ជកម្មទាំងឡាយ ដែលមានគ្រឹះស្ថាន សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងាររបស់ខ្លួននៅក្នុងព្រះរាជាណាចក្រកម្ពុជា មានកាតព្វកិច្ចចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម ពីគ្រប់ទីកន្លែងតាមរយៈគេហទំព័រ: www.businessregistration.moc.gov.kh ។

**ប្រការ២៖**

ពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល ត្រូវបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវទាំងអស់តាមទម្រង់កំណត់នៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ។ ព័ត៌មានស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ដែលបានបំពេញដោយ ពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល និងឯកសារតម្រូវសម្រាប់តម្កល់នៅក្រសួងពាណិជ្ជកម្ម ត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មជាទម្រង់អេឡិចត្រូនិក ។ ក្នុងករណី ពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល មិនអាចបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មដោយខ្លួនឯងបាន អាចមកក្រសួងពាណិជ្ជកម្មដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ។

**ប្រការ៣៖**

សំណុំឯកសារចុះបញ្ជីពាណិជ្ជកម្មដែលត្រូវបញ្ចូលក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មជាទម្រង់អេឡិចត្រូនិក មានដូចខាងក្រោម ៖

ក) សម្រាប់ការចុះបញ្ជីក្រុមហ៊ុន

១. ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ ជាដើម

២. លក្ខន្តិកៈក្រុមហ៊ុន

៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ម្ចាស់ហ៊ុន និងអភិបាល

៤. រូបថត ៤x៦

៥. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អភិបាល ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

៦. ករណីម្ចាស់ហ៊ុនជានីតិបុគ្គល ៖

- ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាម្ចាស់ហ៊ុន

៧. ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចខាងក្រោម ៖

- លក្ខន្តិកៈច្បាប់ដើម ចំនួន ០២ ច្បាប់
- ករណីម្ចាស់ហ៊ុនជានីតិបុគ្គល ៖ សេចក្ដីសម្រេចក្នុងការបង្កើតក្រុមហ៊ុននិងតែងតាំងអ្នកតំណាងនីតិបុគ្គលម្ចាស់ហ៊ុន ច្បាប់ដើម ចំនួន ០១ ច្បាប់
- លិខិតច្បាប់ដើមបញ្ជាក់អំពីឈ្មោះគណនីរបស់ក្រុមហ៊ុនដែលបានបើកនៅធនាគារណាមួយ ចំនួន ០១ ច្បាប់

ក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលលក្ខន្តិកៈច្បាប់ដើម ក្នុងចំរវេលា៣០ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់នឹងការចុះបញ្ជី និងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម ។

ខ) ការចុះបញ្ជីសាខា ឬការិយាល័យតំណាង

១. ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ ជាដើម
២. ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
៣. សេចក្ដីសម្រេចរបស់ក្រុមហ៊ុនដើមបង្កើតសាខា ឬការិយាល័យតំណាង និងតែងតាំងនាយកសាខា ឬការិយាល័យតំណាង
៤. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់នាយកការិយាល័យតំណាង ឬសាខា
៥. រូបថត ៤x៦
៦. សេចក្ដីប្រកាសដោយសុទ្ធចិត្តរបស់នាយកការិយាល័យតំណាង ឬសាខា ថាគ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការ ដែលស្ថិតនៅក្រោមច្បាប់ស្ដីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

គ) ការចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិ

១. ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ ជាដើម
២. កិច្ចសន្យាបង្កើតក្រុមហ៊ុន
៣. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់សហកម្មសិទ្ធិករ និងអ្នកគ្រប់គ្រង
៤. រូបថត ៤x៦

៥. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់អ្នកគ្រប់គ្រងថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

៦. ករណី សហកម្មសិទ្ធិករ ជានីតិបុគ្គល ៖

- ច្បាប់ចម្លងឯកសារគតិយុត្តិនៃការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនដើមដោយមានការបញ្ជាក់ស្របតាមការតម្រូវរបស់បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុន និងការតែងតាំងអ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ

៧. ក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម តាមប្រព័ន្ធស្វ័យប្រវត្តកម្ម ក្រុមហ៊ុនត្រូវផ្ញើមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនូវឯកសារដូចខាងក្រោម ៖

- កិច្ចសន្យាបង្កើតក្រុមហ៊ុនច្បាប់ដើម ចំនួន ០២ ច្បាប់
- ករណីសហកម្មសិទ្ធិករជានីតិបុគ្គល ៖
  សេចក្តីសម្រេចក្នុងការបង្កើតក្រុមហ៊ុននិងតែងតាំង
  អ្នកតំណាងនីតិបុគ្គលជាសហកម្មសិទ្ធិករ ច្បាប់ដើម ចំនួន ០១ ច្បាប់

ក្នុងករណី នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មមិនបានទទួលកិច្ចសន្យាបង្កើតក្រុមហ៊ុនច្បាប់ដើម ក្នុងចិរវេលា៣០ថ្ងៃនេះទេ ក្រសួងពាណិជ្ជកម្មអាចជំទាស់នឹងការចុះបញ្ជីនិងលុបចោលការចុះបញ្ជីពាណិជ្ជកម្ម ។

### ឃ) ការចុះបញ្ជីសហគ្រាសឯកបុគ្គល

១. ឯកសារបញ្ជាក់អាសយដ្ឋាន ដែលអាចជាវិក័យប័ត្រអគ្គិសនី វិក័យប័ត្រទឹក កិច្ចសន្យាជួលផ្ទះឬអគារ លិខិតប្រៃសណីយ៍ ជាដើម

២. អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់ឯកកម្មសិទ្ធិករ

៣. រូបថត ៤x៦ របស់ឯកកម្មសិទ្ធិករ

៤. សេចក្តីប្រកាសដោយសុទ្ធចិត្តរបស់ឯកកម្មសិទ្ធិករថា គ្មានជាប់ទោសពៃរ៍ក្នុងកិច្ចការពាណិជ្ជកម្ម រដ្ឋប្បវេណី ឬព្រហ្មទណ្ឌ និងមិនមែនជាមន្ត្រីរាជការដែលស្ថិតនៅក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ៤៖

ពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល ត្រូវធានាអះអាង ចំពោះព័ត៌មានស្នើសុំចុះបញ្ជីពាណិជ្ជកម្ម និងឯកសារតម្រូវដែលខ្លួនបានបំពេញ និងបញ្ចូលទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្ម ជាទម្រង់អេឡិចត្រូនិកថា ពិតជាព័ត៌មាននិងឯកសារត្រឹមត្រូវនិងមិនក្លែងបន្លំ ។ ប្រសិនបើមន្ត្រីចុះបញ្ជីនៃក្រសួងពាណិជ្ជកម្មរកឃើញថា ព័ត៌មាននិងឯកសារទាំងនោះមិនត្រឹមត្រូវឬមានការក្លែងបន្លំ ក្រសួងពាណិជ្ជកម្មនឹងចាត់វិធានការតាមមាត្រា ២៦ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីវិសោធនកម្ម ហើយ ពាណិជ្ជករ សហកម្មសិទ្ធិករ

ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាលនោះ ត្រូវទទួលទោសដូចមានកំណត់ក្នុងមាត្រា៤២ថ្មី និងមាត្រា៤៣ នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់ស្តីពីវិសោធនកម្ម ព្រមទាំងច្បាប់ពាក់ព័ន្ធដទៃទៀតជាធរមាន។

**ប្រការ៥៖**

ការទូទាត់កម្រៃសេវាដែលត្រូវបង់ចូលជាថវិការដ្ឋ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារផ្អែកតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៨៣ សហវ. ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន ឬលិខិតបទដ្ឋានដែលនឹងត្រូវបានធ្វើវិសោធនកម្ម ។ ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ ។ ក្នុងករណីពាណិជ្ជករ សហកម្មសិទ្ធិករ ស្ថាបនិក ម្ចាស់ហ៊ុន ឬអភិបាល អញ្ជើញមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ការទូទាត់កម្រៃសេវាត្រូវធ្វើដោយផ្ទាល់នៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៦៖**

ខ្លឹមសារប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៧៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ៨ ដើម្បីអនុវត្ត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងពាណិជ្ជកម្ម
លេខ ៧០០ ព.ណចបព.ប្រក

ភ្នំពេញ, ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៥

# ប្រកាស
## ស្តីពី
## ការចុះបញ្ជីពាណិជ្ជកម្មសារឡើងវិញ ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពី វិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ១៩១ ពណ ចបព ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- យោងតាមការចំបាច់ក្នុងទិសដៅកែទម្រង់ការងារចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្មដើម្បីសម្រួលដល់វិស័យឯកជន និងគោលបំណងកិច្ចសម្រួលពាណិជ្ជកម្មដោយកាត់បន្ថយបែបបទ។
- បានឃើញប្រកាសលេខ ២៩៩ ពណ.ចបព.ប្រក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម



ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
*Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA*
ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
*Phone/Facsimile: (855)-23 866 469*

<u>**សម្រេច**</u>

**<u>ប្រការ១៖</u>**

កំណត់ឲ្យរាល់ក្រុមហ៊ុន សហគ្រាស សាខា ការិយាល័យតំណាង បុត្រសម្ព័ន្ធ ឬទីភ្នាក់ងារទាំងឡាយ ដែលបានចុះបញ្ជីពាណិជ្ជកម្មមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ មកចុះបញ្ជីសាឡើងវិញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មរបស់ក្រសួងពាណិជ្ជកម្មតាមគេហទំព័រ:www.businessregistration.moc.gov.kh ដើម្បីឲ្យការផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យ ការបំពេញទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវផ្ញើជូន ឬចេញដោយក្រសួងពាណិជ្ជកម្មអាចធ្វើទៅបានតាមប្រព័ន្ធអេឡិចត្រូនិក។

**<u>ប្រការ២៖</u>**

អភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាស ត្រូវបំពេញព័ត៌មាននិងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវ។ អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសដែលបានចុះបញ្ជីសាឡើងវិញរួចហើយនឹងទទួលបានលេខចុះបញ្ជី និងវិញ្ញាបនបត្រថ្មីដែលផ្តល់ឲ្យតាមរយៈប្រព័ន្ធស្វ័យប្រវត្តកម្ម ដោយពុំមានកំណត់សុពលភាព ។

**<u>ប្រការ៣៖</u>**

ការចុះបញ្ជីសាឡើងវិញដូចមានចែងក្នុងប្រការ១ ត្រូវធ្វើឡើងចាប់ពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងអស់មិនទាន់បានចុះបញ្ជីសាឡើងវិញ ក្នុងចន្លោះពេលពីថ្ងៃទី០៤ ខែមករា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ត្រូវតែបម្រុងទុកនាមករណ៍ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជៀសវាងការបាត់បង់ឈ្មោះដែលបានចុះបញ្ជីមុនថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦។ នាមករណ៍បម្រុងទុកមានសុពលភាព០៣ (បី) ខែ និងអាចស្នើសុំពន្យារពេល០៣ (បី)ខែ បន្តទៀតបានដោយមិនតម្រូវឲ្យបង់កម្រៃសេវាឡើយ។

ការបម្រុងទុកនាមករណ៍តាមប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ក្រុមហ៊ុនដែលបានចុះបញ្ជីរួចមុន ថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ ត្រូវបញ្ចូលឯកសារវិញ្ញាបនប័ត្រដែលបានចុះបញ្ជី។

ក្នុងករណីអភិបាលក្រុមហ៊ុន ឬម្ចាស់សហគ្រាសមិនអាចបំពេញព័ត៌មាន និងបញ្ចូលឯកសារទាំងអស់ទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មសម្រាប់ចុះបញ្ជីពាណិជ្ជកម្មតាមលក្ខខណ្ឌតម្រូវដោយខ្លួនឯងបាន អាចអញ្ជើញមកក្រសួងពាណិជ្ជកម្ម ដើម្បីស្នើសុំឲ្យមន្ត្រីចុះបញ្ជីពាណិជ្ជកម្មជួយបំពេញព័ត៌មាន និងបញ្ចូលឯកសារទៅក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស។

**ប្រការ៤៖**

ក្នុងករណី អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាស មិនបានចុះបញ្ជីសាឡើងវិញតាមកាលបរិច្ឆេទកំណត់ក្នុងប្រការ៣ នោះការចុះបញ្ជីសាឡើងវិញនៅតែអាចធ្វើបន្តបានរហូតដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ តែត្រូវបង់កម្រៃសេវាសាធារណៈពេញលេញដូចជាការចុះបញ្ជីថ្មីដែរ។

**ប្រការ៥៖**

ប្រសិនជា អភិបាលក្រុមហ៊ុន និងម្ចាស់សហគ្រាសទាំងឡាយមិនបានចុះបញ្ជីសាឡើងវិញមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៦ទេនោះ ក្រសួងពាណិជ្ជកម្មនឹងធ្វើលិខិតបញ្ជូនទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជម្រះកាតព្វកិច្ចពន្ធដារ និងបញ្ជូនទៅតុលាការដើម្បីអនុវត្តតាមនីតិវិធីច្បាប់។

**ការ៦៖**

ការទូទាត់កម្រៃសេវាដែលត្រូវបង់ចូលជាថវិកាជាតិ ត្រូវធ្វើតាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារផ្អែកតាមការកំណត់ក្នុងប្រកាសរួមលេខ ១៦៨៣ សហវ. ប្រក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤ រវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀតជាធរមាន។ ក្រុមហ៊ុនអាចរក្សាទុកនូវបង្កាន់ដៃបង់ប្រាក់ដែលចេញដោយប្រព័ន្ធស្វ័យប្រវត្តកម្ម ដើម្បីជាភស្តុតាងបញ្ជាក់ថាពិតជាបានធ្វើការទូទាត់ប្រាក់រួចហើយ។ ក្នុងករណី ស្ថាបនិក ឬអភិបាល ឬម្ចាស់ហ៊ុនអញ្ជើញមកនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មដើម្បីស្នើឲ្យមន្ត្រីចុះបញ្ជីជួយបំពេញនូវព័ត៌មាន និងបញ្ចូលលក្ខខណ្ឌតម្រូវក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មជំនួស ការទូទាត់កម្រៃសេវាត្រូវធ្វើដោយផ្ទាល់នៅបញ្ជរបង់ប្រាក់កម្រៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

**ប្រការ៧៖**

ខ្លឹមសារប្រកាសទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៨៖**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៦ តទៅ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**ចម្លងជូន:**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រចាំការ **គាត ឈន់**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អាជ្ញាធរសេវនកម្មជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានគាំពារគ្រួល
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ៨ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ១០៧ ពណ.ចបព.ប្រក

# ប្រកាស
# ស្តីពី
# ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៩១ ពណ.ចបព.ប្រក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
- ប្រកាសលេខ២១៣ពណ.ចបព.ប្រក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម

**ប្រការ ៨.**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្ម រាជធានី-ខេត្ត ប្រធានអង្គភាពនានាចំណុះក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ៧៤

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

ចម្លងជូន:
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រីប្រចាំការ **ប៊ិន ឈិន**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងស្ថាប័នពាក់ព័ន្ធ
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាល រាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ៨ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.៨១០.......សហវ

**ក្រសួងពាណិជ្ជកម្ម**

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីរៀបចំយន្តការ
## ការចុះបញ្ជីពាណិជ្ជកម្ម និងពន្ធដាររួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ នស.៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសារពើពន្ធ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី វិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម និងច្បាប់វិសោធនកម្ម

-បានឃើញព្រះរាជក្រមលេខ សន/រកម/០៦០៥/១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ ស្តីពីសហគ្រាសពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92,Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ: ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងប្រកាសលេខ២៩៩ ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- យោងប្រកាសលេខ៣០០ ចបព.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីការចុះបញ្ជីពាណិជ្ជកម្មសាឡើងវិញ ក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្ម
- យោងសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.ពហ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី លើករណីសំណើសុំគោលការណ៍របស់ក្រសួងពាណិជ្ជកម្ម សុំអនុវត្តជម្រើសទី១ "ក្រោមក្របខ័ណ្ឌដំបូលតែមួយ"
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងាររួមសម្រាប់រៀបចំ និងបង្កើតយន្តការចុះបញ្ជីរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារ និងដើម្បីគ្រប់គ្រងឲ្យកាន់តែប្រសើរឡើងនូវទិន្នន័យសហគ្រាសដែលបានចុះបញ្ជី ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **គង់ ទិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សហប្រធាន |
| ២. ឯកឧត្តម **សុខ សុភ័ក្រ្ត** | អនុរដ្ឋលេខាធិការនៃក្រសួងពាណិជ្ជកម្ម | សហប្រធាន |
| ៣. ឯកឧត្តម **ម៉ក់ ខុសតា** | អគ្គនាយកសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៤. ឯកឧត្តម **ហោង សុខណាង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ | អនុប្រធាន |
| ៥. លោកស្រី **ម៉ុម ថាណា** | អគ្គនាយកសេវាពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦. លោក **ខិម តារាឫទ្ធិ** | ប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. លោក **ម៉ៅន ភ្លេន** | ប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨. លោក **គង់ សុខហេង** | អនុប្រធាននាយកដ្ឋានសេវាអ្នកជាប់ពន្ធនិងបំណុលពន្ធ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩. លោក **លីម ជីលុច** | អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យានៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០. លោក **ឡូវី ម៉ាន់ ណារី** | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១១. លោក **ស៊ុំ ម៉ិច** | អនុប្រធាននាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១២. លោក **គន់ ឌីរ៉េច** | ប្រធានការិយាល័យព័ត៌មាន និងទំនាក់ទំនងសាធារណៈ | លេខាធិការ |
| ១៣. លោក **ខ៉ែត ណៃលាង** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៤. លោក **កែច ម៉េងតា** | ប្រធានការិយាល័យសេវាអ្នកជាប់ពន្ធ និងចុះបញ្ជី នៃនាយកដ្ឋានសេវាអ្នកជាប់ពន្ធ និងបំណុល នៃអគ្គនាយកដ្ឋានពន្ធដារ | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារនេះមានភារកិច្ចរៀបចំយន្តការចុះបញ្ជីរួមរវាងក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចខាងក្រោម÷

- រៀបចំយន្តការ នីតិវិធី លិខិតបទដ្ឋាននានា ដើម្បីចុះបញ្ជីពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដាររួមគ្នា
- រៀបចំយន្តការតភ្ជាប់ប្រព័ន្ធ និងកម្មវិធីការងារ ដើម្បីអនុវត្តកិច្ចការងារចុះបញ្ជីរួម
- រៀបចំគម្រោងបច្ចេកទេស និងថវិកាដែលត្រូវការ សម្រាប់រៀបចំនិងដាក់អនុវត្តយន្តការចុះបញ្ជីរួម
- រៀបចំកិច្ចប្រជុំជាប្រចាំក្នុងរយៈពេលមួយខែម្តង ឬតាមការចាំបាច់ តាមការអញ្ជើញរបស់សហប្រធាន។ ក្រុមការងារអាចអញ្ជើញជំនាញការ និងអ្នកជំនាញរបស់តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ចូលរួមផ្តល់យោបល់លើការងារពាក់ព័ន្ធ។

**ប្រការ ៣.-**

គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់អង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងប្រការ១ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**<u>ចម្លងជូន:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
KINGD0M OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
អគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម
General Directorate of Trade Support Services
នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម
Department of Commercial Registration

លេខទម្រង់/Form No.: ………………………

# ពាក្យស្នើសុំចុះបញ្ជីក្រុមហ៊ុន
## Application for Company Registration
## សម្រាប់ក្រុមហ៊ុនឯកជន/មហាជនទទួលខុសត្រូវមានកម្រិត
## For Private/Public Limited Company

| **ឯកសារត្រូវភ្ជាប់ជាមួយទម្រង់នេះ**/Documents to be attached with this form: | |
|---|---|
| ☐ កម្មវត្ថុអាជីវកម្ម / Business Objective | ☐ ព័ត៌មានអំពីអភិបាល / Director Details |
| ☐ សកម្មភាពអាជីវកម្មចម្បង / Main Business Activities | ☐ ព័ត៌មានអំពីម្ចាស់ហ៊ុន / Shares and Shareholders Details |
| ☐ អនុស្សរណៈ/លក្ខន្តិកៈក្រុមហ៊ុន / Memorandum/ Articles of Association | ☐ ឯកសារបញ្ជាក់អាសយដ្ឋាន / Proof of Address[2] |
| ☐ ប្រភេទតួនាទីនៅក្នុងក្រុមហ៊ុន / Employee Position Details[1] | ☐ ផ្សេងទៀត / Other : ………………………………………… …………………………………………………………………… …………………………………………………………………… |

| 1. **ព័ត៌មានទូទៅ**/General Information | |
|---|---|
| ឈ្មោះក្រុមហ៊ុនដែលស្នើសុំ (ខ្មែរ)៖ | |
| Name of Proposed Company (in Latin): | |
| ប្រភេទក្រុមហ៊ុន/Type of Company: | ☐ ឯកជនទទួលខុសត្រូវមានកម្រិត/Private Limited Company<br>☐ មហាជនទទួលខុសត្រូវមានកម្រិត/Public Limited Company |

| 2. **ព័ត៌មានភាគហ៊ុន**/Share Information | | | |
|---|---|---|---|
| តម្លៃគោលភាគហ៊ុន/Share Par Value (KHR): | | | |
| តម្លៃគោលភាគហ៊ុនប្រហាក់ប្រហែល/Par Value Equivalent (USD): | | | |
| ចំនួនភាគហ៊ុនមូលធន/Number of Share Capital: | | | |
| មានប្រភេទភាគហ៊ុនច្រើន/More than one class of share?: ☐ មែន ☐ មិនមែន | | | |
| សញ្ជាតិរបស់ម្ចាស់ហ៊ុនច្រើនជាងគេ/ Nationality of Majority Shareholders: | | ចំនួនភាគរយ/ Percentage: | |

| 3. **អាសយដ្ឋាន**/Addresses | |
|---|---|
| អាសយដ្ឋានជាក់ស្តែង/ Physical Registered Address: | ផ្ទះលេខ/House No ............. ផ្លូវ/Street ........................................<br>ខណ្ឌ/ស្រុក/District ........................................... ឃុំ/សង្កាត់/Commune |

[1] ដូចជាគណនី ទីផ្សារ ព័ត៌មានវិទ្យា ។ល។ / Details of the positions of each professional employee e.g. accountant, marketing, IT etc.

[2] ឯកសារដូចជាវិក័យបត្រភ្លើង ទឹក ។ល។ / Please provide a telephone, utility or other bill that has been sent to your address

| | |
|---|---|
| | ................................................ ភូមិ/Village ........................................<br>ខេត្ត/ក្រុង/City/Province ............................ ប្រទេស/Country ............................<br>លេខកូដប្រៃសណីយ/Postal Code ............................ |
| អសយដ្ឋានសម្រាប់ទំនាក់ទំនង/ Postal Registered Address: | ☐ ដូចខាងលើ (មិនចាំបាច់បំពេញបន្ថែម)/ Same as above (no need to fill in details)<br>☐ មិនដូច (ចូរបំពេញ) / No (please fill)<br>ផ្ទះលេខ/House No ............. ផ្លូវ/Street ........................................<br>ខណ្ឌ/ស្រុក/District ........................................ ឃុំ/សង្កាត់/Commune<br>................................................ ភូមិ/Village ........................................<br>ខេត្ត/ក្រុង/City/Province ............................ ប្រទេស/Country ............................<br>លេខកូដប្រៃសណីយ/Postal Code ............................ |
| អ៊ីម៉ែល/Contact Email (print): | |
| លេខទូរស័ព្ទ/Telephone: | |

| 4. **ចំនួនបុគ្គលិក**/Number of Employees | | | |
|---|---|---|---|
| ចំនួនបុគ្គលិកភេទប្រុស/ Male Employees: | | ចំនួនបុគ្គលិកភេទស្រី/ Female Employees: | |
